# បណ្តាញផ្លូវសម័យអង្គរនិងរចនាសម្ព័ន្ធពាក់ព័ន្ធ

អ៊ឹម សុខរិទ្ធី
*អាជ្ញាធរអប្សរា*

## ការងារកន្លងមក

អត្ថបទនេះផ្អែកទៅលើផ្នែកមួយនៃសារណារបស់ខ្ញុំអំពី "Réseaux routiers et moyens de transport à l'époque angkorienne"[១] បូកបញ្ចូលជាមួយការស្រាវជ្រាវបន្តរបស់ខ្ញុំកន្លងមកទៀតអំពីគមនាគមន៍សម័យអង្គរនិងរចនាសម្ព័ន្ធពាក់ព័ន្ធ ដើម្បីស្វែងយល់បន្ថែមនិងផ្ទៀងផ្ទាត់ឡើងវិញ ព្រមទាំងបំពេញការខ្វះខាតលើការស្រាវជ្រាវពីមុន។ ជាពិសេស ទិន្នន័យទាក់ទងនឹងបណ្តាញផ្លូវឆ្ពោះ ទៅដែនដីថៃឡូងដីសព្វថ្ងៃនៅក្នុងអត្ថបទនេះបានមកពីគម្រោងស្រាវជ្រាវរួមមួយរវាងខ្មែរ-ថៃ អំពីផ្លូវបុរាណដែលចេញពីអង្គរទៅកាន់ភិម័យ។ គម្រោងនេះមានឈ្មោះជាផ្លូវការថា "Living Angkor Road" *(ការសិក្សាលើផ្លូវបុរាណដែលភ្ជាប់រាជធានីអង្គរទៅភិម័យ ៖ ទិដ្ឋភាពបុរាណនិងបច្ចុប្បន្ន)* ដែលកំពុងដំណើរការ។ *ភាគីថៃនៃក្រុមស្រាវជ្រាវនេះមាន “សាកលវិទ្យាល័យសិល្បករ” (*Silpakorn University*), “ក្រុមសិល្បករ” (*Fine Arts Department*)* និង *“រាជបណ្ឌិតយោធាចូឡាចមក្លាវ” (*Chulachomklao Royal Military Academy*)* ដែលដឹកនាំដោយបណ្ឌិត Surat Lertlum។ *រីឯភាគីខ្មែរ មានអតីតប្រធាននាយកដ្ឋានវប្បធម៌ និងស្រាវជ្រាវនៃអាជ្ញាធរអប្សរា, លោក គឹម សំណាង, ខៀវ ច័ន្ទ, ហេង ថាន, ស៊្រុន តិច, អ៊ា ដារិទ្ធ ព្រមទាំងរូបខ្ញុំ។*

នាឆ្នាំ១៩៩៩ សាស្ត្រាចារ្យ Yoshiaki Ishizawa និង Hitoshi Tamura ចេញផ្សាយសៀវភៅមួយដែលមានចំណងជើងថា “Along the Royal Roads to Angkor”។ *សៀវភៅនោះមានពីរផ្នែក ដែលទីមួយបង្ហាញពីរូបភាពប្រាសាទនៅអង្គរ និងទិដ្ឋភាពបច្ចុប្បន្ននៅសៀមរាប។ ផ្នែកទី២ជាអត្ថបទនិយាយអំពីផ្លូវ អមដោយរូបភាពនៃទិដ្ឋភាពសព្វថ្ងៃនៅតាមអតីតក្រុង ឬមណ្ឌលបុរាណនានាចំណុះអង្គរ ដែលអ្នកនិពន្ធយល់ថាពាក់ព័ន្ធនឹងរាជធានីអង្គរ តាមរយៈបណ្តាញផ្លូវមួយដែលគូសជាផែនទីបង្ហាញក្នុងសៀវភៅស្រាប់*[២]។ *នាដើម ស.វ.ទី២០ លោក*E. Lunet de Lajonquière បានសរសេរមុនគេបង្អស់ អំពីបណ្តាញផ្លូវចាស់និងរចនាសម្ព័ន្ធរបស់ផ្លូវក្នុងសៀវភៅបញ្ជីបេតិកភណ្ឌខ្មែរ[៣]។

*ការសិក្សារបស់ខ្ញុំផ្អែកមូលដ្ឋានលើទិន្នន័យផ្សេងៗដូចខាងក្រោម ៖*

- *ឯកសារសរសេរ ៖ មានសិលាចារិកជាច្រើន ដែលក្នុងចំណោមនោះ សិលាចារិកប្រាសាទព្រះខ័ន ជាប្រភពមូលដ្ឋានសម្រាប់ការ*

---

[១] Im 1998.
[២] Ishizawa & Tamura 1999.
[៣] Lunet de Lajonquière 1902-1911.

ស្រាវជ្រាវនេះ។ ស្លោកទី១២២_១២៦ នៃសិលាចារិកនេះរៀបរាប់អំពីសាលាសំណាក់ (សូមមើលបន្ថែមនៅខាងក្រោម) ចំនួន១២១ នៅតាមបណ្តោយផ្លូវដូចខាងក្រោម ៖

១_ បុរីយសោធរ (រាជធានីអង្គរ) ឆ្ពោះទៅភិម័យ

២_ យសោធរឆ្ពោះទៅរាជធានីចម្ប៉ា

៣_ និងលើផ្លូវវង់មួយខ្សែដែលចេញពីយសោធរ រួចត្រលប់ចូលមកយសោធរវិញ។

ក្រៅពីនេះ មានអត្ថបទដែលជាកំណត់ហេតុនៃអ្នកជំនួញផ្សេងៗ ដែលបានឆ្លងកាត់ស្រុកខ្មែរ។ ជាពិសេសកំណត់ហេតុអ្នកការទូតចិនគឺសំណេររបស់លោក ជីវ តាក្វាន់ នាចុងសតវត្សទី១៣ រៀបរាប់ជីវភាពរស់នៅនិងទំនៀមទម្លាប់របស់អ្នកស្រុកនៅរាជធានីអង្គរ។

_ សំណល់នៃសំណង់បុរាណ ៖ សំដៅលើស្លាកស្នាមដែលមាននៅសល់ដល់បច្ចុប្បន្ន ដូចជាស្នាមខ្សែផ្លូវ, ប្រព័ន្ធទឹក (ទំនប់ប្រឡាយ), ប្រាសាទនានា, មន្ទីរពេទ្យ, សាលាសំណាក់, ស្ពាន ហើយនិងស្រះទឹក ដែលតាំងនៅតាមបណ្តោយផ្លូវ។

_ សំណល់ផ្សេងៗដែលបានមកពីការស្រាវជ្រាវ តួយ៉ាងដូចជាកំណាយស្រាវជ្រាវជាដើម

_ ចម្លាក់នៅតាមជញ្ជាំងថែវប្រាសាទបាយ័ន្តនិងបន្ទាយឆ្មារ។ ចម្លាក់នៅប្រាសាទទាំងពីរនេះ រៀបរាប់ព្រឹត្តការណ៍សំខាន់ៗ មានចម្បាំងរវាងខ្មែរនិងចាម និងចម្បាំងបង្ក្រាបការបះបោរក្នុងស្រុក ។ល។

_ ព្រមទាំងទិន្នន័យដែលបានមកពីការវិភាគលើរូបភាពថតពីលើអាកាស មានរូបភាពថតពីលើយន្តហោះនិងរូបភាពថតពីផ្កាយរណប។ ការវិភាគបង្ហាញឲ្យយើងឃើញពីស្នាមគំនូសវែងត្រង់ៗ ដែលជាផ្លូវនិងប្រព័ន្ធរៀបចំទឹកបុរាណ។ល។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងក្របខណ្ឌនៃសម័យអង្គរប៉ុណ្ណោះ ដោយផ្តើមពីរាជធានីអង្គរដែលជាមណ្ឌលនៃចក្រភពខ្មែរ។ ការបរិយាយជាបន្តបន្ទាប់នៅខាងក្រោម មានចែកជា៣ចំណុច ៖

_ ទី១ ៖ ប្រភេទផ្លូវដែលសំដៅលើផ្លូវថ្នល់ផ្សេងៗ មានប្រភេទផ្លូវក្នុងរាជធានី, ផ្លូវចេញពីរាជធានី, និងផ្លូវអ្នកស្រុកប្រើប្រាស់ប្រចាំថ្ងៃជាដើម។

_ ទី២ ៖ គឺបណ្តាញផ្លូវប្រើប្រាស់នៅក្នុងរាជធានី និងចេញទៅមណ្ឌល ក្រៅ។

_ ទី៣ ៖ រចនាសម្ព័ន្ធពាក់ព័ន្ធនឹងបណ្តាញផ្លូវមានស្ពានថ្ម, សាលាសំណាក់, មន្ទីរពេទ្យ និង "សំណង់រក្សាទឹក"[៤] ផ្សេងៗ។

ស្ថានភាពភូមិសាស្ត្រស្រុកខ្មែរផ្តល់លក្ខណៈងាយស្រួលដល់វិស័យគមនាគមន៍។ ទំនាបកណ្តាលគ្របដណ្តប់ស្ទើរតែពេញផ្ទៃប្រទេស។ ជួរភ្នំពាត់ជុំវិញទំនាបកណ្តាល ដូចជាជួរភ្នំដងរែកពាត់ពីខាងជើង, ជួរភ្នំក្រវាញនៅត្បូង, និងភ្លៀសានមានជួរភ្នំអាណាម។ ជួរភ្នំទាំងនេះ មិនបង្ករជាឧបសគ្គដល់ផ្លូវចរាចរណ៍ឡើយ។ វាលទំនាបកណ្តាលមួយផ្នែកធំលិចទឹកនៅរដូវវស្សា ដែលលាតសន្ធឹងពីទិសអាគ្នេយ៍នៅតំបន់ដីសណ្តរទន្លេមេគង្គ (ប្រទេសវៀតណាមខាងត្បូងបច្ចុប្បន្ន) ទៅកាន់ពាយ័ព្យវាលរាបទន្លេមេណាម (ប្រទេសថៃឡង់ដ៍)។ វាលទំនាបនេះ មានរយៈកំពស់ទាប ហើយមានកម្រិតកំពស់ប្រែប្រួលខុសគ្នាប្រមាណពី១០ទៅ៣០ម៉ែត្រ។

នៅរដូវវស្សា ប្រព័ន្ធជលសាស្ត្រនេះនាំមកជាមួយនូវដីល្បាប់ដ៏មានជីរជាតិមកកកនៅតាមវាលរាបជុំវិញជាប្រចាំ។ នារដូវប្រាំង ទឹកចាប់ស្រកទៅវិញ។ វាលរាបនេះក្លាយជាវាលដាំដំណាំដ៏ធំល្វឹងល្វើយ។ មនុស្សមកតាំងទីរស់នៅលើតំបន់នេះ ដើម្បីប្រកបរបរកសិកម្ម។ កសិកម្មលូតលាស់ធ្វើឲ្យមានទំនាក់ទំនងរវាងសហគមន៍ផ្សេងៗ តាមរយៈការដោះដូរនៃផលិតផលគ្នាទៅវិញទៅមក។ ម្យ៉ាងទៀត ដើម្បីសម្រួលដល់ជីវភាពអ្នកស្រុករាជការបានរៀបចំបុរី និងការប្រើប្រាស់ដីជាបន្តបន្ទាប់ដែលនាំមកការបង្កើតហេដ្ឋារចនាសម្ព័នផ្សេងៗ ដូចជាបណ្តាញផ្លូវយ៉ាងខ្វាត់ខ្វែងជាដើម។

ដើម្បីទប់ទល់នឹងគុណវិបត្តិនៃធម្មជាតិ ដូនភ្លៀងច្រើន ដូនខ្សត់ ព្រមទាំងបង្កើនសង្វាក់ផលិតកម្មនៃកសិកម្ម ខ្មែរមានមធ្យោបាយដោះស្រាយតាំងពីបុរាណរៀងមក។ នោះគឺជាការងាររៀបចំប្រព័ន្ធស្រោចស្រប់ទឹក ឬហៅថា "ប្រព័ន្ធធារាសាស្ត្រ"។ បច្ចេកទេសនេះ ឃើញមានប្រើប្រាស់តាំងពីសម័យមុនអង្គរមកម្លេះ ហើយចេះតែវិវឌ្ឍបន្តិចម្តងៗរហូតមក។ ចុងស.វ.ទី៩ ប្រព័ន្ធធារាសាស្ត្រនេះបានអភិវឌ្ឍខ្លាំងណាស់

[៤] ខ្ញុំសូមប្រើពាក្យនេះ ដើម្បីសម្គាល់នូវរាល់សំណង់នានាដែលកើតដោយមនុស្សលើក ឬជីក ឬកើតដោយធម្មជាតិរួច មនុស្សមកកែច្នៃសម្រាប់រក្សាទឹកទុកប្រើប្រាស់ មានស្រះ, កញ្ចាន, ត្រពាំង, រហាល, រលំ, ខ្នារ, ល្បើក, ទន្លេ, បារាយជាដើម។

ដែលជាកត្តាធ្វើឱ្យវិស័យសេដ្ឋកិច្ចរីកចម្រើន។ លើសពីនេះទៅទៀត ប្រព័ន្ធនេះក៏មាននាទីប្រើប្រាស់ជាគមនាគមន៍ តភ្ជាប់សហគមន៍មួយទៅសហគមន៍មួយទៀត។

ខ្មែរទទួលឥទ្ធិពលអារ្យធម៌ឥណ្ឌា ប្រហែលជាចាប់តាំងពីដើមនៃគ្រឹស្តសករាជ្យមក តាមរយៈចរន្តសាសនាពីរ គឺព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា។ ការរៀបចំបុរីក៏ធ្វើឡើងក្នុងទ្រង់ទ្រាយជា រូបភាពបង្រួមនៃលោកទាំងមូលតាមទស្សនៈសាសនាដែរ។ គឺថា បុរីតំណាងឲ្យចក្រវាឡ ហើយជាស្ថាននៃទេពដែលឧទ្ទិសថ្វាយដោយព្រះមហាក្សត្រ។ នៅចំកណ្តាលបុរី មានប្រាសាទធំមួយដែលសាងឡើងលើខឿនជាថ្នាក់ៗ រាងជាសាជីហៅថា “ប្រាសាទភ្នំ” ព្រមទាំងមានថ្នល់រត់តាមទទឹងនិងបណ្តោយថ្ងៃ ចេញអំពីប្រាសាទទៅកាន់ទិសធំៗទាំង៤។ ប្រាសាទភ្នំជាប្រាសាទសម្រាប់រាជ្យ ជាទីគោរពបូជាផ្ទាល់របស់ព្រះមហាក្សត្រ។ ពេលដែលព្រះអង្គសោយទីវង្គត ប្រាសាទនេះក្លាយជាស្ថានសោយសុខរបស់ព្រះអង្គឯបរលោក។ ព្រះមហាក្សត្រថ្មីឡើងគ្រងរាជ្យក្រោយៗ ក៏បន្តរៀបចំទឹកដីតាមទស្សនៈតែមួយ ព្រមទាំងស្ថាបនាប្រាសាទថ្មីបន្ថែមសម្រាប់ ការគោរពបូជាផ្ទាល់របស់ព្រះអង្គ។ ការងាររៀបចំទឹកដីនេះ ចេះតែបានធ្វើឡើងជាបន្តបន្ទាប់រៀងមក បង្កើនឲ្យហេដ្ឋារចនាសម្ព័ន្ធនៅអង្គរចេះតែកើនចម្រើន។

នយោបាយក្រៅប្រទេសនៃសម័យអង្គរ សម្គាល់ឃើញមានព្រឹត្តការណ៍ពីរសំខាន់ គឺទំនាក់ទំនងការទូតជាមួយអាណាចក្រជិតខាង ហើយនិងចម្បាំងជាមួយនឹងអាណាចក្រអាណាមនិងចម្ប៉ា។ ការផ្លាស់ប្តូរទូតរវាងខ្មែរនិងអាណាចក្រផ្សេងៗ ធ្វើឲ្យយើងដឹងអំពីផ្លូវនៃដំណើរគោចរនោះ។ ឧទាហរណ៍ លោក ជីវ តាក្វាន់ បានសរសេររៀបរាប់អំពីដំណើរមកកាន់អាណាចក្រខ្មែរ តាំងពីកន្លែងចេញដំណើររហូតមកដល់រាជធានីអង្គរ។ នាស.វ.ទី១២និង១៣ ខ្មែរបានលើកទ័ពជាច្រើនសារទៅច្បាំងនឹងនគរចម្ប៉ានិងអាណាម។ ទ័ពខ្មែរប្រហែលប្រើប្រាស់ផ្លូវយុទ្ធសាស្ត្រណាមួយរបស់ខ្លួនក្នុងការលើកទ័ពទៅកាន់នគរទាំងពីរខាងលើ។

ពាណិជ្ជកម្មសម័យបុរាណធ្វើឡើងតាមរបៀបប្រព័ន្ធដោះដូរគ្នា ជាវត្ថុទល់នឹងវត្ថុ។ ប្រាក់កាសប្រើប្រាស់ក្នុងវិស័យជួញដូរ ពុំទាន់មាននៅឡើយ។ អ្នកស្រុកដោះដូរគ្នាជារបស់ប្រើប្រាស់គ្រប់ប្រភេទទៅវិញទៅមក។ អ្នកជំនួញជួញដូររវាងផលិតផលក្នុងស្រុកជាមួយវត្ថុនាំចូលពីបរទេស ជាពិសេសរបស់នាំចូលពីឥណ្ឌានិងចិន។ លោកជីវ តាក្វាន់បានសង្កេតឃើញមានវត្ថុច្រើនមុខណាស់ នាំយកមកពីស្រុកចិនមានដោះដូរលើទីផ្សារខ្មែរ។ តាមរយៈពាណិជ្ជកម្មនេះ ធ្វើឲ្យយើងដឹងអំពីផ្លូវធ្វើដំណើរចេញចូលស្រុកខ្មែរនៃឈ្មួញសម័យនោះ។

## ក. ប្រភេទផ្លូវ

ចាប់ពីចុងស.វ.ទី៨ដល់ទី១៤ រាជធានីនៃអាណាចក្រខ្មែរតាំងនៅជាបន្តបន្ទាប់ក្នុងវាលរាបទន្លេសាប គឺស្ថិតនៅចន្លោះភ្នំគូលេនដែលស្ថិតនៅខាងជើងនិងទន្លេសាបនៅខាងត្បូង (មើលរូបទី១)។ តំបន់នេះអ្នកស្រាវជ្រាវហៅថា “វាលរាបអង្គរ” ដែលយើងមើលឃើញស្លាកស្នាមជាគំនូសដីខ្វាត់ខ្វែង។ ទាំងនោះជាសំណល់នៃបណ្តាលផ្លូវ, សំណង់ផ្សេងៗនៅតាមបណ្តោយផ្លូវនិងប្រព័ន្ធធារាសាស្ត្រ។ ការសិក្សាលើសំណល់ទាំងនេះអាចឲ្យយើងសម្គាល់ថ្នល់ជាប្រភេទផ្សេងៗ ដែលមានទំហំធំតូចផ្សេងៗគ្នា។ ថ្នល់ដែលមានទំហំធំ ឃើញមាននៅក្នុងរាជធានី ហើយជាថ្នល់ទទឹងនិងបណ្តោយថ្ងៃចេញពីប្រាសាទភ្នំ។ ថ្នល់ធំៗខ្លះទៀតចេញពីរាជធានីទៅកាន់មណ្ឌលរដ្ឋបាលផ្សេងៗនៃព្រះរាជាណាចក្រ។ ថ្នល់ខ្លះ មានទំហំតូចរត់ស្របតាមផ្លូវធំក្នុងរាជធានី ភ្ជាប់ពីសង្កាត់មួយទៅសង្កាត់មួយទៀត។ ថ្នល់ខ្លះមានរត់តាមបណ្តោយប្រាំងផ្លូវទឹក ឬប្រឡាយជាដើម។ មួយចំនួនទៀតកើតឡើងដោយអ្នកស្រុកធ្វើដំណើរទៅមករាល់ថ្ងៃ ដោយសត្វពាហនៈនិងរទេះគោក្របី បង្កើតបានជាស្នាមផ្លូវរាងស្រុតកណ្តាលហើយមានកំពស់ទាបជាងចិញ្ចើមសងខាង។

### ក.១. ថ្នល់ក្នុងរាជធានី

តាំងពីដើមសម័យប្រវត្តិសាស្ត្ររហូតមក ខ្មែរបានផ្លាស់ប្តូរទីតាំងរាជធានីនៅច្រើនតំបន់ខុសៗពីគ្នា តាមសម័យកាលផ្សេងៗ ព្រមទាំងធ្វើការស្ថាបនានិងជុសជុលស្តារសំណង់ស្ថាបត្យកម្មនៅគ្រប់ជំនាន់រាជ្យថ្មីនិមួយៗ។ ក្នុងរយះពេលច្រើនសតវត្សកន្លងទៅនេះ ព្រះមហាក្សត្រនានាស្ថាបនាសំណង់សម្រាប់ឧទ្ទិសដល់បុព្វការីជននិងសម្រាប់ការបូជាផ្ទាល់ ព្រមទាំងប្រាសាទតូចធំនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុងខេត្តខណ្ឌនៃព្រះរាជា




*រូបទី១_ ផែនទីវាលរាបអង្គរ (កែសម្រួលពីផែនទីនៃ* Royal Angkor Foundation *ឆ្នាំ ១៩៩៥)។*

ណាចក្រ។ បុរីរៀបចំឡើងតាមគម្រោងនគរោបនីយកម្មយ៉ាងជាក់លាក់ ដោយយកប្រាសាទភ្នំជាមណ្ឌល។ ពោលគឺរាជធានីជារូបភាពបង្រួមនៃចក្រវាឡនៅលើផែនដី ដែលប្រាសាទភ្នំនៅកណ្ដាលនោះជាភ្នំព្រះសុមេរុ។ ប្រាសាទភ្នំបែរមុខទៅទិសទាំងបួនតាមរយៈក្លោងទ្វារទាំងបួន។ បន្ទាប់មកថ្នល់ទទឹងនិងបណ្ដោយធំៗបួនភ្ជាប់បន្តពីក្លោងទ្វារទាំងនេះ។ ជាប្រភេទថ្នល់ដីលើក ដូចនឹងទំនប់ដែលមានផ្ទៃលើតូចជាងបាតក្រោម ហើយខ្លះមានស្រះនៅពីចំហៀងជាគូៗ ជីកបន្តគ្នាតាមបណ្ដោយថ្នល់។ ថ្នល់ភាគច្រើន ស្រះគូៗនោះក្លាយមកជាប្រឡាយវិញ។

ក្នុងរាជធានីផ្លូវសំខាន់ៗគឺជាថ្នល់ដែលរត់លើខ្សែទទឹងនិងបណ្ដោយថ្ងៃនេះឯង។ ដើម្បីងាយស្រួលហៅទៅក្រោយៗទៀត ខ្ញុំសូមស្នើហៅផ្លូវប្រភេទនេះ ជាបណ្ដោះអាសន្នថា “ថ្នល់ទទឹង” និង “ថ្នល់បណ្ដោយ”។ ឧទាហរណ៍ នៅហរិហរាល័យ (អតីតរាជធានីនៅតំបន់រលួសសព្វថ្ងៃ) ព្រះបាទឥន្ទ្រវរ្ម័ន ស្ថាបនាប្រាសាទបាគងសម្រាប់ការបូជាផ្ទាល់របស់ព្រះអង្គ ឬជាប្រាសាទសម្រាប់រាជ្យ ដែលជាមណ្ឌលនៃរាជធានី។ ផ្លូវសំខាន់នៃរាជធានីនេះគឺថ្នល់ទទឹងនិងថ្នល់បណ្ដោយដែលចេញពីប្រាសាទបាគងទៅតាមទិសធំៗទាំងបួន។ សព្វថ្ងៃ យើងអាចមើលឃើញសល់ស្នាមដោយផ្នែកខ្លះនៃថ្នល់ទាំងនោះ[៥] (មើលរូបទី២)។

---

[៥] Goloubew 1937.




*រូបទី២ - ហរិហរាល័យមើលពីលើអាកាស (ប្រភព ៖ JICA ឆ្នាំ ១៩៩៥)*

ក្រុងយសោធរមានប្រាសាទភ្នំបាខែងជាមណ្ឌល ដែលស្ថាបនាឡើងនាចុងស.វ.ទី៩ ដោយព្រះបាទយសោវរ្ម័ន នៅលើកូនភ្នំធម្មជាតិមានឈ្មោះដើមថា "វ្នំកន្ទាល" (ភ្នំកណ្ដាល) ឬជាសំស្ក្រឹតថា "យសោធរគិរិ"។ ថ្នល់ទទឹងនិងថ្នល់បណ្ដោយនៃបុរីថ្មីនេះ ចេញពីជើងភ្នំបាខែងតាមទិសទាំងបួន (មើលរូបទី៣)។ ប៉ុន្តែមកដល់សព្វថ្ងៃ យើងអាចសម្គាល់ឃើញស្លាកស្នាមផ្លូវបានបីជ្រុង គឺជ្រុងខាងកើត, ខាងត្បូង, និងខាងលិច។ ថ្នល់ទាំងបីនេះមានស្រះទឹកនៅចំហៀងទាំងពីរ[៦]។ រីឯថ្នល់ខាងជើងបាំងបាត់ដោយព្រៃអង្គរធំ។ តាមរយៈការស្រាវជ្រាវដែលធ្វើនៅក្នុងក្រុងអង្គរធំ[៧] គេប្រទះឃើញស្នាមដីលើកមួយខ្សែរត់ទទឹងថ្ងៃ ស្ថិតនៅលើខ្សែបន្ទាត់ជើង-ត្បូងនៃប្រាសាទភ្នំបាខែងនិងភិមានអាកាស។ ស្លាកស្នាមនេះ ប្រហែលជា "ថ្នល់ទទឹងខាងជើង" នៃក្រុងយសោធរនោះហើយ។

ក្នុងរវាងពាក់កណ្ដាលស.វ.ទី១០ ព្រះបាទរាជេន្ទ្រវរ្ម័នផ្ដើមកសាងព្រះរាជវាំង ព្រមទាំងភិមានអាកាសក្នុងទ្រង់ទ្រាយដំបូង។ តាមរយៈសំណង់ផ្សេងៗ ក្នុងរាជនេះ យើងយល់ថាបុរីរបស់ព្រះអង្គរៀបចំឡើងដោយគោរពទៅតាមលំនាំបុរីយសោធរដំបូង ដែលបានត្រួសត្រាយដោយព្រះបាទយសោវរ្ម័ន។ ការរៀបចំនេះតម្រូវតាមខ្សែបន្ទាត់ពីរ ៖ ខ្សែទទឹងថ្ងៃប្រៀបទៅភ្នំបាខែង និងខ្សែបណ្ដោយថ្ងៃប្រៀបទៅនឹងប្រាសាទមេបុណ្យ។ ប្រាសាទប្រែរូបដែលជាប្រាសាទសម្រាប់រាជ្យ ឈរលើខ្សែទទឹងថ្ងៃជាមួយនឹងមេបុណ្យ។ យើងនៅមើលឃើញសំណល់ដីលើកដោយផ្នែកខ្លះ ដែលចេញអំពីប្រាសាទប្រែរូបតាមទិសទាំងបួន (មើលរូបទី៤)។ នោះហើយជាថ្នល់ទទឹង និងបណ្ដោយថ្ងៃនៃប្រាសាទភ្នំរបស់ព្រះបាទរាជេន្ទ្រវរ្ម័ន។

[៦] Goloubew & Marchal 1933 និង Goloubew 1934 ហើយនិងIm 1998 : 15-16.
[៧] ក្រុមស្រាវជ្រាវនេះដឹកនាំដោយសាស្ត្រាចារ្យ Jacques Gaucher ក្នុងគម្រោង "De Yasodharapura à Angkor Thom"។




រូបទី៣ _ ភ្នំបាខែង (ប្រភព ៖ JICA ឆ្នាំ ១៩៩៥)




រូបទី៤_ ប្រែរូប និងមេបុណ្យ មើលពីលើអាកាស (ប្រភព ៖ Nara National Cultural Properties Research Institute)។

ព្រះបាទសូរ្យវរ្ម័នទី១ កែប្រែថែមថយយកទ្រង់ទ្រាយបញ្ចប់នៃភិមានអាកាស ព្រមទាំងរៀបចំបំពាក់រចនាសម្ព័ន្ធបន្ថែមក្នុងព្រះរាជវាំង ដូចជាសាងកំពែងពាត់ជុំវិញដែលយើងឃើញសព្វថ្ងៃជាដើម។ ព្រះអង្គផ្ដើមកសាងប្រាសាទបាភួននិងលើកបារាយទឹកថ្លានៅខាងលិចព្រះរាជវាំង។ បាភួនស្ថិតនៅលើខ្សែទទឹងថ្ងៃរវាងភិមានអាកាសនឹងភ្នំបាខែង។ ថ្នល់ធំៗក្នុងរាជធានីអង្គរនៃរាជ្យនេះ ប្រហែលជាពុំមានការកសាងថ្មីទេ។

នាដើមស.វ.ទី១២ ព្រះបាទសូរ្យវរ្ម័នទី២ស្ថាបនាអង្គរវត្ត ឬហៅអង្គរតូច។ ប្រាសាទនេះ ស្ថាបនាឡើងសម្រាប់រាជ្យ។ តាមរយៈស្លាកស្នាមនៅសល់ យើងឃើញមានស្នាមផ្លូវបណ្ដោយថ្ងៃដែលចេញពីអង្គរវត្ត តាមច្រកខាងលិចនិងខាងកើត។ រីឯព្រះរាជវាំង ទំនងគ្មានការប្រែប្រួលទេ ពោលគឺស្ថិតនៅត្រង់កន្លែងដដែល។

បន្ទាប់ពីដេញចាមចេញពីព្រះនគរមក ព្រះបាទជ័យវរ្ម័នទី៧ រៀបចំរាជធានីក្នុងទ្រង់ទ្រាយថ្មីស្រឡាង។ រាជធានីថ្មីនេះនៅតែមានឈ្មោះដដែលថាយសោធរ ដែលហ៊ុំពាត់ដោយកំពែងថ្មបាយក្រៀមរាងបួនជ្រុងស្មើ ហើយមានបរិវេណប្រវែង១២ គ.ម.។ សព្វថ្ងៃយើងស្គាល់រាជធានីនេះថា អង្គរធំ ឬមហានគរ។ រាជធានីថ្មីនេះ មានកសិណទឹកពីរជាន់ពាត់ជុំវិញ ៖ កសិណខាងក្រៅ មានទំហំ១០០ម៉ែត្រ និងជម្រៅពី៥និង៦ម៉ែត្រ។ កសិណខាងក្នុងស្ថិតនៅចម្ងាយប្រមាណ៨០ម៉ែត្រពីជើងកំពែង មានទំហំប្រមាណ៤០ ម៉ែត្រ[៨] ។ ថ្នល់ទទឹងនិងបណ្ដោយថ្ងៃចេញពីបាយ័ន្តដែលជាមណ្ឌលទៅតាមក្លោងទ្វារក្រុងទាំងបួន។ ផ្លូវមួយៗមានអមដោយប្រឡាយថ្មបាយក្រៀមពីចំហៀង។ ថ្នល់ទទឹងនិងថ្នល់បណ្ដោយនេះ ចែកក្រុងអង្គរធំជាបួនសង្កាត់ (មិនសំដៅលើតំបន់រដ្ឋបាលទេ) ពោលគឺស្រដៀងនឹងក្រឡាចត្រង្គធំៗបួន។ រីឯថ្នល់បណ្ដោយទីប្រាំ ជាថ្នល់ចាស់ដែលចេញពីព្រះរាជវាំងតាមក្លោងទ្វារខាងកើត ឆ្ពោះទៅក្លោងទ្វារជ័យនៃរាជធានី។ ថ្នល់ទទឹងនិងបណ្ដោយទាំងនេះមានប្រឡាយទឹកអមបណ្ដោយចំហៀងទាំងពីរ[៩] ។

ក្រៅពីថ្នល់ទទឹងនិងបណ្ដោយទាំងនេះ រាជធានីអង្គរមានបំពាក់ផ្លូវតូចធំផ្សេងៗទៀត សម្រាប់ប្រើប្រាស់ជាសាធារណៈ។ ឧទាហរណ៍ នៅក្នុងក្រុងអង្គរធំ តាមលទ្ធផលនៃការស្រាវជ្រាវនៅអង្គរធំរបស់លោកសាស្ត្រាចារ្យ Jacques Gaucher បានប្រទះឃើញស្លាកស្នាមខ្សែបន្ទាត់ជាច្រើនរត់ជួរគ្នានៅខាងក្នុងជ្រុងទាំងបួននៃក្រុង។ ស្លាកស្នាមទាំងនោះជាផ្លូវទទឹងនិងបណ្ដោយថ្ងៃ ស្របនឹងថ្នល់សំខាន់របស់ក្រុងទាំងប្រាំ។ តាមលំនាំនេះ ផ្លូវអម្បាលមាណនោះ បែងចែកផ្ទៃដីនៃរាជធានីអង្គរធំជាក្រឡាចត្រង្គតូចៗបន្តទៀត។ លោកសាស្ត្រាចារ្យបង្ហាញបន្ថែមថា ក្នុងផ្ទៃក្រឡាចត្រង្គតូចៗនេះ មានទួលដីលើកបង្ហាប់ជាលំនាំគ្រឹះនៃលំនៅដ្ឋានជាច្រើន ហើយនិងមានស្រះទឹកតូច_ធំ តិចឬច្រើនដែលនៅជាប់នឹងថ្នល់ផង[១០]។ ទិន្នន័យទាំងនេះ ស្របគ្នានឹងការបរិយាយរបស់អ្នកការទូតចិន លោក ជីវ តាក្វាន់ ដែលបានមកស្នាក់ក្នុងក្រុងអង្គរធំជាច្រើនខែក្នុងឆ្នាំ១២៩៦។

របៀបរៀបចំដែនដីដូច្នេះ នាំឲ្យយើងចាប់អារម្មណ៍មើលមកបណ្ដាភូមិនៅវាលរាបខាងលិចអង្គរសព្វថ្ងៃ។ តួយ៉ាងមានភូមិល្វា, រវៀល, ម្កាក់, ត្រីញ័រ, នគរភាសជាដើម ហើយទៅខាងលិចនេះបន្តិចទៀត ដែលស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ មានភូមិទានកាំជាដើម[១១]។ ភូមិទាំងនោះមានថ្នល់សំខាន់ពីររត់តាមខ្សែទទឹងនិងបណ្ដោយថ្ងៃរួចប្រសព្វគ្នានៅត្រង់ចំណុចកណ្ដាលភូមិ។ ត្រង់នោះយើងតែងឃើញមានព្រះភូមិ ឬផ្ចិតភូមិ។ ថ្នល់តូចៗដទៃទៀតរត់ស្របតាមផ្លូវសំខាន់ទាំងពីរខាងលើ បង្កើតផ្ទៃដីភូមិជាក្រឡាចក្រត្រង្គតូចៗ។ ផ្ទះសម្បែងអ្នកស្រុកសង់នៅក្នុងក្រឡាចក្រ ត្រង្គតូចៗទាំងនោះ ដោយបែរមុខមកផ្លូវហើយបែរខ្នងរកគ្នា។ សព្វថ្ងៃ ដោយស្រុករីកចម្រើន គេនិយមប្រើអណ្ដូងទឹក។ តែស្រះទឹកនៅខាងមុខផ្ទះហើយជាប់នឹងថ្នល់នៅសល់មួយៗដែរ។

ក.២. ផ្លូវចេញពីរាជធានី

ដោយសារការស្រាវជ្រាវនៅស្ដួចស្ដើងនៅឡើយ នាំឲ្យយើងខ្វះទិន្នន័យសំខាន់ទាក់ទងនឹងកាលបរិច្ឆេទពិតប្រាកដនៃការស្ថាបនាផ្លូវទាំងអម្បាលនោះ។ រីឯការស្រាវជ្រាវរបស់ខ្ញុំនេះវិញ ធ្វើឡើងតាមរយៈទិន្នន័យផ្សេងៗដូចបានរៀបរាប់មកខាងលើ។ ដូច្នេះក្នុងការបរិយាយនៅខាងក្រោមៗ ខ្ញុំនឹងលើកយកមកនិយាយអំពីបណ្ដាញផ្លូវដែលសល់ស្លាកស្នាមខ្លះ និងរលុបបាត់ខ្លះ។

---

[៨] Chronique, *BEFEO* XXXVII, 2 : 651.

[៩] Goloubew 1937; 1938 និង Im 1998 : 34-36.

[១០] Gaucher 2004.

[១១] ភូមិទាំងនោះជាស្ថានីយ៍បុរេប្រវត្តិ។ បើយោងភស្តុតាងជាឧបករណ៍ថ្ម (អ្នកស្រុកហៅ "គ្រាប់រន្ទះ") ដែលប្រទះឃើញនៅក្នុងភូមិផ្ទាល់ យើងយល់ថាស្ថានីយ៍នោះប្រហែលជាយុគថ្ម។ ទាក់ទងនិងស្ថានីយ៍បុរេប្រវត្តិ។ សូមមើលបន្ថែមតាម Malleret 1959.

បើពិនិត្យលើផែនទីភូមិសាស្ត្រនៃតំបន់អង្គរ (មើលរូបទី១) យើងមើលឃើញខ្សែគំនូសត្រង់ៗ រត់ខ្វាត់ខ្វែងតភ្ជាប់ពីចំណុចមួយទៅចំណុចមួយទៀត។ ខ្សែគំនូសទាំងនេះ ជាបណ្តាញផ្លូវបុរាណដែលចរាចរក្នុងតំបន់អង្គរនិងទៅកាន់មណ្ឌលក្រៅរាជធានី។ ផ្លូវទាំងនេះអាចសម្គាល់បានជា៖

- ប្រភេទថ្នល់ធំៗ ឆ្ពោះទៅកាន់មណ្ឌលក្រៅអង្គរ តភ្ជាប់ពីថ្នល់ទទឹងនិងថ្នល់បណ្តោយនៃរាជធានី ពោលគឺចេញពីប្រាសាទភ្នំដែលជាមណ្ឌល។ ដើម្បីងាយហៅឈ្មោះទៅក្រោយៗទៀត ខ្ញុំសូមកំណត់យកទិសណាមួយ ដែលថ្នល់នោះឆ្ពោះទៅ មកប្រើជាឈ្មោះសម្គាល់ថ្នល់ធំៗទាំងនោះ ហើយជាពិសេស គឺដើម្បីរក្សាឈ្មោះក្នុងកំណត់បញ្ជីបេតិកភណ្ឌរបស់លោកLunet de Lajonquière ព្រមទាំងឧទ្ទិសដល់លោកផង ដែលបានចំណាយពេលរាប់ឆ្នាំក្នុងការងារចុះបញ្ជីប្រាសាទខ្មែរកាលពីជាងមួយរយឆ្នាំមុន[១២] ។ តាមរបៀបនេះ អាចមានថ្នល់ធំៗចំនួនប្រាំមួយខ្សែចេញពីរាជធានីអង្គរ (សូមមើលនៅចំណុចបណ្តាញផ្លូវខាងក្រោម)។ ឆ្ពោះទៅមណ្ឌលខាងកើតមានផ្លូវពីរខ្សែ ពោលគឺ “ផ្លូវខាងកើត” និង “ផ្លូវអាគ្នេយ៍”។ មណ្ឌលនៅខាងលិចក៏មានផ្លូវពីរខ្សែដែរគឺ “ផ្លូវខាងលិច” និង “ផ្លូវខាងពាយ័ព្យ”។ មណ្ឌលខាងជើងមានផ្លូវមួយខ្សែគឺ “ផ្លូវខាងជើង” ព្រមទាំងមួយខ្សែទៀតចុះទៅទន្លេសាប នៅខាងត្បូង។ បន្ថែមលើនេះ ជាផ្លូវដែលបែកចេញពីផ្លូវធំៗខាងលើនេះ ភ្ជាប់ទៅកាន់មណ្ឌលដទៃទៀត។ ឧទាហរណ៍ ផ្លូវទៅកាន់មណ្ឌលកោះកេរ្តិ៍ បែកចេញពីប្រាសាទមាលា[១៣]។ ផ្លូវទៅបន្ទាយឆ្មារ បែកចេញពីផ្លូវខាងលិចម្តុំទីរួមស្រុកភ្នំស្រុកសព្វថ្ងៃ (សូមមើលលំអិតនៅបណ្តាញផ្លូវ)។

-ប្រភេទថ្នល់ដែលជាទំនប់នៃប្រព័ន្ធធារាសាស្ត្រមានថ្នល់បារាយនិងទំនប់នៃបណ្តារប្រព័ន្ធប្រឡាយទាំងឡាយ។ ឧទាហរណ៍ ក្រុងយសោធរភ្ជាប់និងហរិហរាល័យដោយផ្លូវលើកមួយខ្សែចេញពីខាងកើតភ្នំបាខែងភ្ជាប់ទៅនឹងជ្រុងពាយ័ព្យនៃឥន្ទ្រតដាក(បារាយលលៃសព្វថ្ងៃ)។ ទំនប់នៃបារាយនេះ ភ្ជាប់បន្តពីថ្នល់ចូលមកហរិហរាល័យ។ ជាក់ស្តែងទំនប់បារាយខាងត្បូង ដែលយើងបន្តប្រើរហូតទល់សព្វថ្ងៃ។ បន្ទាប់មក ទំនប់ខាងត្បូងនេះតបន្តភ្ជាប់ទៅថ្នល់មួយទៀត ចេញពីជ្រុងអាគ្នេយ៍នៃបារាយនេះដដែលឆ្ពោះទៅកើត ដែលយើងស្គាល់ថាជាផ្លូវជាតិលេខ៦បច្ចុប្បន្ន។ រីឯទំនប់នៃបារាយដទៃទៀតក៏មានការប្រើប្រាស់ដូចគ្នានេះដែរ (សូមមើលការបរិយាយបន្ថែមនៅខាងក្រោម)។

ក.៣. ថ្នល់ផ្សេងៗ

រាជធានីអង្គរធំមានថ្នល់ប្រភេទម្យ៉ាងដែលពាត់ជុំវិញក្រុង។ ថ្នល់ប្រភេទនេះ គេឃើញមានពីរខ្សែ។ ខ្សែទីមួយពាត់ពីក្រៅកសិណដែលស្ថិតនៅជាប់មាត់កសិណផ្នែកខាងក្រៅ ហើយភ្ជាប់នឹងក្លោងទ្វារចូលក្រុងទាំងប្រាំ។ ថ្នល់នេះមានទំហំប្រមាណជិត១០ម៉ែត្រ។ យើងនៅមើលស្គាល់ស្លាកស្នាមនៃថ្នល់នេះ ដោយផ្នែកខ្លះៗ។ ជាពិសេសនៅកំណត់ថ្នល់ផ្នែកខាងជើងនៃអង្គរធំ។ អ្នកភូមិនគរក្រៅខ្លះ សង់ផ្ទះរស់នៅលើកំណាត់ថ្នល់ភាគខាងលិច (មើលរូបទី៥)។ ខ្សែទីពីរនៅលើកំពែងក្រុងតែម្តង។ ថ្នល់នេះភ្ជាប់មកក្លោងទ្វារក្រុងពីខាងក្នុងតាមជម្រាលដែលក្បែរនោះ។ ថ្នល់នេះមានទំហំប្រហាក់ប្រហែល និងថ្នល់ពាត់ពីខាងក្រៅដែរ(មើលរូបទី៦)។

លើសពីនេះ មានផ្លូវតូចៗកកើតដោយមនុស្សដើរនិងរទេះបរលើរាល់ថ្ងៃ។ ជាប្រភេទផ្លូវលំដែលមានស្នាមរត់តាមបណ្តោយស្ទឹងថ្លុងកាត់វាលស្រែនិងព្រៃ ភ្ជាប់ពីសហគមន៍មួយទៅសហគមន៍មួយទៀតជាដើម។ ផ្លូវប្រភេទនេះ ជាទូទៅមិនមានរាងត្រង់ៗទេ។ វាបត់បែនដោយកន្លែងទៅតាមស្ថានភាពភូមិសាស្ត្រ ហើយច្រើនជាផ្លូវកាត់។ អាស្រ័យដោយភូមិសាស្ត្រអំណោយផល អ្នកស្រុកប្រើប្រាស់ផ្លូវប្រភេទនេះយ៉ាងស្រួលសម្រាប់ធ្វើទំនាក់ទំនងគ្នា ពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងមណ្ឌល ឬចេញក្រៅមណ្ឌល ពីភូមិដ្ឋានទៅកាន់ប្រាសាទជាដើម។ នារដូវទឹកជន់ ផ្លូវប្រភេទនេះងាយនឹងជន់លិចណាស់។ យើងសង្កេតឃើញនាសម័យបច្ចុប្បន្ន ពេលទឹកជន់លើផ្លូវដូច្នេះម្តងៗ អ្នកស្រុកប្រើទូកចរាចរតាមបណ្តោយផ្លូវ ឬជួនកាលអ្នកស្រុកបររទេះគោក្របីពីលើតែម្តង។

---

[១២]Lunet de Lajonquière 1902 : LIV-LX.

[១៣] អ្នកស្រាវជ្រាវហៅ “បេងមាលា” ដោយសារប្រាសាទស្ថិតនៅភូមិបេង។ ក្រោយមកក៏ហៅ “បឹងមាលា”។ ប៉ុន្តែអ្នកស្រុកហៅត្រឹមថា “មាលា”។ ពីមុននៅក្នុងបរិវេណប្រាសាទមានវត្តបុរាណមួយឈ្មោះថា “វត្តព្រះកេតុមាលា” ដែលគេទើបនឹងប្តូរទីតាំងឱ្យទៅនៅខាងក្រៅវិញ។




រូបទី៥ - ហេដ្ឋារចនាសម្ព័ន្ធនៅខាងជើងអង្គរធំ (កែសម្រួលពីផែនទី JICA ឆ្នាំ ១៩៩៧)

## ១. បណ្ដាញផ្លូវ

ខ្ញុំនឹងបរិយាយត្រង់ចំណុចនេះ អំពីតែផ្លូវទាំងឡាយដែលចេញពីរាជធានីទៅកាន់មណ្ឌលផ្សេងៗនៅក្នុងព្រះរាជាណាចក្រ ព្រមទាំងឆ្ពោះទៅកាន់អាណាចក្រជិតខាង[១៤]។ ដូចពោលខាងដើម ថ្នល់ធំទាំងនោះមើលទៅឃើញថា មានប្រភពចេញពីប្រាសាទភ្នំដែលជាមណ្ឌលនៃរាជធានី។ នៅលើវាលរាប ខ្មែរលើកថ្នល់ឲ្យខ្ពស់ជាងទំនាបជុំវិញប្រហែលពីរបីម៉ែត្រ ដែលមានផ្ទៃលើតូចជាងបាតក្រោម ដើម្បីធានាការធ្វើចរាចរបាននៅ គ្រប់រដូវ។ តាមបណ្ដោយថ្នល់ប្រឡាយអមពីចំហៀងទាំងពីរ។ រីឯនៅលើវាលខ្ពស់វិញតួថ្នល់នៅរាបស្មើផ្ទៃដីជុំវិញ ឬទាបជាងទៅតាមការប្រើប្រាស់។ ដោយពុំទាន់មានតឹកតាងគ្រប់គ្រាន់ ដើម្បីកំណត់កាលបរិច្ឆេទនៃការលើកថ្នល់ទាំងនោះ ខ្ញុំផ្ដើម



រូបទី៦ - ថ្នល់លើកំពែងក្រុងអង្គរធំ

[១៤]រីឯបណ្ដាញថ្នល់នៅតាមរាជធានី សូមមើលបន្ថែមនៅ Im 1998 និង Gaucher 2004។

វៀបរាប់ថ្នល់មួយៗ ជាលំដាប់លំដោយនៅខាងក្រោម ដោយផ្អែកតាមបរិបទនៃប្រវត្តិសាស្ត្រ។

១.១. ផ្លូវអាគ្នេយ៍

ព្រះបាទយសោវរ្ម័ន ស្ថាបនារាជធានីនៅចុងស.វ.ទី៩ ដែលមានឈ្មោះតាមលំនាំព្រះនាមរបស់ព្រះអង្គថា "យសោធរ"។ ថ្នល់ទទឹងនិងថ្នល់បណ្តោយថ្ងៃ ចេញពីភ្នំបាខែងតាមទិសទាំងបួនជាផ្លូវធំនៃក្រុងយសោធរ។ ថ្នល់បណ្តោយខាងកើតភ្ជាប់ពីជណ្តើរឡើងភ្នំទៅកើតត្រង់ ដោយកាត់ស្ទឹងសៀមរាប។ នៅច្រាំងខាងលិច យើងឃើញនៅសល់កម្រាលថ្មបាយក្រៀមរាងជាខឿនមួយភ្ជាប់នឹងមាត់ទឹក។ ប៉ុន្តែយើងពុំប្រទះឃើញសំណល់ដូចគ្នានៅត្រើយខាងកើតទេ ក្រៅអំពីស្នាមដីលើកដែលជាថ្នល់បន្តទៅកើតទៀត។ ស្នាមថ្នល់នេះស្ទើរលុបទាំងស្រុងក្នុងចម្ងាយប្រមាណ៦០០ម៉ែត្រពីមាត់ស្ទឹងត្រើយខាងកើត។ នៅចម្ងាយនេះ ថ្នល់បណ្តោយព្រែកជាពីរ ដែលទីមួយបន្តទៅកើតត្រង់ដោយរត់ស្របនឹងទំនប់យសោធរតដាក[១៥]។ ថ្នល់នេះដូចពោលខាងដើម ខ្ញុំហៅថា "ផ្លូវខាងកើត"[១៦]។ ទីពីរចុះមកអាគ្នេយ៍ទៅភ្ជាប់និងហរិហរាល័យត្រង់ជ្រុងកែងពាយ័ព្យនៃឥន្ទ្រតដាក (បារាយលលៃ) ដែលរត់លើចម្ងាយប្រហែល១៥គ.ម. ហើយភ្ជាប់មកក្នុងក្រុងតាមថ្នល់ទំនប់ខាងត្បូងបារាយ។

ដូចបានពោលខាងលើ ថ្នល់ធំៗនៃហរិហរាល័យ គឺថ្នល់ទទឹងនិងបណ្តោយថ្ងៃនៃប្រាសាទបាគង។ ថ្នល់ទទឹងខាងជើងរត់មកភ្ជាប់និងថ្នល់បារាយខាងត្បូង ដោយកាត់មុខខាងកើតប្រាសាទព្រះគោ ហើយរត់ជួរគ្នានិងខ្សែទទឹងថ្ងៃនៃបាគងនិងប្រាសាទលលៃ។ ថ្នល់ទទឹង ខាងត្បូងរត់ចុះមកក្រោមសំដៅទន្លេសាប ដោយកាត់មុខខាងកើតនៃប្រាសាទព្រៃមន្ទីរ។ ថ្នល់នេះសល់ស្នាមនៅផ្នែកខាងត្បូងប្រាសាទខ្លះប៉ុណ្ណោះ[១៧]។ ថ្នល់បណ្តោយខាងលិចនៅសល់ស្នាមវែងជាងគេ។ រីឯថ្នល់បណ្តោយខាងកើតនៅសល់ស្នាមត្រឹមស្ទឹងរលួស ហើយរលុបបាត់ដានស្ទើរទាំងស្រុងចាប់ពីត្រើយខាងកើត(មើលរូបទី៧)។

ចំពោះថ្នល់ដែលចេញបន្តពីហរិហរាល័យ តាមជ្រុងអាគ្នេយ៍នៃឥន្ទ្រតដាកឆ្ពោះទៅកើត ខ្ញុំហៅថា "អាគ្នេយ៍"។ សព្វថ្ងៃ ផ្លូវនេះក្លាយជាផ្លូវជាតិលេខ៦ ដែលគ្រប់គ្នាដឹងថាមានស្ពានបុរាណវែងមួយយ៉ាងល្អ នៅទីប្រជុំជនកំពង់ក្តី ចម្ងាយប្រមាណ៥០គ.ម. ពីទីរួមខេត្តសៀមរាប (សូមមើលបន្តនៅខាងក្រោម)។ ថ្នល់បណ្តោយប្រសប់នឹងផ្លូវនេះ នៅម្តុំទីប្រជុំជននៃភូមិអង្ក្រង។ ផ្លូវអាគ្នេយ៍រត់លើបន្ទាត់មួយស្របនឹងច្រាំងទន្លេសាប ឆ្ពោះទៅកើតដែលទំនងជាទៅភ្ជាប់នឹងក្រុងបុរាណសម័យមុនអង្គរឈ្មោះថា "ឦសានបុរ" ដែលយើងស្គាល់សព្វថ្ងៃថា "សម្បូណ៌"[១៨] (ខេត្តកំពង់ធំ) ព្រមទាំងឆ្ពោះទៅកាន់មណ្ឌលរដ្ឋបាលដទៃទៀត ដែលស្ថិតនៅដែនដីខាងកើតក្បែរៗ ទន្លេធំ។

នៅលើដងផ្លូវអាគ្នេយ៍នេះ យើងប្រទះឃើញមានស្ពានថ្មបុរាណតូចធំប្រមាណ២២ចាប់ជ្រុងអាគ្នេយ៍នៃឥន្ទ្រតដាក(បារាយលលៃ)មកទល់និងប្រជុំជនកំពង់ក្តី (សូមមើលបន្ថែមខាងក្រោម)។ ក្នុងចំណោមនោះ ស្ពានដែលនៅទីប្រជុំជនកំពង់ក្តីមានប្រវែងវែងជាងគេ ដែលបានជួលជុលស្តារហើយ ក្នុងកំឡុងឆ្នាំ១៩៦៥_៦៧។ ក្រៅពីនេះ មានស្រះទឹកជាច្រើនទៀត ដែលនៅតាមដងផ្លូវ ហើយបន្តប្រើប្រាស់ដល់សព្វថ្ងៃ។ ប៉ុន្តែយើងពុំប្រទះឃើញមានសាលាសំណាក់ណាមួយទេ។ រីឯកំណាត់ផ្លូវចាប់ពីស្ពាននៅកំពង់ក្តីទៅកើត យើងក៏ពុំប្រទះឃើញសំណល់ស្ពានថ្ម និងសាលាសំណាក់តទៅទៀតដែរ។ ដូច្នេះហើយ យើងនៅមានមន្ទិលនៅឡើយថា តើថ្នល់បុរាណនោះរត់តពីកំពង់ក្តីរហូតដល់ប្រាសាទអណ្តែតតាមស្នាមណា? តាមស្នាមផ្លូវជាតិលេខ៦បច្ចុប្បន្ន ដែលត្រូវគេកែសម្រួលផ្នែកខ្លះ ដើម្បីតម្រូវតាមលក្ខណ:បច្ចេកទេសដោយតម្រូវឲ្យផ្លូវមានរាងត្រង់? ឬមួយក៏មានស្នាមផ្លូវណាផ្សេងទៀត?

យើងតែងឃើញមានសំណល់ប្រាសាទបុរាណច្រើនតាំងនៅខាងត្បូងនិងខាងជើងផ្លូវជាតិលេខ៦សព្វថ្ងៃ ចាប់ពីអង្គររហូតដល់កំពង់ចាមពោលគឺដែនដីនៃទន្លេធំ។ ភាគច្រើននៃប្រាសាទទាំងនោះមានសាងឡើងនៅសម័យមុនអង្គរ ហើយមានស្លាកស្នាមជួលជុលស្តារបន្ថែមនៅសម័យអង្គរ

[១៥] ដោយយោងតាមភូមិសាស្ត្រអ្នកស្រាវជ្រាវបារាំងហៅបារាយនេះថា "Baray Oriental" (បារាយខាងកើត)។បន្ទាប់មក ហៅជាអង្លេសថា "Eastern Baray"។ប៉ុន្តែអ្នកស្រុកហៅ "ថ្នល់បារាយ" ដូច្នេះ។ ពាក្យនេះត្រូវមកយកប្រើក្នុងការបោះពុម្ពផ្សាយដោយអ្នកស្រាវជ្រាវខ្លះរហូតដល់ទសវត្ស១៩៦០។

[១៦] អ្នកស្រុកសៀមរាប_អង្គរហៅផ្លូវនេះថា "ផ្លូវបេង"។ ពីព្រោះផ្លូវនេះរត់ឆ្ពោះទៅកាន់ប្រាសាទមាលាដែលតាមដំណាលចាស់ៗថា ពីដើមមានដើមបេងដុះច្រើនណាស់។ ជាពិសេសភូមិដែលនៅម្តុំប្រាសាទនោះ ក៏មានឈ្មោះថា "ភូមិបេង" ដែរ។

[១៧] Goloubew 1937 & Stern 1937.

[១៨] យើងហៅសព្វថ្ងៃថា "សម្បូណ៌ព្រៃគុក"




រូបទី៧ - ហរិហរាល័យ (កែសម្រួលពីផែនទី JICA ឆ្នាំ១៩៩៧)

ព្រមទាំងមានប្រាសាទសាងនៅសម័យអង្គរតាមរាជ្យផ្សេងៗផង។ នេះជាភស្តុតាងថា ប្រាសាទដែលមានមកហើយនោះ អ្នកជាន់ក្រោយនៅបន្តគោរពបូជានិងថែទាំជានិច្ច។ ម្យ៉ាងទៀត បើមើលលើទីតាំងនៃប្រាសាទទាំងនោះវិញ យើងឃើញថានៅរាយគ្នាជាក្រុមបន្តគ្នាតាមលំនាំរត់ដូរលើខ្សែតែមួយ ដែលស្របនិងផ្លូវជាតិលេខ៦។ នៅម្តុំស្ទោង យើងប្រទះឃើញសិលាចារិកនៅលើមេទ្វារនៃប្រាសាទ "ទ្វារក្តី" ដែលបរិយាយពីមណ្ឌលនៃដែនដីមួយឈ្មោះថា "ទ្វារវតី"[១៩]។

នៅខាងលិចទីរួមខេត្តកំពង់ធំ មានស្លាកស្នាមនៃប្រាសាទរាយគ្នាតពីប្រាសាទអណ្តែតមក។ ក្នុងចំណោមនោះ មានវត្តស្ពែងដាដើម ដែលនៅមានសំណល់ផ្តែទ្វារនិងសសរពេជ្រ ស្ថាបទានៅសម័យសម្បូណ៌ព្រៃគុកនិងសម័យអង្គរបន្តគ្នា ព្រមទាំងចម្លាក់ទាសម័យក្រោយអង្គរផង។ រីឯនៅខាងកើតទីរួមខេត្តវិញ ក្នុងភូមិសាស្ត្រស្រុកស្រយ៉ូវ ពោលគឺសហគមន៍ចំណុះវត្តស្រយ៉ូវតែម្តង មានសំណល់ប្រាសាទជាច្រើនម្តុំជាមណ្ឌលមួយ។ ជាអាទិ៍មានទួលវិហារនៅខាងលិចវត្ត ខាងត្បូងមានសំណល់ប្រាសាទបី-បួន ដែលសំខាន់ជាងគេ គឺទីតាំងនៃមន្ទីរពេទ្យមួយ ឈ្មោះថា "គុករកា"[២០]។ ជាប់របងវត្តខាងត្បូងមានសំណល់រក្សាទឹកធំមួយ ដែលមានបណ្តោយប្រមាណ១.០០០ ម៉ែត្រនិងទទឹងប្រហែល៣០០ម៉ែត្រ។ អ្នកស្រុកហៅសំណង់នោះថា "បឹងវាល់ពល" (មើលរូបទី៨និង៩)។ ឆ្លោះទៅកើតបន្តិចទៀត មានបូជនីយ៍ដ្ឋានភ្នំសន្ទុក ដែលទំនងជាមណ្ឌលនៃរដ្ឋបាលដែនដីបុរាណមួយ មានចារ

[១៩] Cœdès, *I.C.* VI : 132-139.
[២០] Cœdès 1940 : 344-347.



រូបទី៨ _ ហោបន់ស្រន់នៃមន្ទីរពេទ្យ, គុករកា (កំពង់ធំ)



រូបទី៩ _ បឹងវាល់ពល (ស្រយ៉ូវ, កំពង់ធំ)

ក្នុងសិលាចារិកពីរនៅស.វ.ទី១០ និងម្តងទៀតនៅស.វ.ទី១៥[២១]។ បន្តទៅខាងកើតក្នុងដែនដីស្រុកជើងព្រៃ យើងឃើញមានប្រាសាទជាងម្ភៃសាងឡើងនៅជុំគ្នា ដែលមានរចនាបទផ្សេងៗគ្នាផង[២២]។

ម្យ៉ាងទៀត តាមសំណេរនៃដំណើរគោចរក្នុងការងារចុះបញ្ជីប្រាសាទខ្មែររបស់លោក Lunet de Lajonquière កាលពីដើមស.វ.ទី២០ នៅក្នុងទឹកដីស្រុកស្ទោងដែលខ្ញុំសូមលើកមកដូច្នេះ "...អ្នកស្រុកបានមកតាំងទីរស់នៅជុំគ្នានៅតំបន់កណ្តាល[២៣] តាមបណ្តោយច្រាំងទន្លេសាប ហើយនៅលើបណ្តោយថ្នល់បុរាណខាងត្បូង[២៤] ដែលភ្ជាប់មកពីអង្គរឆ្ពោះទៅសហគមន៍នៅម្តុំទន្លេមេគង្គ..."[២៥]។ យ៉ាងដូច្នេះ យើងអាចយល់ថា កំណាត់ផ្លូវជាតិលេខ៦ពីកំពង់ក្តីមកទឹកដីកំពង់ចាម ប្រហែលជាស្ថាបនាពីលើថ្នល់បុរាណដែលបន្តមកពីហរិហរាល័យនោះហើយ។

ប៉ុន្តែផ្លូវនេះមិនមែនភ្ជាប់ត្រង់ទៅវៀសានបុរតែម្តងទេ គឺមានរបត់មួយនៅម្តុំខាងត្បូងប្រាសាទអណ្តែត ដែលស្ថិតខាងលិចទីរួមខេត្តកំពង់ធំប្រមាណជាងម្ភៃគីឡូម៉ែត្រ។ របត់នោះគឺជាថ្នល់ដីលើកមួយខ្សែភ្ជាប់ពីប្រាសាទអណ្តែតឆ្ពោះទៅវៀសានតម្រង់ទៅសម្បូណ៌ត្រង់ជ្រុងនិរតីនៅម្តុំប្រាសាទខ្នាយទោល ដោយកាត់តាមវត្តសានគរ, វត្តមហ, បឹងដំណាក់[២៦]។ សព្វថ្ងៃអ្នកស្រុកនៅបន្តប្រើប្រាស់ថ្នល់នេះ ដោយផ្នែកខ្លះនៅឡើយ។

ព្រះបាទយសោវរ្ម័នស្ថាបនា "អាស្រម"[២៧] ប្រមាណ១០០តាំងនៅទីកន្លែងផ្សេងៗក្នុងព្រះរាជាណាចក្រ ដែលមានឈ្មោះតាមលំនាំព្រះនាមរបស់ព្រះអង្គ ហៅ "យសោធរាស្រម"។ អាស្រមនីមួយៗមាន "រាជកុដិ" ដែលបម្រុងសម្រាប់ព្រះរាជារៀបចំពិធីផ្សេងៗក្នុងវេលាព្រះអង្គយាងកាត់តាមមណ្ឌលនោះម្តងៗ[២៨]។ រហូតមកដល់សព្វថ្ងៃ អ្នកស្រាវជ្រាវបានប្រទះឃើញសិលាចារិកនៃអាស្រមនោះប្រហែលម្ភៃ ដែលមាននិយាយទាក់ទងនឹងទីតាំងនៃអាស្រម និងចារជាបទបញ្ជាចំពោះអ្នកដំណើរមកកាន់ទីនោះសម្រាប់អនុវត្ត[២៩]។ សិលាចារិកទាំងនោះប្រទះឃើញនៅចុងខាងត្បូងនៃស្រុកខ្មែរ (ពុំឃើញមាននៅក្នុងដីប្រទេសវៀតណាមបច្ចុប្បន្នទេ) នៅក្នុងតំបន់វត្តភូ ក្នុងស្រុកលាវ និងភ្នំរុង ស្រុកថៃឡង់ដ៏សព្វថ្ងៃ។ ខ្ញុំគិតថាពិតជាមានថ្នល់ផ្សេងៗ ដែលភ្ជាប់ពីរាជធានីឆ្ពោះទៅកាន់អាស្រមទាំងនោះ។

---

[២១] Pou 1992 : 477 និង Pou 1981 : 111-124.
[២២] Im 1998 : 23 និង Cœdès, *I.C.* V : 229-234; *I.C.*, III : 164-169.
[២៣] កន្លែងនេះ លោកចង់បញ្ជាក់ថា នៅខាងត្បូងមានតំបន់ក្រោម ដែលចុះទៅទន្លេសាប រីឯខាងជើងមានតំបន់លើរហូតដល់ភ្នំដងរែក។
[២៤] ពីព្រោះនៅតំបន់លើ មានថ្នល់បុរាណមួយខ្សែទៀតដែលចេញពីអង្គរសំដៅមកប្រាសាទបាកាណ (នៅសំណេរនោះ លោកហៅថាប្រាសាទព្រះខ័ននៅក្នុងខេត្តកំពង់ស្វាយ) ដែលស្ថិតនៅជើងស្រុកស្ទោងសព្វថ្ងៃ។
[២៥] Lunet de Lajonquière 1902 : 256.
[២៦] Ibid : 225; 259.
[២៧] "អាស្រម" ជំនាន់នោះ សំដៅកន្លែងសិក្សាសាសនានិងវិជ្ជាផ្សេងៗ។
[២៨] Cœdès 1932 : 84-112.
[២៩] Jacques & Dumont 1990 : 52-53.

នៅក្នុងរាជធានីយសោធរ យើងប្រទះឃើញមានអាស្រមចំនួនបួន។ ក្នុងចំណោមនោះ មានអាស្រមបីមានទីតាំងនៅខាងត្បូងថ្នល់បារាយ (យសោធរតដាក) ដែលស្ទើរតែរត់ជួរគ្នាពីលិចទៅកើតមាន ៖ ក្ដីសួរ[៣០] នៅខាងកើតប្រាសាទតាព្រហ្ម, ប្រាសាទកំណាប់នៅខាងកើតប្រាសាទប្រែរូប និងប្រាសាទតុបនៅខាងត្បូងជ្រុងអាគ្នេយ៍នៃថ្នល់បារាយ។ អាស្រមទីបួនស្ថិតនៅម្ដុំទេពប្រណមខាងជើងរាជវាំងអង្គរធំសព្វថ្ងៃ។ អាស្រមនេះស្ថិតនៅលើខ្សែទទឹងថ្ងៃ រវាងភ្នំបាខែងនិងភិមានអាកាស។ ដូច្នេះ ខ្ញុំយល់ថាថ្នល់បណ្ដោយថ្ងៃដែលចេញពីរាជវាំងកាត់តាមក្លោងទ្វារជ័យសព្វថ្ងៃទំនងជាលើកក្នុងរាជ្យព្រះបាទយសោវរ្ម័ន ដែលភ្ជាប់ពីរាជវាំងទៅអាស្រម, ថ្នល់បារាយហើយនិងភ្នំបូកផង។ ការសិក្សាពីលើយន្តហោះនៅលើតំបន់អង្គរនាទសវត្ស ១៩៣០ បានបង្ហាញឲ្យឃើញមានស្នាមផ្លូវពីរខ្សែដែលចេញពីថ្នល់បារាយ[៣១]។ ទីមួយចេញពីជ្រុងឦសានឆ្ពោះទៅកាន់ភ្នំបូក។ ផ្លូវនេះមានសំណល់ស្ពានថ្មបុរាណមួយ (ស្ពានទ) ដែលស្ថិតនៅក្បែរជ្រុងបារាយ ហើយគេនៅតែបន្តប្រើមកទល់សព្វថ្ងៃ។ ទីពីរ ជាថ្នល់ចេញពីជ្រុងអាគ្នេយ៍រត់ចុះត្បូងតាមទទឹងថ្ងៃ មកប្រសប់នឹងថ្នល់បណ្ដោយមកពីភ្នំបាខែង ត្រង់ជ្រុងពាយ័ព្យនៃបារាយលលៃ។ អ្នកស្រុកនៅប្រើថ្នល់នេះដោយផ្នែកខ្លះនៅឡើយ (មើលទី១៦)។

១.២. ផ្លូវខាងកើតឬ "ផ្លូវបេង"

ប្រមាណជាង៣ម្ភៃឆ្នាំក្រោយពីព្រះបាទយសោវរ្ម័នចូលទីវង្គត ដែនដីខ្មែរទំនងជាមានរាជធានីពីរផ្សេងគ្នា។ ទីមួយ រាជធានីយសោធរនៅដដែល ដែលមានព្រះរាជាបីព្រះអង្គគ្រងរាជ្យជាបន្តបន្ទាប់គឺព្រះបាទហសិវរ្ម័នទី១, ព្រះបាទឦសានវរ្ម័នទី១និងព្រះបាទហសិវរ្ម័នទី២។ ទីពីរមានបុរីថ្មីមួយទៀតស្ថាបនានៅទិសឦសាននៃក្រុងយសោធរ ក្នុងចម្ងាយកាត់ប្រមាណ៧០គ.ម. ស្ថិតនៅលើដែនដីមួយដែលតាមសិលាចារិកហៅថា "ចោកគគ្យរ" ដែលសព្វថ្ងៃហៅក្លាយមកថា "កោះកេរ្ដិ៍"។ បុរីថ្មីនេះ ស្ថាបនាឡើងដោយព្រះរាជាមួយអង្គដែលបច្ចុប្បន្នយើងស្គាល់ថា ព្រះបាទជ័យវរ្ម័នទី៤។ កោះកេរ្ដិ៍រៀបចំឡើងតាមលំនាំដូចនៅក្រុងយសោធរដែរ ដែលមានប្រាសាទធំរាងសាជី ប្រាំពីរថ្នាក់ជាមណ្ឌល, រហាលធំមួយនិងប្រាសាទតូចធំរាប់សិបទៀត។

ព្រះបាទរាជេន្ទ្រវរ្ម័នឡើងគ្រងបន្តពីព្រះបាទជ័យវរ្ម័នទី៤។ ព្រះអង្គបានយាងត្រលប់មកគ្រងរាជ្យនៅអង្គរវិញ ដោយបានស្ដារក្រុងយសោធរបន្ថែមផង[៣២]។ ព្រះបាទរាជេន្ទ្រវរ្ម័នស្ថាបនាប្រាសាទមេបុណ្យនៅកណ្ដាលយសោធរតដាកដើម្បីឧទ្ទិសដល់ព្រះបាទយសោវរ្ម័ន រួចទើបស្ថាបនាប្រាសាទប្រែរូបសម្រាប់រាជ្យ ។ ប្រាសាទទាំងពីរស្ថិតនៅខ្សែ ទទឹងថ្ងៃជាមួយគ្នា។ មេបុណ្យនេះក៏ស្ថិតនៅលើខ្សែបណ្ដោយថ្ងៃនឹងភិមានអាកាស[៣៣]។ យ៉ាងដូច្នេះ ខ្សែទទឹងនិងបណ្ដោយថ្ងៃនេះ ជានិមិត្តរូបយ៉ាងសំខាន់នៃភាពសក្ការៈនៃសំណង់ដើម ដែលព្រះបាទយសោវរ្ម័នបានសាងទុកមក ព្រមទាំងជាមូលដ្ឋាននៃការរៀបចំរាជធានីអង្គរ។ " ផ្លូវខាងកើត" ដែលបន្តពីថ្នល់បណ្ដោយខាងកើតនៃភ្នំបាខែងក៏រត់ស្របនឹងខ្សែបណ្ដោយនោះដែរ។

បុរាណដ្ឋានវត្តភូ ដែលស្ថិតនៅក្នុងខេត្តចម្ប៉ាសាក់នៃស្រុកលាវបច្ចុប្បន្ននិងនៅឦសាននៃអង្គរជាក្រុងបុរាណផង ហើយជាពិសេសជាបូជនីយដ្ឋានដ៏សំខាន់នៃសម័យនោះផង។ ព្រះរាជាសម័យអង្គរតែងយាងទៅសំពះ ហើយតែងនាំយកមកអង្គរវិញនូវព្រះបដិមាដែលមានព្រះនាមយកលំនាំតាមព្រះនាមបដិមានៅវត្តភូជានិច្ច។ ឧទាហរណ៍ ព្រះបាទរាជេន្ទ្រវរ្ម័នបានយាងទៅសំពះនៅបូជនីយដ្ឋានវត្តភូ ដែលមានឈ្មោះដើមថា "លិង្គបពិត" នៅក្នុងដែនដី "លិង្គបុរ" ព្រមទាំងយកព្រះបដិមាដែលគោរពបូជានៅទីនោះ មកតម្កល់នៅក្នុងប្រាសាទប្រែរូប។ ព្រះបដិមានោះ មានព្រះរូបជាព្រះលិង្គ ដែលមានព្រះនាមថា "រាជេន្ទ្រភទ្រេស្វរ"[៣៤]។

បូជនីយដ្ឋានវត្តភូនិងបុរីកោះកេរ្ដិ៍ តាំងនៅលើទិសឦសានបើប្រៀបនឹងអង្គរ។ សព្វថ្ងៃ យើងនៅមើលឃើញតាមរយៈរូបថតពីលើអាកាសនៃស្នាមផ្លូវមួយខ្សែស្ទើរតែទាំងស្រុង ដែលភ្ជាប់ពីអង្គរទៅកោះកេរ្ដិ៍និងវត្តភូ។ ផ្លូវបេងនេះ រត់នៅចន្លោះប្រាសាទក្រវ៉ាន់នៅខាងត្បូង និងបាទជុំ នៅខាងជើងតម្រង់ទៅកើត ដោយកាត់តាមមុខខាងជើងនៃវត្តត្រាច (ដែលមានប្រាសាទចៅស្រីវិបុលស្ថាបនាក្រោយមក), មុខខាងត្បូងនៃបន្ទាយអំពិល រួចទៅប្រសប់និងថ្នល់ដែលឡើងមកពីទីប្រជុំជនដីដែកបច្ចុប្បន្នត្រង់ភូមិត្រពាំងប្រី (មើលរូបទី១០)។ ចេញពីភូមិត្រពាំងប្រី ថ្នល់ងាកទៅឦសាន សំដៅភូមិបេង

---

[៣០] បរិវេណនោះ អ្នកស្រុកហៅថា "គោកខ្មោច"។ អ្នកស្រាវជ្រាវនិយមហៅថា "Kuṭīśvara"។
[៣១] Goloubew 1930 : 469.
[៣២] Cœdès 1908 : 239
[៣៣] សូមមើលបន្ថែមពីប្រវត្តិទាក់ទងនឹងព្រះរាជវាំងនិងអង្គរធំ នៅក្នុងសៀវភៅដែលផ្សាយដោយអាជ្ញាធរអប្សរា, ប្រវត្តិសង្ខេបអង្គរធំ, បោះពុម្ពលើកទី១, ឆ្នាំ២០០១ ។
[៣៤] គេប្រទះឃើញមានភស្តុតាងជាច្រើននៃសម័យអង្គរនៅបូជនីយដ្ឋានវត្តភូតាំងពីដើមស.វ.ទី៩មកម្ល៉េះ ជាពិសេសសិលាចារិកដែលចារនៅបូជនីយដ្ឋានតែម្ដង។ Cœdès, *I.C.* VI : 30.




*រូបទី១០ - ផ្លូវបេងភ្ជាប់ពីប្រាសាទចៅស្រីវិបុលទៅប្រាសាទមាលា (កែសម្រួលពីផែនទីក្រសួងសាធារណៈការនិងដឹក ជញ្ជូននិងJICA ឆ្នាំ២០០៣)*

ដោយសណ្តូកតាមមុខខាងត្បូងនៃប្រាសាទមាលា (ប្រាសាទដែលឃើញទ្រង់ទ្រាយសព្វថ្ងៃស្ថាបនានៅសម័យក្រោយនេះ)។ នៅត្រង់ចុងអាគ្នេយ៍នៃប្រាសាទមាលាផ្លូវបេងព្រែកជាពីរបន្តទៀត។ ទីមួយ ងាកឡើងឦសានសំដៅទៅកោះកេរ្តិ៍ រួចបន្ទាប់មកឡើងបន្តសំដៅឆ្ពោះទៅវត្តភូ ដោយកាត់តាមដែនដីនៃភ្នំសណ្តក[៣៥], ប្រាសាទអ្នកបួស[៣៦], និងប្រាសាទប្រាំល្វែង[៣៧] (មើលរូបទី១១ និង១២)។ តាមបណ្តោយខ្សែផ្លូវនេះ យើងប្រទះឃើញស្ពានថ្មនិងសំណង់រក្សាទឹកខ្លះៗ ប៉ុន្តែគ្មានសាលាសំណាក់ទេ។ កំណាត់ផ្លូវចេញពីអង្គរមកដល់ត្រឹមប្រាសាទមាលា មានសាលាសំណាក់មួយនិងមន្ទីរពេទ្យមួយ។ សំណង់ទាំងពីរនេះ ស្ថាបនាឡើងនៅក្នុងបរិវេណប្រាសាទមាលាតែម្តង។ សាលាសំណាក់ស្ថិតនៅខាងកើតនៃប្រាសាទធំ ខាងជើងថ្នល់បណ្តោយឆ្ពោះទៅរហាល ហើយមានឈ្មោះថា "គុកទ័ពធំ"។ រីឯមន្ទីរពេទ្យវិញស្ថិតនៅទិសនិរតីនៃប្រាសាទធំមានឈ្មោះថាប្រាសាទ "ដូនច័ន្ទ" (សូមមើលបន្ថែមខាងក្រោម)។ ទីពីរ ផ្លូវបេងសំដៅទៅកើតត្រង់ឆ្ពោះទៅប្រាសាទបាកាណ[៣៨] ដោយឆ្លងតាមស្ពានអូរតាអោងដែលវែងជាងគេ នៅតាមបណ្តោយផ្លូវនេះ

---

៣៥ ភ្នំសណ្តកស្ថិតនៅពាយ័ព្យនៃកោះកេរ្តិ៍។ ជាបូជនីយដ្ឋានធំមួយទំនងជាល្បីរន្ទឺណាស់នៅសម័យបុរាណ។ យើងប្រទះឃើញសិលាចារិកជាច្រើន ដែលរាប់មានតាំងពីរាជ្យព្រះបាទ យសោវរ្ម័ន, ព្រះបាទរាជេន្ទ្រវរ្ម័នព្រមទាំងរាជ្យក្រោយធំៗពីរទៀត គឺរាជ្យព្រះបាទសូរ្យវរ្ម័នទី១ និងព្រះបាទសូរ្យវរ្ម័នទី២ផង។ សិលាចារិកហៅដែនដីនោះថា "សិវបុរ"។Cœdès, *I.C* VII : 89.

៣៦ យើងប្រទះឃើញនៅបុរាណដ្ឋាននេះ មានសិលាចារិកមានកាលបរិច្ឆេទផ្សេងៗគ្នា។ សិលាចារិកដែលចាស់ជាងគេ ចារនៅសម័យមុនអង្គរ។ Cœdès, *I.* VI : 23.

៣៧ Groslier 1924-1926 : 133-135.

៣៨ អ្នកស្រុកហៅប្រាសាទនេះថា "បាកាណ" ប៉ុន្តែដោយអ្នកស្រាវជ្រាវបារាំងស្តាប់ច្រឡំហៅ "ព្រះខ័ន" វិញ។ ដើម្បីចៀសវាងការហៅជាន់នឹងឈ្មោះព្រះខ័ននៅអង្គរ គេបន្ថែមឈ្មោះអតីតខេត្ត"កំពង់ស្វាយ" ដែលប្រាសាទនេះតាំងនៅតពីក្រោយ។




រូបទី១១ _ ផែនទីបណ្តាញផ្លូវ (ប្រភព ៖ Lunet de Lajonquière)




រូបទី១២ _ ខ្សែផ្លូវឆ្ពោះទៅកាន់វត្តភូ (កែសម្រួលពីរូបភាពផ្កាយរណបLandsat ETM)




*រូបទី១៣ - ផ្លូវភ្ជាប់ពីប្រាសាទមាលាទៅបាកាណ (កែសម្រួលពីផែនទីក្រសួងសាធារណៈការនិងដឹកជញ្ជូននិងJICA ឆ្នាំ២០០៣)*

(សូមមើលខាងក្រោមបន្ថែម) និងទីប្រជុំជនខ្នារក្នុងស្រុកជីក្រែង(មើលរូបទី១៣)។ ថ្នល់នេះចូលទៅកាន់ប្រាសាទតាមច្រកខាងលិច។ កំណាត់ផ្លូវនេះមានប្រវែងជាង៧០គ.ម. មានស្ពាន, សាលាសំណាក់និងសំណង់រក្សាទឹកតាំងនៅតាមបណ្ដោយថ្នល់ជាលំដាប់លំដោយ (មើលរូប ទី១៤និង១៥)។ សព្វថ្ងៃ អ្នកស្រុកនៅបន្តប្រើប្រាស់ថ្នល់នេះ សម្រាប់ធ្វើដំណើរមកកាន់ទីប្រជុំជនខ្នារនិងចុះមកកំពង់ក្ដី។

ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ នាដើមស.វ.ទី១២ ក្រៅអំពីការស្ថាបនាអង្គរវត្តដ៏ស្កឹមស្កៃ យើងនៅសម្គាល់ឃើញមានព្រឹត្តការណ៍នយោបាយសំខាន់មួយទៀត។ ព្រឹត្តការណ៍នោះទាក់ទងនឹងចម្បាំងជាមួយប្រទេសដៃវៀតនិងចម្ប៉ា។ ចម្លាក់នៅរោងទងខាងត្បូងផ្នែកខាងកើតនៃអង្គរវត្តក៏មានរំឭកពីប្រវត្តិសាស្ត្រនៃរាជ្យរបស់ព្រះអង្គដែរ។ យើងពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញពីផ្លូវយុទ្ធសាស្ត្រដែលព្រះបាទសូរ្យវរ្ម័នទី២ លើកទ័ពចេញច្បាំងជាច្រើនសារនឹងចាមហើយនិងយួននៅឡើយ។

នាចុងស.វ.ទី១២ និងដើមស.វ.ទី១៣ ក៏មានព្រឹត្តការណ៍នយោបាយសំខាន់ទាក់ទងនិងផ្លូវបេងនេះ ពោលគឺព្រឹត្តការណ៍នៅដើមនិងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ទាក់ទងនឹងការលើកទ័ពមកដេញចាមពីអង្គរ ហើយនិងការលើកទ័ពទៅវាយចាមវិញ។ ចម្លាក់នៅរោងទងខាងក្រៅនៃបាយ័ន្តក៏បានរំឭកពីចម្បាំងទាំងពីរនោះដែរ[៣៩]។

[៣៩] ដូចរៀបរាប់មកខាងលើ ផ្លូវចេញពីរាជធានីអង្គរទៅទិកដីភាគខាងកើតនៃព្រះរាជាណាចក្រ មានតែពីរគឺផ្លូវអាគ្នេយ៍និងផ្លូវបេងនេះឯង។ នៅឆ្នាំ១៩៩៨ ដោយផ្អែកលើសិក្សាលើទិន្នន័យដូចពោលមកខាងលើ ខ្ញុំបានសាកល្បងបង្ហាញពីដំណើរគោចរទាំងនោះ ក្នុងសារណារបស់ខ្ញុំ។ Im 1998 : 32.



រូបទី១៤ - ផ្លូវពីមាលាឆ្ពោះទៅបាកាណ



រូបទី១៥ - ស្រះទឹកនៅតាមបណ្តោយផ្លូវពីមាលាឆ្ពោះទៅបាកាណ

១.៣. ផ្លូវខាងលិច

សំណង់ប្រាសាទដែលបានស្ថាបនានៅតាមបណ្តោយវាលរាបទន្លេសាបឆ្ពោះទៅខាងលិច ហើយរហូតដល់ទៅក្នុងទឹកដីថៃឡង់ដ៏យ៉ាងជ្រៅ បើមើលតាមទម្រង់រចនាបទស្ថាបត្យកម្មឃើញថា មានកាន់តែច្រើនឡើងៗចាប់ពីស.វ.ទី១០និងទី១១មក។ បើរាប់ទាំងសំណង់នៅសម័យមុននេះទៀតនោះ ឃើញថាកាន់តែមានចំនួនច្រើនច្រើនឡើងទៅទៀត។ ជាពិសេស នៅក្នុងបរិវេណបារាយទឹកថ្លាមានបុរីចាស់មួយ ដែលស្ថាបនាឡើងមុនបារាយនោះច្រើនរយឆ្នាំ។ បុរីនោះពាត់ដោយគូទឹកមានប្រាសាទសំខាន់បី គឺអកយំ, ព្រៃក្មេងនិងវត្តខ្នាត។ លោក B-P Groslier បានឲ្យឈ្មោះទៅតាមឈ្មោះភូមិមួយនៅម្តុំខាងត្បូងថ្នល់បារាយនោះថា “បន្ទាយឈើ”[៤០]។ ម្យ៉ាងទៀត ប្រាសាទអកយំឈរនៅលើខ្សែបណ្តោយថ្ងៃនិងភ្នំបាខែង ហើយលើខ្សែទទឹងថ្ងៃនឹងប្រាសាទគោកពោធិ[៤១]ដែលនៅជើង[៤២]។ នៅខាងត្បូងនៃខ្សែបណ្តោយ បើរាប់ពីប្រាសាទអកយំមកកើត មានប្រាសាទបីតម្រៀបគ្នានោះគឺ ៖ កោះហូរ , គោកតាវង្សនិងអ្នកតានារាយណ៍ (ជាប់ខាងជើងព្រលានយន្តហោះសៀមរាប)។ ដូច្នេះ ថ្នល់បណ្តោយខាងលិចនៃភ្នំបាខែងដែលសល់ស្នាមដូចពោលមកខាងដើម ទំនងភ្ជាប់ទៅនឹងបន្ទាយឈើដែលជាបុរីចាស់ ប្រៀបដូចគ្នានឹងថ្នល់អាគ្នេយ៍ភ្ជាប់ទៅហរិហរាល័យ ដែលតាំងនៅខាងកើតដូច្នោះដែរ។

ពេលបារាយលើកនៅស.វ.ទី១១ បានលុបបន្ទាយឈើភាគខាងជើងមួយផ្នែកធំ។ ប្រាសាទអកយំត្រូវលប់បាត់ស្ទើរទាំងស្រុង។ ដូច្នេះ ទំនប់បារាយខាងត្បូងត្រូវប្រើជាថ្នល់សម្រាប់ជាមធ្យោបាយទំនាក់ទំនងឆ្ពោះទៅខាងលិច ចាប់ពីពេលនោះមក។ នេះមិនមែនជារឿងថ្មីទេ។ យើងធ្លាប់ឃើញឧទាហរណ៍ដូច្នេះ នាសម័យមុននេះ តាមដំណើរគោចរនៃផ្លូវអាគ្នេយ៍ ដែលភ្ជាប់ពីរាជធានីទៅហរិហរាល័យ ក៏តាមរយៈថ្នល់បារាយលលៃដែរ រួចបន្តទៅដែនដីខាងកើតតាមជ្រុងអាគ្នេយ៍។ ដូចគ្នានេះដែរ ការប្រើថ្នល់បារាយខាងកើតភ្ជាប់ពីរាជធានីទៅតំបន់ភ្នំបូកតាមជ្រុងឦសាន។

ក្រោយមក នាចុងស.វ.ទី១២ ព្រះបាទជ័យវរ្ម័នទី៧ស្ថាបនាក្រុងអង្គរធំ ដែលរក្សាឈ្មោះដើមដដែលគឺ “យសោធរ”។ រាជធានីយសោធរថ្មីនេះមានបាយ័ន្តជាមណ្ឌល ហើយមានកសិណនិងកំពែងថ្មបាយក្រៀមពាត់ជុំវិញលើផ្ទៃដីប្រមាណប្រាំបួនលានម៉ែត្រក្រឡា ព្រមទាំងមានថ្នល់ទទឹងនិងបណ្តោយថ្ងៃ ដែលចេញពីមណ្ឌលឆ្ពោះទៅទិសទាំងបួន តាមលំនាំនឹងការរៀបចំក្រុងពីមុនរៀងមក[៤៣]។ ថ្នល់បណ្តោយថ្ងៃដែលឆ្ពោះទៅខាងលិចកាត់តាមក្លោងទ្វារតាការ ភ្ជាប់ត្រង់ទៅថ្នល់បារាយទឹកថ្លាតែម្តង។ នាជ្រុងពាយ័ព្យនៃបារាយមានថ្នល់មួយខ្សែរត់ទៅទិសខាងលិច។ ថ្នល់នេះ ដូចពោលមកខាងលើ ខ្ញុំហៅថា “ផ្លូវខាងលិច” ។ ប៉ុន្តែផ្លូវនេះពុំមែនសណ្តូកតាមបណ្តោយថ្ងៃ ឬកើតលិចត្រង់តែម្តងទេ ពោលគឺងាកទៅជើងបន្តិច។ បើយកថ្នល់

[៤០] Groslier 1960 : 87 និង B-P Groslier 1979 : 161.
[៤១] នៅក្នុងដែនដីនេះ មានប្រាសាទឥដ្ឋបីដែលប្រាសាទគោកពោធិស្ថិតនៅខាងជើង បន្ទាប់មកប្រាសាទភ្នំរុង ហើយប្រាសាទរលុះ នៅខាងត្បូងគេ។Stern 1939 : 182-186.
[៤២] Paris 1942 : 320.
[៤៣] Gaucher 2004 : 58-86.

បណ្តោយថ្ងៃនៃបាយ័ន្តមកប្រៀប នោះយើងឃើញថាផ្លូវនេះងាកទៅពាយ័ព្យប្រមាណ២០អង្សា។ តាមរូបភាពពីលើអាកាសយើងសម្គាល់ឃើញស្នាមថ្នល់នេះយ៉ាងវែង ចាប់ពីជ្រុងពាយ័ព្យនៃបារាយទឹកថ្លាតម្រង់ទៅព្រំដែនខ្មែរ_ថៃ ក្នុងភូមិសាស្ត្រស្រុកស្វាយចេក (ខេត្តបន្ទាយមានជ័យ)។ ដំណើរគោចរនៃថ្នល់នេះ កាត់តាមស្រុកពួកនិងស្រុកក្រឡាញ់ (ខេត្តសៀមរាប) ហើយនិងភ្នំស្រុក, ថ្មពួកនិងស្វាយចេក (ខេត្តបន្ទាយមានជ័យ) (មើលរូបទី១៦)។

បើយោងតាមសិលាចារិកដែលតម្កល់នៅប្រាសាទស្តុកកក់ធំ ដែនដីនៅខាងលិចរាជធានីយសោធរចែកចេញជាមណ្ឌលរដ្ឋបាលជាច្រើន[៤៤]។ ទំនាក់ទំនងរវាងរាជធានីនិងមណ្ឌលទាំងនោះ ប្រាកដជាដើរតាមផ្លូវខាងលិចនេះឯង។ នៅខាងលិចទីប្រជុំជននៃស្រុកពួក ថ្នល់កាត់តាមមណ្ឌលបុរាណមួយ ដែលនៅជាប់ខាងត្បូងមានសំណល់បន្ទាយមួយធំដែលមានគូទឹកពាត់ជុំវិញពីក្រៅ ហើយមានកំពែងថ្មបាយក្រៀមនៅខាងក្នុង ព្រមទាំងច្រកចូលពីរ ខាងកើតនិងខាងលិច។ បន្ទាយនេះអ្នកស្រុកហៅថា "កំពែងព្រះស្រុក"[៤៥] ដែលស្ថាបនាឡើងនៅជាប់ត្រើយខាងកើតនៃស្ទឹងព្រះស្រុក។ នៅខាងក្នុងកំពែងមានសំណល់គ្រឹះបុរាណខ្លះៗ និងស្នាមថ្នល់ទទឹងនិងបណ្តោយថ្ងៃដែលចែកកំពែងជាក្រឡាចត្រង្គ។ ខាងកើតកំពែងមានស្រះទឹកធំមួយ ដែលជ្រុងឦសានជាប់នឹងជើងថ្នល់ខាងលិច។ ទៅខាងជើងថ្នល់បន្តិចមានស្នាមដីលើកជាទំនប់ទាបពាត់ផ្ទៃដីដ៏ធំមួយ កើតជាបន្ទាយរាងបួនជ្រុងទ្រវែងដែលមានប្រវែងទទឹងជើង_ត្បូងប្រមាណ១.២០០ម៉ែត្រ និងបណ្តោយលិច_កើតប្រមាណ២.៥០០ម៉ែត្រ។ ថ្នល់ទំនប់ខាងជើងនៃបន្ទាយសន្ទឹងទៅជាប់នឹងភូមិល្វា[៤៦] (មើលទី១៦)។ ផ្លូវខាងលិច មានស្ពានពីរនៅម្តុំនេះ។ ស្ពានរលុះនៅខាងកើតកំពែង[៤៧]។ ស្ពាននៅភាគពាយ័ព្យស្ពានស្ទឹងព្រះស្រុក (មើលបន្ថែមនៅខាងក្រោម)។

យើងពុំប្រទះឃើញមានសំណល់សាលាសំណាក់និងមន្ទីរពេទ្យណាមួយនៅតាមបណ្តោយផ្លូវនេះទេ ប៉ុន្តែមានស្ពាននិងសំណង់រក្សាទឹកជាហូរហែរ។ នាទិសពាយ័ព្យនៃទីប្រជុំជនក្រឡាញ់ ប្រមាណជាង១០គ.ម. ផ្លូវខាងលិចរត់តាមស្ពានដែលវែងជាងគេនៃផ្លូវនេះ គឺស្ពានស្ទឹងស្រែង (មើលបន្ថែមនៅខាងក្រោម)។ ប្រមាណ១០គ.ម. ខាងលិចស្ពានស្រែង ផ្លូវខាងលិចកាត់ខាងជើងនៃបុរីចាស់មួយទៀត ដែលមានទំហំប្រហាក់ប្រហែលនឹងកំពែងព្រះស្រុក។ បុរីមានគូព័ទ្ធពីក្រៅ ដែលមានទំហំប្រមាណ៣០ម៉ែត្រ ហើយមានកំពែងដីលើកពាត់ពីក្នុងមួយជាន់ទៀត ដែលមានប្រវែងបណ្តោយលិច_កើត ១.២០០ម៉ែត្រ និងទទឹងជើង_ត្បូង ៩០០ម៉ែត្រ។ បុរីនេះមានថ្នល់ទទឹងនិងបណ្តោយថ្ងៃកាត់កែងគ្នា[៤៨]។ សព្វថ្ងៃ បុរីនេះ ក្លាយជាទីប្រជុំជនស្រុកភ្នំស្រុក។

មុនមកដល់បុរីនេះ ប៉ុន្មានគីឡូម៉ែត្រភាគខាងកើត ផ្លូវខាងលិចប្រសប់នឹងថ្នល់ចាស់មួយ ដែលចុះមកម្តុំស្ពានទ័ពនៃផ្លូវពាយ័ព្យ (សូមមើលបន្ថែមខាងក្រោម) ចំភូមិត្រពាំងប្រី ត្រង់ចំណុចប៉ុន្មានសិបម៉ែត្រខាងលិចស្ពានក្មេង (មើលរូបទី១៦)។ មកខាងលិច ប្រមាណជាង៥គ.ម. ខាងលិចទីប្រជុំជនភ្នំស្រុក ផ្លូវខាងលិចរត់កាត់វាលទំនាបធំមួយ ដែលអ្នកស្រុកហៅថា "វាលចោក"។ កាត់តាមវាលនេះ ផ្លូវខាងលិចឆ្លងកាត់ស្ពានបុរាណបី បើរាប់ពីកើតទៅ មានស្ពានថ្នល់ដាច់, ស្ពានដាច់និងស្ពានរាប (សូមមើលបន្ថែមខាងក្រោម)[៤៩]។

កាលពីដើម អ្នកស្រុកបិទផ្លូវទឹកត្រង់ស្ពានដាច់ និងប្រើតួថ្នល់នេះជាទំនប់ ដើម្បីរក្សាទឹកប្រើប្រាស់។ អ្នកស្រុកហៅសំណង់រក្សាទឹកនេះថា "ត្រពាំងថ្ម"[៥០]។ ប៉ុន្តែត្រពាំងនោះមិនធំដូចឃើញសព្វថ្ងៃនេះទេ ហើយអាចរីងដោយឆ្នាំខ្លះ។ ក្រោយមកនាសម័យកម្ពុជាប្រជាធិបតេយ្យ គេកែនប្រជាជនឲ្យទៅលើកដី យកមកបូកពីលើថ្នល់ចាស់ដោយកន្លែង និងលុបស្ពានទាំងបីនៅត្រង់នោះ ហើយនិងលុបស្ពានស្រែងដែលនៅខាងកើត (សូមមើលបន្ថែមខាងក្រោម) ព្រមទាំងបង្កើតទំនប់ទ្វារជាច្រើន ចាប់ពីខាងកើតស្ពានស្រែងត្រង់ថ្នល់ដាច់ (ចំណុចប្រសប់នៃផ្លូវខាងលិចនិងផ្លូវថ្មីលេខ៦៨ ដែលស្ថិតនៅខាងជើងទីប្រជុំជនស្រុកក្រឡាញ់ចម្ងាយ១០គ.ម.) ដើម្បីនាំទឹកទៅបញ្ចូលនិងរក្សាក្នុងត្រពាំងថ្ម សម្រាប់គម្រោងអភិវឌ្ឍន៍កសិកម្មនៅសម័យនោះ។

---

[៤៤] Cœdès & Dupont 1943 : 56-134 និង Groslier 1925 : 359.
[៤៥] អ្នកស្រុកនៅម្តុំនេះដំណាលតគ្នាថា កំពែងនេះសាងជាគំរូ មុននឹងយកលំនាំនេះទៅស្ថាបនាអង្គរតូច និងអង្គរធំ។
[៤៦] ភូមល្វាជាស្ថានីយ៍បុរេប្រវត្តិនៃយុគថ្ម។ សូមអានបន្ថែម Martel 1975.
[៤៧] សព្វថ្ងៃ ផ្លូវមួយកំណាត់ត្រង់នេះ ត្រូវក្រុមហ៊ុនឯកជនមួយ ឈូសពង្រាបដើម្បីបង្កើតវាលវាយកូនគោល។
[៤៨] Aymonier 1901 : 348-349 និង Lunet de Lajonquière 1911 : 366.
[៤៩] កាលសម័យលោក Lunet de Lajonquière មកស្រាវជ្រាវដើម្បីដល់ទឹកដីនេះ ស្ពានដាច់នៅសល់ត្រឹមតែគំនរថ្មបាយក្រៀមប៉ុណ្ណោះ។ រីឯស្ពានថ្នល់ដាច់វិញ នៅអាចធ្វើដំណើរឆ្លងកាត់បានដោយកន្លែង។ ចំណែកស្ពានរាបនៅល្អជាងគេ។
[៥០] Lunet de Lajonquière 1911 : 369.

ពេលនោះគេហៅត្រពាំងថ្មថា "អាងទឹក១មិថុនា"។ សព្វថ្ងៃ អាងនេះមានទំហំធំជាងទ្រង់ទ្រាយដើមច្រើនដងណាស់ ព្រមទាំងត្រូវពង្រីករចនាសម្ព័ន្ធសំណង់ទំនប់និងទ្វារទឹកខ្លះបន្ថែម។ អាជ្ញាធរដែនដីដាក់ឈ្មោះជាផ្លូវការថា "អាងទឹកត្រពាំងថ្ម" វិញ។

ទំនប់ខាងត្បូងនៃ "អាងទឹកត្រពាំងថ្ម" ជាជង្គផ្លូវខាងលិច។ នៅដើមស.វ.ទី២០ លោក Aymonier ប្រទះឃើញថ្នល់មួយខ្សែបែក ពីផ្លូវនេះត្រង់ខាងលិចស្ពានរាបប៉ុន្មានម៉ែត្ររត់ឡើងឆ្ពោះទៅជើង។ ថ្នល់នេះកាត់តាមយសោធរាស្រមមួយ ដែលស្ថិតនៅខាងកើតស្រុកស្វាយចេកសព្វថ្ងៃ (គេហៅថាប្រាសាទតាសៀវ) រួចភ្ជាប់ទៅបន្ទាយច្មារតាមជ្រុងអាគ្នេយ៍ ដោយសសៀរតាមបណ្ដោយថ្នល់រហាលខាងត្បូង[៥១]។ ដោយសារគេពង្រីកទំហំត្រពាំងថ្មដូចពោលខាងដើម ថ្នល់ភ្ជាប់ទៅបន្ទាយច្មារបាត់ដានផ្នែកខាងក្រោមនេះ តែស្នាមខាងជើងនៅអាចមើលស្គាល់ (មើលរូបទី១៧)។

ក្នុងទឹកដីស្រុកស្វាយចេក យើងប្រទះឃើញមានសិលាចារិកនៃប្រាសាទពីរ ដែលបង្ហាញឈ្មោះមណ្ឌលរដ្ឋបាលពីរ ដូចគ្នានឹងសិលាចារិកនៅប្រាសាទស្តុកកក់ធំដែរ។ នោះគឺ "ស្តុករមាំង" (មានន័យថា "ស្រះរមាំង") ចារនៅប្រាសាទរលុះ ដែលនៅខាងកើតនិង "ត្បូងរមាំង" ចារនៅបន្ទាយព្រាវនៅខាងលិច[៥២]។ រីឯនៅភាគក្នុងដីថៃឡង់ដ៏សព្វថ្ងៃវិញ ពោលគឺក្នុងតំបន់ប្រាសាទស្តុកកក់ធំ យើងអាចមើលឃើញស្នាមថ្នល់ ដែលតមកពីព្រំដែនខ្មែរ_ថៃ សសៀរតាមបណ្ដោយទំនប់ខាងជើងនៃល្បើករបស់ប្រាសាទដែលនៅខាងកើត ឆ្ពោះមកលិចស្របនឹងខ្សែបណ្ដោយថ្ងៃនៃប្រាសាទ។ នៅជ្រុងពាយ័ព្យខាងក្រៅកំពែងប្រាសាទ ថ្នល់នេះកាត់កែងនឹងថ្នល់មួយទៀត ដែលរត់ទទឹងថ្ងៃឆ្ពោះទៅជើង សំដៅភ្នំដងរែកនៃខ្ពង់រាបនគររាជ (ស្រុកថៃគេហៅថា "នគររាជសីមា")។ ដូចពោលមកខាងដើម សិលាចារិកស្តុកកក់ធំមាននិយាយទាក់ទងនឹងមណ្ឌលរដ្ឋបាលខ្លះៗនៅភាគខាងលិចនេះ។ ទឹកដីនៅម្តុំនោះ មានស្រុកបុរាណសំខាន់ពីរគឺ "ស្តុករឡិ" (មានន័យថា"ស្រះឫស្សី") ទំនងមានប្រាសាទស្តុកកក់ធំជាមណ្ឌល ហើយនៅខាងជើង "ភទ្របត្តន" ដែលមានប្រាសាទជាច្រើននៅរាយរហូតដល់ច្រកជួរភ្នំដងរែក "តាកោ" (មើលរូបទី១៩)។ ឆ្ពោះទៅខាងលិចប្រាសាទស្តុកកក់ធំ តួថ្នល់បានបាត់រូបរាងហើយ ប៉ុន្តែនៅសល់តែស្នាមទួលនៅដាច់ៗពីគ្នា ដែលមានដើមឈើដុះពីលើ បន្តគ្នាមិនឆ្ងាយពីបរិវេណប្រាសាទប៉ុន្មាន។ ក្នុងភូមិសាស្ត្រខេត្តស្រះកែវដែលនៅភាគខាងលិចនៃប្រាសាទស្តុកកក់ធំមានសំណល់ប្រាសាទខ្មែរច្រើន ហើយស្ថាបនាក្នុងរាជ្យផ្សេងៗគ្នាផង (មើលរូបទី២០)។

ប៉ុន្មានឆ្នាំមកនេះ លោកគ្រូ Vickery បានសិក្សាស្រាវជ្រាវជាថ្មីលើសិលាចារិក K. 506 និង K.1150 នៃប្រាសាទ "ខៅណាយ" នៅខេត្តស្រះកែវ។ លោកយល់ថានៅស.វ.ទី៧ ក្នុងរាជ្យព្រះបាទឦសានវរ្ម័ន កម្ពុជាគ្រប់គ្រងពេញលេញនៅដែនដី "តាប្រាយ៉ា" (Ta Phraya) ហើយនិងកំពុងបើកមុខទៅកាន់ សមុទ្រនៅតំបន់ជ្រោយ "វត្សូនា" ពោលគឺពង្រីកទឹកដីតាមបណ្ដោយវាលរាបទំនាបកណ្ដាលនៅស្រុកខ្មែរ ឆ្ពោះទៅកាន់វាលរាបនៃទន្លេមេណាម[៥៣]។ ក្រោយពីនេះ យើងលែងប្រទះឃើញមានសិលាចារិកទាក់ទងនឹងខ្មែរ រហូតដល់រាជ្យព្រះបាទសូរ្យវរ្ម័នទី១។ ពោលគឺក្នុងរាជ្យនេះ អារ្យធម៌អង្គរសាយខ្លាំងឡើងៗនៅភាគកណ្ដាលនៃវាលរាបមេណាម[៥៤]។ នាស.វ.ទី១២ ព្រះបាទសូរ្យវរ្ម័នទី២ រួចក្រោយមកព្រះបាទជ័យវរ្ម័នទី៧ បានពង្រីកឥទ្ធិពលនៃដែនដីខ្មែរឲ្យក្លាយជាចក្រភពដ៏ធំមួយ។ តឹកតាងជាប្រវត្តិសាស្ត្រនៃការពង្រីកនោះមានច្រើនណាស់ បើរាប់ពីសំណល់ស្ថាបត្យកម្មមានដូចជាប្រាសាទ, សំណល់ក្រុង, សាលាសំណាក់, មន្ទីរពេទ្យ, ប្រព័ន្ធធារាសាស្ត្រជាដើម។ ក្រៅពីនេះ បើយោងលើប្រភពសិលាចារិកក្នុងរាជ្យ ខាងលើក៏យើងប្រទះឃើញមានការរៀបរាប់អំពីឈ្មោះនៃដែនដីនៅខាងលិចនោះខ្លះៗដែរ។ ទី១ សម្បថនៃតម្រួចទាំងបួនថ្នាក់ ជំនាន់ព្រះបាទសូរ្យវរ្ម័នទី១ ដែលជាតំណាងអ្នកគ្រប់គ្រងខេត្តខណ្ឌនៃចក្រភពប្រមាណពីរយឈ្មោះ។ ក្នុងនោះ មានអ្នកតំណាងមកពី "ល្វោ" (លពបុរីសព្វថ្ងៃ)[៥៥]។ ទី២ សិលាចារិកខ្លីៗចារលើរោងទងខាងត្បូងផ្នែកខាងលិចនៃអង្គរវត្ត ដែលរំឭកពិធីបព្ចុះទ័ពនៃព្រះបាទសូរ្យវរ្ម័នទី២។ ក្នុងចំណោមមេទ័ពដែលតំណាងដែនដីនៃចក្រភពខ្មែរ ក៏មានមកពី "ល្វោ" ដែរ[៥៦]។ ទី៣ សិលាចារិកខ្លីៗ ចារលើមេទ្វារនៃប្រាសាទតូចៗនៅបាយ័ន្ត ដែលបង្ហាញពីឈ្មោះទេពដែលតម្កល់ក្នុងប្រាសាទមួយ ហើយតំណាងឲ្យខេត្តខណ្ឌនៃព្រះរាជាណាចក្រ[៥៧]។ ក្នុងចំណោមនោះ ក៏មានទេពតំណាងឲ្យដែនដី "ភិម័យ" ជាដើម។ ដូចនេះ ផ្លូវខាងលិចនិងផ្លូវពាយ័ព្យ (សូមមើលបន្ថែមខាងក្រោម) ពិតណាស់ថាជាខ្សែភ្ជាប់ទំនាក់ទំនងរវាងមណ្ឌលនៅអង្គរទៅនឹងដែនដីនៅខាងលិច។

---

៥១ Aymonier 1901 : 332-333

៥២ Aymonier 1901 : 326-327 និង Cœdès, *I.C.* III : 54-64.

៥៣ Vickery 1998 : 198-199, 330-332, 338.

៥៤ Vickery 1985 : 226-224.

៥៥ Cœdès, *I.C.* III : 208.

៥៦ Cœdès 1911 : 402 និង Le Bonheur & Poncar 1995 : 22.

៥៧ Dumarçay & B-P. Groslier 1973 : 10-306.

រូបទី១៦ _ បណ្តាញផ្លូវនិងរចនាសម្ព័ន្ធពាក់ព័ន្ធនៅជុំវិញរាជធានី, វាលខាងលិចនិងវាលខាងជើង





ស្ពានថ្មវត្តស្វាយ
ស្ពានព្រៃស្ពាន
ស្រុកអង្គរជុំ
ក្បាលស្ពាន
ផ្លូវភ្នំគូលែន
បន្ទាយស្រី
ភ្នំដី
ភូមិគោកថ្មី
ស្ពានវាលរាជដាក
ស្ពានថ្មី
ព្រះខ័ន
វាលរាជដាក
ស្ពានមេម៉ាយ
បារាយទឹកថ្លា
ស្រុកពួក
អង្គរធំ
តាព្រហ្ម
ប្រែរូប
ភ្នំបាខែង
អង្គរវត្ត
ចៅស្រីវិបុល
ក្រុងសៀមរាប




រូបទី១៧ - ផ្លូវភ្ជាប់ទៅបន្ទាយឆ្មារ (កែសម្រួលពីឯកសាររបស់អង្គការ The Halo Trust)




រូបទី១៨ - សំណល់ប្រាសាទខ្មែរនៅខេត្តស្រះកែវ, ថៃឡង់ដ៍ (កែសម្រួលពីរូបភាពផ្កាយរណបLandsat ETM)

១.៤. ផ្លូវពាយ័ព្យ

យើងស្គាល់ផ្លូវនេះគ្រប់គ្នាថា “ផ្លូវអង្គរទៅភិម័យ” ដោយសារផ្លូវនេះភ្ជាប់រាជធានីអង្គរទៅភិម័យ។ ទិន្នន័យខ្លះដែលយកមកពីបង្ហាញក្នុងចំណុចនេះ បានមកពីគម្រោងសហការណ៏ស្រាវជ្រាវខ្មែរ_ថៃ ដូចជម្រាបមកខាងដើម។

ដំណើរគោចរនៃផ្លូវរត់ទៅលើទិសពាយ័ព្យនៃក្រុងអង្គរធំ។ យើងទៅមើលស្គាល់ស្នាមថ្នល់នេះ ចាប់ពីក្រុងអង្គរធំរហូតដល់ស្រុកចុងកល្ប នៃ (ខេត្តឧត្តរមានជ័យ)។ មួយកំណាត់ថ្នល់ដែលបន្តទៅទល់នឹងព្រំដែនខ្មែរ_ថៃ នៅសល់ស្នាមខ្លះប៉ុណ្ណោះ រីឯផ្នែកនៅក្នុងទឹកដីថៃឡង់ដីសព្វថ្ងៃ យើងពុំប្រទះឃើញស្នាមទេ។ ដោយការរៀបចំដែនដីទៅវាលខាងជើងអង្គរធំស្អេកស្កះពេក ខ្ញុំសូមចាប់និយាយបញ្រ្ចាស់ពីជើងមកត្បូងបន្តិចមុន ពោលគឺសំដៅទៅដើមផ្លូវវិញ។ ខ្សែផ្លូវរត់តាមគន្លងអាគ្នេយ៏_ពាយ័ព្យឆ្ពោះទៅស្រុកចុងកល្ប ចាប់ត្រឹមម្តុំខាងលិចភូមិទ័ពស្វាយ ដែលជាទីប្រសប់រវាងឃុំនគរភាសនៃស្រុកអង្គរជុំនិងឃុំជប់តាត្រាវនៃស្រុកអង្គរធំ (ជាង១៦គ.ម.ភាគខាងជើងអង្គរធំ) គឺម្តុំខាងអាគ្នេយ៏នៃប្រាសាទធំមួយ[៥៨]។ ត្រង់នេះ បើប្រៀបនឹងខ្សែបណ្តោយថ្ងៃនៃអង្គរធំ ផ្លូវនេះងាកទៅជើងប្រមាណ៤០អង្សា។

រឿងទាក់ទងនឹងដើមផ្លូវនោះ គឺចាប់ពីត្រង់នេះចុះមកត្បូង។ នៅមិនឆ្ងាយប៉ុន្មានពីប្រាសាទព្រះខ័នភាគអាគ្នេយ៏ ខ្សែផ្លូវពាយ័ព្យងាកទៅខាងត្បូងបន្តិចប្រៀបនឹងតម្រុយខាងលើមកដល់ត្រឹមម្តុំខាងជើងឃុំស្វាយចេក ពោលគឺប្រហែល២០អង្សាងាកចាកពីគន្លងអាគ្នេយ៏_ពាយ័ព្យ។ ចាប់ពីចំណុចនេះមកក្រោម ផ្លូវរត់ចុះមកត្បូងស្ទើរតែត្រង់តែម្តង។ បានសេចក្តីថា បើប្រៀបនឹងខ្សែបណ្តោយថ្ងៃនៃអង្គរធំ គឺស្ទើរតែកាត់កែងគ្នា។ មកចំណុចដែលជាទីប្រសប់នៃភូមិព្រះគោថ្មី (ខាងលិច), គោកគ្រើល (ខាងកើត) ពោលគឺត្រង់ទីប្រសប់នឹងថ្នល់បណ្តោយថ្ងៃមួយខ្សែ[៥៩] នៅឦសានប្រាសាទស្រឡៅ យើងប្រទះឃើញផ្លូវពាយ័ព្យព្រែកជាបីផ្លូវរត់ចុះមកត្បូងត្រង់ សំដៅថ្នល់បារាយទឹកថ្លាក្នុងភូមិគោកបេង (មើលរូបទី១៦)។

ផ្លូវទាំងបីរត់ស្ទើរតែស្របគ្នានឹងខ្សែទទឹងថ្ងៃនៃអង្គរធំ ហើយមកប្រសប់នឹងថ្នល់បារាយខាងជើងរាំងគ្នាពីកើតទៅលិច ដោយកាត់តាមថ្នល់ទំនប់បណ្តោយថ្ងៃមួយទៀត ត្រង់ភូមិប្រណិត។ ថ្នល់បណ្តោយថ្ងៃនេះ រត់នៅភាគខាងត្បូង ហើយស្របនឹងផ្លូវព្រះរាម។ ភាគខាងកើតនៃថ្នល់នេះរត់ពីខាងជើងប្រាសាទព្រះខ័ន ហើយខាងត្បូងប្រាសាទប្រីនិងបន្ទាយប្រី ព្រមទាំងរត់លើថ្នល់ទំនប់ខាងជើងនៃវាលរាជដាក[៦០] ដែលទៅជិតជ្រុងឦសានថ្នល់បណ្តោយកាត់តាមស្ពានបុរាណមួយឈ្មោះថា “ស្ពានវាលរាជដាក”។ បន្ទាប់មក ថ្នល់នេះឆ្ពោះទៅទល់នឹងស្ទឹងរលួសនៅក្បែរ ជើងភ្នំបូកភាគខាងលិច ដោយកាត់ទទឹងស្ទឹងសៀមរាបតាមស្ពានបុរាណមួយឈ្មោះ “ស្ពានធំ”។ រីឯភាគខាងលិចវិញ ថ្នល់បណ្តោយសសៀរតាម ខាងជើងប្រាសាទគោកពោធិបានឆ្ងាយបន្តិចក៏បត់ចុះមកនិរតី ប្រសប់នឹងផ្លូវខាងលិចត្រង់ភូមិចំបក់ហែរ។

ផ្លូវខាងកើតគេ ក្នុងចំណោមផ្លូវបីបន្តពីផ្លូវពាយ័ព្យ កាត់កែងនឹងថ្នល់បារាយត្រង់ជ្រុងឦសាន។ ថ្នល់បណ្តោយថ្ងៃនៃបាយ័ន្ត ចេញទៅក្រៅក្រុងតាមក្លោងទ្វារតាការ (ក្លោងទ្វារខាងលិច) ក៏មកភ្ជាប់នឹងថ្នល់បារាយខាងកើតដែរ។ ដូច្នេះ ក្រុងអង្គរធំនិងផ្លូវពាយ័ព្យតភ្ជាប់ តាមរយៈថ្នល់បារាយនេះឯង។ ចំណែកឯប្រាសាទព្រះខ័ន, នាគព័ន្ធនិងប្រាសាទដទៃទៀតនៅខាងជើងក្រុង ព្រមទាំងផ្លូវខាងជើងផង (សូមមើលខាងក្រោម) ប្រហែលជាភ្ជាប់ទំនាក់ទំនងទៅនឹងផ្លូវពាយ័ព្យ តាមថ្នល់បណ្តោយ(តពីភ្នំបូកនៅខាងកើតមកប្រាសាទគោកពោធិ នៅខាងលិច) ដូចពោលមកខាងលើ។

ចាប់ពីដើមផ្លូវទល់នឹងព្រំដែន ផ្លូវពាយ័ព្យរត់កាត់តាមស្រុកសៀមរាប, អង្គរធំ, អង្គរជុំនិងស្រីស្នំ (ខេត្តសៀមរាប) ហើយនឹងស្រុកចុងកល្បនិងសំរោងនៃ (ខេត្តឧត្តរមានជ័យ)។ ចាប់ពីប្រាសាទព្រះខ័ន (ខាងលិចអូរចារ) ទៅជើង ផ្លូវពាយ័ព្យរត់លើគន្លងអាគ្នេយ៏_ ពាយ័ព្យទៅទល់នឹងព្រំដែនខ្មែរ_ថៃ ត្រង់ច្រកច្លងកាត់ភ្នំដងរែក “អូរស្មាច់” (មើលរូបទី១៦)។ ផ្លូវនេះមានប្រវែងសារុបប្រមាណជាង២៤០ គ.ម. ចាប់ពីរាជធានីអង្គរទៅទល់នឹងភិម័យ ។ ប្រវែងក្នុងដែនដីខ្មែរ ចាប់ពីអង្គរទល់ច្រកច្លងកាត់ភ្នំដងរែកមានជិត ១២០គ.ម. ដោយមានសាលាសំណាក់, ស្ពាននិងសំណង់រក្សាទឹកជាហូរហែរនៅតាមដងផ្លូវ (សូមមើលបន្ថែមខាងក្រោម)។ ប៉ុន្តែ យើងពុំមានប្រទះឃើញមន្ទីរពេទ្យទេ ក្រៅពីនៅដើមផ្លូវពោលគឺនៅអង្គរ។ រីឯខាង

---

[៥៨] អ្នកស្រុកហៅថា “ព្រះខ័ន” ស្ថិតនៅខាងលិចអូរចារប្រមាណមួយគីឡូម៉ែត្រ។ ផ្លូវពាយ័ព្យកាត់ប្រាសាទនេះចំពាក់កណ្តាលតែម្តង។

[៥៩] ថ្នល់នេះ អ្នកស្រុកហៅថា “ផ្លូវព្រះរាម” ដែលទំនងជាចេញពីម្តុំភូមិតាកុះនៅខាងកើតសំដៅឆ្ងាយទៅខាងលិច ដោយសសៀរតាមគូរទឹកខាងក្រៅនៃវត្តនាមរូប ហើយរត់ពីខាងជើងនៃភូមិល្វា ព្រមទាំងបត់មកត្បូងប្រសប់នឹងផ្លូវខាងលិចក្នុងភូមិសាស្រ្តគោកថ្មី ស្រុកពួកនៅប្រមាណ២គ.ម.ខាងលិចស្ពានស្ទឹងព្រះស្រុក។ ផ្លូវព្រះរាមកាត់កែងនឹងផ្លូវទទឹងថ្ងៃខាងជើងអង្គរធំនៅខាងកើតភូមិគោកគ្រើល។

[៦០] បារាយដែលជំនាន់ដើមហៅ “ជ័យតដាក” ហើយមានប្រាសាទនាគព័ន្ធនៅកណ្តាល។

ដីថៃឡង់ដីមានប្រវែងជាង ១២០គ.ម. ចាប់ពីច្រកអូរស្មាច់ទល់នឹងភិម័យ។ ក្នុងប្រវែងចម្ងាយនេះមានសាលាសំណាក់និងមន្ទីរពេទ្យ ប៉ុន្តែគ្មានស្ពាន បុរាណ ណាមួយទេ[៦១] ។

១.៥. ផ្លូវខាងជើង[៦២]

ផ្លូវនេះជាបន្តនៃថ្នល់ទទឹងថ្ងៃនៃអង្គរធំ ដែលចេញពីក្លោងទ្វារដីឆ្នាំង ។ ថ្នល់នេះនៅសល់ស្នាមប្រមាណជាង២០គ.ម.ទៅជើង ដោយកាត់តាមភូមិអង្គរក្រៅនៃស្រុកសៀមរាប និងតាមបណ្តោយស្រុកអង្គរធំ រហូតដល់ចុងខាងជើង(មើលរូបទី១និង១៦)។ តាមការចុះស្រាវជ្រាវដល់កន្លែងឃើញថា ស្នាមថ្នល់ដែលមានរាងជាទំនប់ដីលើខ្ពស់នេះ ខិតទៅទល់នឹងជួរភ្នំគូលេនភាគខាងលិច ពោលគឺនៅតំបន់ប្រជុំកូនភ្នំខាងលិចក្បាលស្ពានប្រមាណជា១០ គ.ម.។ ម្តុំនេះ មានកូនភ្នំប្រហែលដប់ដែលនៅជាប់ៗគ្នា ហើយមានកម្ពស់ពីត្បូងទៅជើងខុសៗគ្នា ពី ១០០ម៉ែត្រឡើងទល់នឹងជាង ៣០០ម៉ែត្រ។ បើរាប់ពីត្បូងកូនភ្នំទាំងនេះមាន ៖ ភ្នំកង្រី, តាទា, ចម្ការ, ចង្ក្រានរយ, ស្វែត, ព្រៃចាំង, គ្រប ។ល។ ថ្នល់ខាងជើងនេះឡើងទៅដល់ភ្នំតាទា។ ផុតពីភ្នំនេះទៅ យើងឃើញមានស្នាមផ្លូវលំដែលអ្នកស្រុកដើរឆ្លោះទៅជើងឆ្ងាយទៀត។

ចាប់ពីក្លោងទ្វារដីឆ្នាំង ផ្លូវរត់តាមស្ថានីយ៍បុរាណជាច្រើនដែលមានដូចជា ៖ ប្រាសាទទន្លេស្ងួត (មន្ទីរពេទ្យ) នៅខាងលិច, ទន្លេស្ងួត (សំណង់រក្សាទឹក) នៅខាងកើត, ថ្នល់បណ្តោយប្រាសាទគោកពោធិភ្ជាប់មកភ្នំបូក (សូមមើលខាងលើ), ប្រាសាទថ្ម (សាលាសំណាក់) នៅខាងកើត, បន្ទាយធំនៅខាងលិច, ផ្លូវព្រះរាម, ប្រាសាទភ្នំដីនិងភ្នំកណ្តាលនៅជាប់ខាងលិច, ប្រាសាទកង្រី (នៅលើភ្នំកង្រី)។ល។ នៅម្តុំប្រាសាទកង្រីនេះ យើងប្រទះឃើញផ្លូវលំចាស់ពីរខ្សែ ដែលរត់ទៅកើតឆ្លោះទៅភូមិកំព្រហ្ម[៦៣] (ខាងជើងប្រាសាទបន្ទាយស្រី) ដោយសសៀរតាមជើងភ្នំក្បាលស្ពាននិងមួយទៀតឆ្លោះមកលិចសំដៅមកវត្តប្រាសាទ (ស្ថិតនៅក្នុងភូមិប្រាសាទ) រួចបត់មកត្បូងបន្តប្រសប់នឹងផ្លូវពាយ័ព្យត្រង់ស្ពានថ្កែកូន (ស្ពានបុរាណ) នៅក្នុងភូមិស្រះនៃស្រុកពួក[៦៤]។

ថ្នល់នេះកាត់ផ្លូវទឹកដែលហូរចុះមកពីជួរភ្នំគូលេន និងប្រឡាយខ្វាត់ខ្វែងដែលស្ថាបនាឡើងនៅវាលលើនេះ ព្រមទាំងសំណង់រក្សាទឹកជាហូរហែរ។ ប៉ុន្តែយើងពុំដែលប្រទះឃើញមានស្ពានថ្មណាមួយនៅតាមបណ្តោយផ្លូវនេះទេ។

## គ.រចនាសម្ព័ន្ធពាក់ព័ន្ធនឹងបណ្តាញផ្លូវ

### គ.១. ស្ពាន[៦៥]

ដូចបានបរិយាយមកខាងដើមថា បុរីខ្មែរតែងកសាងនៅក្នុងវាលរាបស្មើបផុតពីទឹក ហើយនៅក្បែរៗផ្លូវទឹកជានិច្ច។ បើស្ថាបនានៅឆ្ងាយ

---

៦១ អ្នកស្រាវជ្រាវថៃនៃក្រុមសិល្បករបានសិក្សាកាលពីឆ្នាំមុននេះអំពីបេតិកភណ្ឌរូបិយ តាមបណ្តោយផ្លូវចាប់ពីព្រំដែនទៅទល់នឹងប្រាសាទភិម័យ ហើយបង្កើតជាតារាងទិន្នន័យបេតិកភណ្ឌផង។

៦២ ទិន្នន័យមួយភាគនៃផ្នែកនេះ បានមកពី Khut 2003 ។

៦៣ ត្រង់នេះ មានផ្លូវលំចុះទៅត្បូងបន្ត ភ្ជាប់ទៅម្តុំគោករហាល (ស្ថានីយ៍បុរាណ) ដែលស្ថិតនៅខាងលិចបន្ទាយស្រី។

៦៤ Khut 2003 : 63-64.

៦៥ - តទៅខាងក្រោមនេះ ខ្ញុំនឹងសង្ខេបរឿងដែលទាក់ទងនឹងស្ពាន ហើយជាពិសេសនឹងបន្ថែមទិន្នន័យថ្មីដែលបានមកពីការស្រាវជ្រាវជាបន្តបន្ទាប់ទៀត ទៅលើការស្រាវជ្រាវរបស់លោក Bruno Bruguier (Bruguier 2000 : 529-551)។ ទន្ទឹមនឹងនេះ គម្រោងការងារលោក Bruguier ដែរហៅថា "កម្មវិធីចុះបញ្ជីបេតិកភណ្ឌប្រាសាទបុរាណនិង ទប់ស្កាត់ការជួញដូរវត្ថុបុរាណខុសច្បាប់" (គម្រោងសហការណ៍រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងសាលាបារាំងចុងបូព៌ា) កំពុងបន្តការងារមកទល់សព្វថ្ងៃ ហើយទិន្នន័យទៀតសោតក៏ប្រទះកាន់តែច្រើនឡើង។ ពេលអនាគតដ៏ខ្លីទិន្នន័យដែលទើបប្រទះឃើញសន្ធឹកសន្ធាប់នោះ នឹងផ្សាយជាផ្លូវការ។

- ខ្ញុំសូមបញ្ជាក់ថា ឈ្មោះស្ពានទាំងប៉ុន្មានដែលធ្លាប់ហៅកន្លងមក គឺយកតាមលំនាំឈ្មោះដែលអ្នកស្រុកហៅ។ ចំណែកស្ពានគ្មានឈ្មោះអ្នកស្រាវជ្រាវសម្គាល់ជាលេខរៀងគ្នា តាមរបៀបចុះបញ្ជីបេតិកភណ្ឌរបស់លោក Lunet de Lajonquière។ ចំពោះស្ពានមានឈ្មោះហៅក៏មានលេខសម្គាល់ដែរ។ អត្ថបទរបស់លោក Bruguier ខាងលើបានធ្វើដូច្នេះមក។ រីស្ពានថ្មីដែលមិនមានក្នុងបញ្ជីរបស់លោក ខ្ញុំនឹងហៅតែតាមឈ្មោះដែលមានមក ដោយឲ្យកូអរដោនេភូមិសាស្ត្ររួមមកផង។ បើស្ពានពុំមានឈ្មោះទេ ខ្ញុំនឹងហៅជាលេខទីប៉ុន្មានបន្តពីស្ពានដែលមានឈ្មោះ ព្រមទាំងអមដោយកូអរដោនេភូមិសាស្ត្រផង។

ពីផ្លូវទឹក គឺតែងបង្កើតជាប្រព័ន្ធទឹកភ្ជាប់មកដែរ។ វាលរាបនោះ ស្រោចស្រពដោយផ្លូវទឹកធម្មជាតិ ដែលនាំទឹកពីតំបន់ខ្ពស់ហូរចូលមកទន្លេសាប ឬទន្លេមេគង្គ។ ករណីសិក្សានេះមានរាជធានីអង្គរជាមណ្ឌល ដែលកសាងឡើងនៅក្នុងទំនាបទន្លេសាបភាគខាងជើង យើងហៅថា "វាលរាបអង្គរ" ហើយមានបុរីផ្សេងៗជារណបដែលស្ថិតនៅតាមបណ្ដោយទំនាបនេះដែរ។ បុរីទាំងនោះ ភ្ជាប់នឹងមណ្ឌលតាមបណ្ដាញផ្លូវដូចពោលមកខាងលើ។ ដូច្នេះ ខ្សែផ្លូវទាំងនោះកាត់ទទឹងខ្សែទឹកដែលហូរចុះមកត្បូង ដោយយល់ឃើញថានៅរដូវវស្សាចរន្តទឹកហូរខ្លាំង ខ្មែរបុរាណលើកផ្លូវខ្ពស់ហើយមានទំហំធំ ព្រមទាំងស្ថាបនាស្ពានថ្មយ៉ាងមាំហើយវិចិត្រផង ដើម្បីការពារទឹកជន់និងបើកទឹកឲ្យហូរតាមសម្រួលចុះទៅក្រោម។

សំណល់ស្ពានដែលប្រទះឃើញសព្វថ្ងៃ ស្ថាបនាអំពីថ្មភក់ (ចំពោះស្ពានតូចៗ) ឬថ្មបាយក្រៀម ឬថ្មទាំងពីរប្រភេទចម្រុះគ្នា (ស្ពានធំ)។ គ្រប់ស្ពានមានបាតក្រាលដោយថ្មបាយក្រៀម ដែលមានកម្រាស់ចាប់ពី២ទៅ៣ស្រទាប់ អាស្រ័យទៅតាមទំហំស្ពាន នៅពីលើគ្រឹះបុកបង្ហាប់រួច (របៀបគ្រឹះប្រាសាទ)។ កម្រាលរៀបចេញពីសសរស្ពានចាប់ពី៤ទៅជាង៨ម៉ែត្រ។ ករណីស្ពានតូចៗ កម្រាលក៏មានទំហំខ្លីជាងនេះដែរ។ ស្ពានតូចៗខ្លះប្រើសសរថ្មភក់ក្រៅពីនោះសុទ្ធតែប្រើថ្មបាយក្រៀម។ សសរតែងមានជើងដែលធ្វើពីថ្មប្រភេទដូចគ្នា ចាប់លើកពីលើកម្រាលតែម្ដង។ ជើងសសរមានតម្រៀប ថ្មជាថ្នាក់ៗលយចេញក្រៅ មានពី១ទៅ៤ថ្នាក់បន្តគ្នាទៅតាមទំហំស្ពាន ទាំងនៅដើមទឹកនិងក្រោមទឹក។ នេះជាបច្ចេកទេសបញ្ចៀសកម្លាំងទឹក កុំឲ្យមកប៉ះនឹងគល់ស្ពានផ្ទាល់នៅផ្នែកដើមទឹកព្រមទាំងបន្ថយកម្លាំងទឹកគួចត្រង់គល់ស្ពាននៅផ្នែកក្រោមទឹកវិញ។ សសរស្ពានកោងខិតមកជួបគ្នា ផ្នែកខាងលើបង្កើតជាប្រឡោះឲ្យទឹកហូរ ហើយផ្នែកខាងលើកើតជាខ្នង។ អ្នកស្រុកសៀមរាបហៅប្រឡោះនោះថា "រន្ធត្រដេវ"។ បច្ចេកទេសនេះ ប្រើដូចគ្នានឹងសំណង់ប្រាសាទដែរ។ ពាក្យបច្ចេកទេសភាសាបារាំងហៅថា "arche en encorbellement" (មើលរូបទី១៩)។ បើមើលចំពីមុខឃើញសសរពីរឃ្លាតពីគ្នា គ្របដោយសាជីរាងជាថ្នាក់។



រូបទី១៩ _ ស្ពានខ្វាវ

លំអស្ពាននៅត្រង់បង្កាន់ដៃ។ ស្ពានខ្លះគ្មានបង្កាន់ដៃទេ។ ប៉ុន្តែតែងមានគែមខ្ពស់ ដែលជាតម្រៀបថ្មមួយថ្នាក់ឬពីរតាមបណ្ដោយ។ គែមនោះភាគច្រើនធ្វើអំពីថ្មភក់ ឬជួនកាលធ្វើអំពីថ្មបាយក្រៀម។ ស្ពានខ្លះមានបង្កាន់ដៃ ដែលជាខ្នងនាគទ្រដោយចម្រឹង ហើយចុងបង្កាន់ដៃទាំងពីរមានលំអដោយក្បាលនាគបើកពពែ។ បង្កាន់ដៃមានទាបឬខ្ពស់ អាស្រ័យទៅតាមទំហំស្ពានតូចធំ។ ចម្រឹងមានច ្លាក់ជាក្បាច់ផ្សេងៗ ដូចជាត្របកឈូក, នាគ ឬគ្រុឌ។ បង្កាន់ដៃនោះ តែងមានចម្លាក់ជាស្រកានិងពួរខ្នងនាគ។ បង្កាន់ដៃនិងចម្រឹងភាគច្រើនសាងពីថ្មភក់ខ្លះទៀត ធ្វើពីថ្មបាយក្រៀម។ រីឯក្បាលនាគមានចាប់ពី៣រហូតដល់៩។ លំអស្ពានមានទម្រង់ដូចគ្នានឹងលំអស្ពានថ្លង់ចូលប្រាសាទ ឬគែមនៃខឿនប្រាសាទខ្លះដែរ។ ឧទាហរណ៍ ដូចជាបង្កាន់ដៃស្ពានហាល, រានហាលនិងក្ការបែននៅអង្គរវត្ត ឬច្រកចូលនិងគែមនៃខឿនបន្ទាយសម្រែឬបាយ័ន្តជាដើម។ ក្រោយមក មានបន្ថែមចម្លាក់ព្រះពុទ្ធនៅពីក្រោមក្បាលនាគបន្ថែម ឲ្យកើតជាព្រះបដិមាព្រះពុទ្ធប្រក់នាគ។ បើសង្កេតលើចម្លាក់រូបព្រះពុទ្ធនោះ មិនមែនទើបឆ្លាក់ថ្មីៗនេះទេ។ គឺទំនងជាឆ្លាក់នៅសម័យកណ្ដាល ពេលព្រះរាជាណាចក្រខ្មែរស្ថិតក្រោមឱវាទព្រះពុទ្ធសាសនាពេញទី។ បង្កាន់ដៃនៃស្ពានខ្លះពុំមានលំអអ្វីទេ ពោលគឺបង្កាន់ដៃធម្មតាដែលមានតែផ្ទាំងថ្ម តម្រៀបជួរគ្នាលើចម្រឹង ធម្មតា ហើយគ្មានចម្លាក់។

ស្ពានមានទំហំផ្សេងៗគ្នា។ ទំហំបណ្ដោយមានចាប់ពី៦,៥០ម៉ែត្រដល់១៤៩ម៉ែត្រ (បណ្ដោយផ្លូវ)។ ទំហំទទឹងមានពី៤ម៉ែត្រដល់១៤,៥០ម៉ែត្រ (គិតតែផ្ទៃប្រើប្រាស់នៃខ្នងស្ពាន) និងរន្ធត្រដេវមានពី៣ដល់៣៤។ កម្ពស់មានប្រមាណពីរឬបីម៉ែត្រឡើងដល់ជាង១០ម៉ែត្រ។ តួស្ពានសាងលយចូលសាច់ថ្នល់ជ្រៅគួរដែរ បើប្រៀបនឹងមាត់ច្រាំង។ ច្រាំងដែលនៅជាប់នឹងគល់ស្ពានទាំងដើមទឹកនិងចុងទឹក សុទ្ធតែរៀបថ្មបាយក្រៀមគ្របការពារពីលើច្រាំងដី ជារាងជណ្ដើរទេរចុះទៅបាតទឹក ហើយសន្ធឹងចេញក្រៅវែងឬខ្លីតាមទំហំស្ពាន។ តាមការសង្កេត ប្រវែងជណ្ដើរនៅគល់ស្ពានប្រហាក់ប្រហែលនឹងប្រវែងសន្ធឹងនៃកម្រាលបាតស្ពាន ចំពោះស្ពានដែលឆ្លងកាត់ផ្លូវទឹកតូច។ រីឯផ្លូវទឹកធំដូចជាស្ទឹងជីក្រែងឬស្ទឹងស្រែងវិញ ប្រវែងជណ្ដើរ

នៅគល់ស្ពានវែងជាងកម្រាល។ ជណ្ដើរនេះប្រើជាមធ្យោបាយការពារទឹកគួចខ្ទង់គល់ស្ពាន។ ជាទូទៅ ផ្ទាំងថ្មប្រើក្នុងសំណង់ស្ពានមានរាងវែងៗ។ ទំហំទទឹងថ្មមានពី៣០ដល់៥០សង់ទីម៉ែត្រ។ ទំហំបណ្ដោយពី១០០ដល់ ២០០សង់ទីម៉ែត្រ ហើយកម្រាស់ពី២៥ទៅ៣០សង់ទីម៉ែត្រ។ កម្រាលស្ពានតម្រៀបថ្មតាមបណ្ដោយទឹក ពោលគឺបើប្រៀបនឹងថ្នល់វាកាត់កែងគ្នា។ រីឯខ្នងស្ពាន គេតម្រៀបថ្មតាមបណ្ដោយថ្នល់។ ចំណែកសសរវិញ គឺតម្រៀបតាមទទឹងនិងបណ្ដោយតរៀងគ្នារហូតក្បាលសសរ។



រូបទី២០ - ស្ពានអណ្ដែត (ចម្លាក់លើថាវខាងត្បូង, បាយ័ន្ត)

រីឯស្ពានសាងអំពីឈើមិនបានសល់មកដល់បច្ចុប្បន្នទេ។ ការស្រាវជ្រាវរបស់លោក Jacques Dumarçay នៅបរិវេណស្ពានថ្ម (ប្រាសាទកែវ) បានប្រទះឃើញស្នាមប្រហោងសសរឈើជាច្រើននៅត្រង់សំណល់ស្ពានថ្មសព្វថ្ងៃ។ លោកលើកសម្មតិកម្មថា សំណល់ស្ពានថ្មសព្វថ្ងៃ ប្រហែលស្ថាបនា នៅស.វ.ទី១៥ ឬទី១៦ ដោយជំនួសស្ពានឈើចាស់ដែលកសាងឡើងក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១[៦៦]។ ម្យ៉ាងទៀត ចម្លាក់បាយ័ន្តនៅថែវខាងក្រៅផ្នែកខាងត្បូង ចុងខាងលិច បង្ហាញស្ពានអណ្ដែតមួយប្រភេទ ដែលស្ថាបនាឡើងដោយបាច់ឫស្សី ឬឈើចងតម្រៀបគ្នាបណ្ដែតទឹក។ យើងឃើញ ក្នុងរូបមានដំរីពីរក្បាលនិងកងទ័ពមួយក្រុមកំពុងឆ្លងកាត់ស្ពាននោះ (សូមមើលរូបទី២០)។

ក្នុងចំណោមបណ្ដាញផ្លូវដែលបរិយាយមកខាងលើ យើងពុំប្រទះឃើញមានស្ពាននៅតាមដងផ្លូវខាងជើង ដែលជាបន្តនៃថ្នល់ទទឹងអង្គរធំទេ។ ពោលគឺមាននៅតាមបណ្ដោយផ្លូវបួនខ្សែទៀត ដូចបានរៀបរាប់ខ្លះៗមកខាងដើម។ ក្រៅពីនេះ មានស្ពានចំនួនប្រាំមិនមាននៅ តាមបណ្ដាញផ្លូវខាងលើ ប៉ុន្តែមាននៅបរិវេណក្បែរៗរាជធានី។ ស្ពានទាំងប្រាំនោះ នៅរាយដូច្នេះ ៖

- ស្ពានថ្មប្រាសាទកែវ (លេខជំរឿនបេតិកភណ្ឌ៤៩១ ដែលតទៅសរសេរត្រឹមតែលេខ) ស្ថិតនៅលើថ្នល់បណ្ដោយថ្ងៃ ដែលចេញពីរាជវាំងមកទល់នឹងថ្នល់បារាយខាងលិច ដោយកាត់តាមមុខខាងជើងប្រាសាទកែវ។
- ស្ពាន (៥២២.០៤) កាត់ស្ទឹងសៀមរាប ដែលនៅចន្លោះរវាងទំនប់ខាងជើងនៃថ្នល់បារាយ និងថ្នល់ខាងត្បូងនៃវាលរាជដាក។
- ស្ពានទ (៥៤៣.០២) ស្ថិតនៅកំណាត់ថ្នល់ពីជ្រុងឦសាននៃថ្នល់បារាយទៅទល់នឹងជើងភ្នំបូក។
- ស្ពានវាលរាជដាក (៥២៨.០២) ស្ថិតនៅខាងត្បូងបន្តិចនៃថ្នល់វាលរាជដាកខាងជើងពោលគឺនៅលើថ្នល់បណ្ដោយពីគោកពោធិមកភ្នំបូក។
- ស្ពានធំ (៦៤០.០១) នៅខាងកើតស្ពានខាងលើ ហើយនៅលើដងថ្នល់បណ្ដោយតែមួយ។ ស្ពានធំឆ្លងកាត់ស្ទឹងសៀមរាប។

ស្ពានដែលនៅលើបណ្ដាញផ្លូវទាំងបួនខ្សែ ដូចមានរាយដូចខាងក្រោម ៖

គ.១.១. នៅលើដងផ្លូវអាគ្នេយ៍នេះ កន្លងមកយើងពុំប្រទះឃើញមានស្ពានថ្មីបន្ថែមទេ។ តាមរបាយការណ៍អភិរក្សអង្គរនាឆ្នាំ១៩២៣ សរសេរដោយលោក Henri Marchal រាយការណ៍ពីស្ពានខ្លះត្រូវលុបបាត់ ដោយការលើកផ្លូវជាតិលេខ៦ពីលើថ្នល់បុរាណ និងការចុះសង្កេតការពង្រឹងស្ពានខ្លះនៅតាមបណ្ដោយផ្លូវនេះ។ បើយើងចែកផ្លូវនេះជាពីរផ្នែក ទីមួយពីរាជធានីយសោធរទៅហរិហរាល័យ (រលួស) ក្នុងចម្ងាយប្រមាណ ១៥គ.ម. មានស្ពានមួយឈ្មោះ “ស្ពានអូរក្អែក” (៥៨៩.០៤)។ ទីពីរ ពីរលួសដល់ទីប្រជុំជនកំពង់ក្ដីនៃស្រុកជីក្រែង ក្នុងចម្ងាយប្រមាណ៥០គ.ម. មានស្ពានតូចធំសារុបចំនួន២២។ ក្នុងចំណោមនេះ ស្ពាននៅត្រង់ទីប្រជុំជនកំពង់ក្ដីដែលឆ្លងកាត់ស្ទឹងជីក្រែង មានទំហំធំជាងគេ[៦៧] ពោលគឺបណ្ដោយ៨៥ម៉ែត្រទទឹង

[៦៦] Dumarçay 1994 : 380; 1998 : 63.

[៦៧] ដូចពោលមកខាងដើមអំពីឈ្មោះស្ពាន ដែលយើងដឹងសព្វថ្ងៃដោយសារអ្នកស្រុកហៅ។ ចំពោះឈ្មោះស្ពាននេះវិញ ដែលវែងជាងគេលើដងផ្លូវនេះវិញ គេហៅផ្សេងៗគ្នាថា “ស្ពានកំពង់ក្ដី”, ឬ“ស្ពានប្រាប់ទិស”។

១៤ម៉ែត្រ (មិនគិតពីទំហំបង្កាន់ដៃ) រន្ធត្រដេវ២១។

តាមរបាយការណ៍អភិរក្សអង្គរនាឆ្នាំ១៩៦៥_៦៨ មានស្ពាន១០ខូចខាតមិនសូវធ្ងន់ធ្ងរ ហើយស្ពាន៩ខូចធន់និងលុបបាត់ក្នុងផ្លូវខ្លះ។ ក្នុងចំណោមនោះមានស្ពាន៣ត្រូវបានជួសជុលស្តារនាកំឡុងឆ្នាំ១៩៦៥_៦៧។

គម្រោងជួសជុលស្តារផ្លូវជាតិលេខ៦ សម្រេចរក្សា និងលើកតម្លៃស្ពានបុរាណនៅលើដងផ្លូវ ដោយងាក ខ្សែផ្លូវវាងមកខាងត្បូងស្ពានបុរាណបន្តិច។ ដូច្នេះផ្លូវជាតិលេខ៦ ដែលជួសជុលស្តាររួចសព្វថ្ងៃបានវាងស្ពានចំនួន១៤ខាងលើ[៦៨]។ រីឯស្ពាននៅប៉ុន្មានទៀតដែលខូចខាតខ្លាំងនៅសល់ស្នាមមើលស្គាល់ខ្លះ, និងស្ពានខ្លះបានលុបបាត់ខ្លះកាលពីលើកផ្លូវនាទសវត្ស១៩២០ ក៏ត្រូវផ្លូវលុបម្ដង ទៀតនាពេលចុងក្រោយនេះ[៦៩]។

គ.១.២. តាមលោក Bruguier មានស្ពានសារុបចំនួន១៨នៅលើដងផ្លូវពីអង្គរទៅបាកាណដោយកាត់តាមប្រាសាទមាលា។ ក្នុងនោះមានស្ពាន១៦នៅតាមដងផ្លូវពីអង្គរទល់នឹងប្រាសាទ បាកាណ ហើយស្ពាន២ទៀតនៅលើកំណាត់ផ្លូវពីមាលាឆ្ពោះទៅកោះកេរ្តិ៍[៧០]។ កន្លងមកនេះ យើងប្រទះឃើញស្ពានពីរទៀត នៅលើកំណាត់ផ្លូវពីអង្គរទៅមាលា។ ទីមួយ នៅខាងលិចស្ពានថ្មស្ទឹងតូច (៥៦៣) ប៉ុន្មានរយម៉ែត្រមានសំណល់ស្ពានមួយ[៧១]។ យើងប្រទះឃើញស្ពាននេះដោយចៃដន្យ តាមរយៈសំណល់ផ្ទាំងថ្មបាយក្រៀមជាច្រើនដុំ ដែលអ្នកស្រុកជីកយកពីរណ្ដៅនៅក្នុងបរិវេណផ្ទះរបស់ខ្លួន (ផ្ទះនេះសង់នៅលើថ្នល់បុរាណ) ដើម្បីយកមកប្រើប្រាស់។ បើពិនិត្យត្រង់រណ្ដៅដែលគេលុងយកថ្ម យើងឃើញសល់ស្នាមផ្ទាំងថ្មនៅតម្រៀបលើគ្នា ដែលជាក្បាលសសរស្ពាន។ ទីពីរ គឺស្ពានដែលនៅខាងលិចកូនស្ពានត្នោតត្រដេវ (២១៣)។ ស្ពាននេះ សព្វថ្ងៃស្ថិតនៅកណ្ដាលចម្ការរបស់អ្នកស្រុក។ អូរដែលហូរកាត់ស្ពានពីដើម បានវាងទៅខាងកើតស្ពាន។ អូរនេះមានឈ្មោះថា "អូរសេះស្លាប់"។ អ្នកស្រុកហៅស្ពាននេះថា "ស្ពានក្មេង" ស្ថិតនៅលើកូអរដោនេភូមិសាស្ត្រ ៤១០៤៣០ ខាងកើត ១៤៨៦២៩១ខាងជើង (តទៅមុខនឹងសរសេរត្រឹមតែលេខកូអរដោនេភូមិសាស្ត្រ)។ ដូច្នេះតាមទិន្នន័យមុននិងក្រោយ យើងប្រទះឃើញមានស្ពានសារុបចំនួន២០នៅតាមបណ្ដោយផ្លូវបេង។

គ.១.៣. កន្លងមកនេះ យើងប្រទះឃើញសំណល់ស្ពាននៅលើដងផ្លូវ ខាងលិចនេះច្រើនជាងមុន (តាមលោក Bruguier មានសំណល់ស្ពាន តែ៩) ហើយនឹងអាចមានច្រើនជាងនេះទៀត ពីព្រោះការស្រាវជ្រាវ តាមបណ្ដោយផ្លូវនេះនៅខ្វះចន្លោះនៅឡើយដោយកន្លែងខ្លះ យើងមិនទាន់ទៅដល់។ ទីតាំងស្ពានដែលនៅចុងគេនៃដងផ្លូវនេះសព្វថ្ងៃ គឺស្ពានរាប[៧២] នៅជ្រុងខាងលិចនៃត្រពាំងថ្ម (ស្រុកភ្នំស្រុក)។ ដើម្បីងាយបរិយាយ ខ្ញុំចែកផ្លូវខាងលិចចាប់ពីបារាយទឹកថ្លាទល់នឹងភ្នំស្រុកជាបីកំណាត់ ៖ ទីមួយ ពីបារាយមកទល់នឹងស្ទឹងព្រះស្រុក (ស្រុកពួក)។ ទីពីរ ចាប់ពីស្ទឹងព្រះស្រុកទល់នឹងស្ទឹងស្រែង (ស្រុកក្រឡាញ់) និងទីបីពីស្ទឹងស្រែងទល់នឹងស្ទឹងភ្នំស្រុក (ត្រពាំងថ្ម)។ កំណាត់ទីមួយនេះ បើរាប់ពីដើមផ្លូវមកមានស្ពានសារុបបី ៖ ស្ពានមេម៉ាយ ឬស្ពានថ្ម (៥៩៥), ស្ពានរលុះនៅខាងកើតកំពែងព្រះស្រុកពីរបីរយម៉ែត្រដែលគ្មានក្នុងបញ្ជីបេតិកភណ្ឌចាស់ដូចពោលមកខាងដើម ព្រមទាំងស្ពានស្ទឹងព្រះស្រុក(៣៦០៣៣៤, ១៤៨៩១០៤) ។ សព្វថ្ងៃស្ពាននេះ(៦៥៣)ខូចខាតធ្ងន់ធ្ងរណាស់ ដែលយើងអាចពិនិត្យឃើញថាមានបណ្ដោយប្រហែល៣៣ម៉ែត្រទទឹង៩,៥០ម៉ែត្រ។ ដោយស្ពានបាក់បែកខ្លាំងនិងដីលុបផង យើងមិនអាចរាប់រន្ធត្រដេវដឹងចំនួន។ កំណាត់ទីពីរ ចាប់ពីស្ទឹងព្រះស្រុកដល់ស្ទឹងស្រែង (ស្រុកក្រឡាញ់)។ នៅតាមបណ្ដោយកំណាត់នេះមានស្ពានចំនួន១០ ក្នុងចម្ងាយប្រមាណ១៩គ.ម.។ ក្នុងចំណោមស្ពានទាំងនេះមានសំណល់ស្ពាន៦មិនមាន នៅក្នុងបញ្ជីបេតិកភណ្ឌ ចាស់[៧៣]។ បើរាប់តពីស្ទឹងព្រះស្រុកមកសំណល់ស្ពាននៅរាយដូច្នេះ ៖

---

៦៨ ប៉ុន្តែមកទល់សព្វថ្ងៃនេះ ផ្លូវមិនទាន់វាងត្រឹមត្រូវនៅទីតាំងស្ពានពីរ គឺស្ពាននៅភូមិអូរ និងស្ពានព្រះទិស ដោយសារការពាក់ព័ន្ធដល់ដីធ្លីអ្នកស្រុកពុំទាន់ដោះស្រាយហើយ។

៦៩ មុនពេលដំណើរការជួសជុលស្តារផ្លូវជាតិលេខ៦ នាឆ្នាំ១៩៩៩_២០០០ អាជ្ញាធរអប្សរាបានបញ្ជូលបុរាណវិទូមួយក្រុម (លើកទី១) ឲ្យចុះសិក្សានិងធ្វើកំណាយសង្គ្រោះនៅទីតាំងស្ពានដែលប្រទះឃើញតាមបណ្ដោយផ្លូវ។ ស្ពានលុបបាត់ទាំង៨នោះ ក៏ត្រូវបានសិក្សានិងចុះក្នុងរបាយការណ៍ការងាររបស់ខ្លួន (របាយការណ៍ខែវិច្ឆកា ១៩៩៩ និងរបាយការណ៍ លើកទី២ ខែវិច្ឆកា ១៩៩៩ ដល់ មករា ២០០០) ។ លើកទី២ ចុះសិក្សាម្ដងទៀតនៅក្នុងកំឡុងឆ្នាំ ២០០៣_២០០៤។

៧០ Bruguier 2000 : 533.

៧១ កូអរដោនេភូមិសាស្ត្រនៅត្រង់នេះ គឺ ៖ ៣៩០៤៩២ខាងកើត និង ១៤៨៤២៤៨ខាងជើង។ ទិន្នន័យនេះ បានមកពីលោក ហេង សុខា និង លោក ស្រី បារាំង ក្នុងកំឡុងពេលចុះស្រាវជ្រាវ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្របុរាណវិទ្យា (ការងារកំពុងធ្វើ) ព្រមទាំងរបាយការណ៍ស្រាវជ្រាវនៃគម្រោង "Greater Angkor Project" នាខែមករា_កុម្ភៈ ២០០៥។

៧២ សព្វថ្ងៃយើងមើលសំណល់ស្ពានស្ទើរលែងស្គាល់ហើយ ដោយសារគេលុបដីពីលើដូចពោលខាងដើម។ សព្វថ្ងៃមានសំណល់ថ្មបាយក្រៀមខ្លះនៅរាយប៉ាយខាងត្បូងស្ពាន។

៧៣ ទិន្នន័យនេះ បានមកពីលោក ហេង សុខា និង ស្រី បារាំង (មីនា ២០០៥)។

- ចាប់ពីស្ពឹងព្រះស្រុកមកទល់នឹងភូមិចុងថ្នល់ (ទីប្រសប់នៃផ្លូវខាងលិចនិងថ្នល់ភ្ជាប់ពីសសរស្ដម្ភទៅអង្គរជុំនៅខាងជើង) មានសំណល់ស្ពានមិនមានក្នុងបញ្ជីចាស់ចំនួន៥។ ស្ពានទាំង៥នេះគ្មានឈ្មោះអ្វីគួរឲ្យកត់សម្គាល់ទេ ក្រៅពីអ្នកស្រុកហៅ "ស្ពានថ្ម"។ បើរាប់ពីកើតទៅមាន ៖ ស្ពានទីមួយបន្ទាប់ពីស្ពានស្ពឹងព្រះស្រុក (៣៥៧៧៧៣, ១៤៩០៤២៥) ក្នុងភូមិសាស្រ្តភូមិគោកថ្មី ឃុំល្វា ស្រុកពួកមានបណ្ដោយ២២ម៉ែត្រ ទទឹង៤ម៉ែត្រ និងរន្ធត្រដេវ១០។ ស្ពានទីពីរ (៣៥៧០២២, ១៤៩០៩១១) ស្ថិតនៅក្នុងភូមិសាស្រ្តភូមិគោកថ្មី មានបណ្ដោយ៨ម៉ែត្រ ទទឹង៦.៥០ម៉ែត្រនិងរន្ធត្រដេវ៤។ ស្ពានទីបី (៣៥៦៧២៥, ១៤៩១១១២) ស្ថិតនៅក្នុងភូមិគោកថ្មីមានបណ្ដោយប្រហែល១៥ម៉ែត្រ ទទឹងប្រហែល៦ម៉ែត្រ និងរន្ធត្រដេវ៧។ ស្ពានទីបួន (៣៥៦៥១៨, ១៤៩១២៤៩) មានចម្ងាយប្រហែល២០០ម៉ែត្រពីស្ពានទីបី និងនៅខាងកើតវត្តប្រាសាទប្រមាណកន្លះគីឡូម៉ែត្រ។ ស្ពាននេះមានបណ្ដោយប្រហែល១៤ម៉ែត្រ ទទឹង៤ម៉ែត្រ និងរន្ធត្រដេវ៣។ ស្ពានទីប្រាំ (៣៥៣៧៦១, ១៤៩៣២៦៧) នៅចម្ងាយ ប្រហែល៥គ.ម. ពីទីប្រសប់ថ្នល់នៃភូមិចុងថ្នល់ និងវត្តយាង ក្នុងភូមិគោកជ្រៃ ឃុំសសរស្ដម្ភ ស្រុកពួក។ ស្ពាននេះមាន បណ្ដោយ១៣ម៉ែត្រ ទទឹង៥ម៉ែត្រ រន្ធត្រដេវ៦ (មើលរូបទី១៦)។

- ចាប់ពីភូមិចុងថ្នល់ទល់នឹងស្ពានស្ពឹងស្រែង មានសំណល់ស្ពានចំនួន៥ ដែលក្នុងនោះមានស្ពានថ្មីមួយ។ ស្ពាននេះហៅស្ពានរលុះ នៅក្នុងភូមិចុងថ្នល់ចម្ងាយប្រមាណមួយគីឡូម៉ែត្រពីទីប្រសប់ថ្នល់ខាងលើ។ ស្ពានរលុះ (៣៤៨៣១៨, ១៤៩៨៦១៧) មានបណ្ដោយ២២ម៉ែត្រ ទទឹងប្រមាណ ៨,៥០ម៉ែត្ររន្ធត្រដេវ១០។ ក្រៅពីនេះជាស្ពានមានក្នុងបញ្ជីបេតិកភណ្ឌរួចហើយ ដូចមានស្ពានរលំអំពិល[៧៤] (៦៥២), ស្ពានមេម៉ាយ (៦៥១), ស្ពានរលំស្វាយ (៦៧៣) និងស្ពានស្រែង (៦៧២)។ កំណាត់ទីបី ចាប់ពីស្ពឹងស្រែងទៅទល់នឹងត្រពាំងថ្ម (ស្រុកភ្នំស្រុក)។ កំណាត់នេះ បើយោងតាមលោក Lunet de Lajonquière ថាមានសំណល់ស្ពានចំនួន១០។ គឺនៅចន្លោះពីស្ពានស្រែងនិងស្ពានថ្នល់ដាច់ (៧៥៦) ដែលស្ថិតនៅក្នុងស្រុកភ្នំស្រុក មានស្ពានរាយបន្តគ្នាចំនួន៧ក្នុងចម្ងាយប្រហែល១២គ.ម. (គាត់គ្រាន់តែឲ្យជាចំនួនប៉ុណ្ណោះ)[៧៥] ហើយបន្ថែមស្ពានបីទៀតចាប់ពីខាងកើតស្រុកភ្នំស្រុកទៅលិច។ ស្ពានបីចុងក្រោយនេះ បើរាប់ពីកើតទៅលិចមាន ៖ ស្ពានថ្នល់ដាច់ (៧៥៦), ស្ពានដាច់ (៧៦៨) និងស្ពានរាប (៧៦៩)។

ក្នុងចំណោមស្ពានទាំង៧ដូចពោលខាងលើ យើងបានប្រទះឃើញពីរបន្តគ្នាដែលស្ថិតនៅខាងកើតភូមិត្រពាំងប្រី (ក្នុងចម្ងាយរវាង៤គ.ម. ខាងកើតស្រុកភ្នំស្រុក) ហើយដែលអ្នកស្រុកបន្តប្រើរហូតដល់សព្វថ្ងៃ (មើលរូបទី១៦)។ ទីមួយ គឺស្ពានក្មេងធ្វើពីថ្មបាយក្រៀម (៣២៣៩៧៥, ១៥១៨៧៤៨) មានបណ្ដោយជិត៣០ម៉ែត្រ ទទឹងប្រហែល៧ម៉ែត្រនិងមានរន្ធត្រដេវ១២។ ទីពីរ គឺស្ពានធំ (៣២៤៤៧៧, ១៥១៨១៣៨) ធ្វើពីថ្មបាយក្រៀមមានបណ្ដោយ ៦៤ម៉ែត្រ ទទឹង១១ម៉ែត្រនិងរន្ធត្រដេវ១៨[៧៦]។ ស្ថានភាពបច្ចុប្បន្ន ស្ពានក្មេងនៅមាន ទ្រង់ទ្រាយល្អច្រើនជាងគេ។

ដោយរួមទាំងទិន្នន័យចាស់និងថ្មី ស្ពានដែលប្រទះឃើញសព្វថ្ងៃនៅតាមបណ្ដោយផ្លូវខាងលិចមានចំនួន២៣។ ក្នុងចំណោមនេះ ស្ពានដែលវែងជាងគេគឺស្ពានស្រែង។ សព្វថ្ងៃយើងមើលតួស្ពានស្ទើរតែលែងស្គាល់ ដោយសារកាលសម័យកម្ពុជាប្រជាធិបតេយ្យ គេបានលើកដីលុបស្ពានដើម្បីបង្វែរចរន្តទឹកបញ្ចូលទៅក្នុងត្រពាំងថ្ម។ សំណល់ខ្លះដែលអាចមើលឃើញមានបំណែកក្បាលនាគមួយនៃបង្កាន់ដៃខាងត្បូងនៅគល់ស្ពានខាងលិច, ស្នាមជណ្ដើរថ្មការពារច្រាំងគល់ស្ពានខាងលិច មុខខាងជើង ព្រមទាំងស្នាមកម្រាលខ្នងស្ពានពីរបីកន្លែងលេចចេញពេលទឹកហូរច្រោះ។ មានខ្ទមអ្នកតាពីរនៅក្បាលស្ពានទាំងពីរ។ ខាងកើតជាខ្ទម "អ្នកតាជ័យ" ដែលតំណាងដោយរូបស្នងប្រុសមួយ ដែលកាន់កាំភ្លើងវែងមួយដើម ព្រមទាំងមានបំណែកថ្មចម្លាក់ស្ពានជាច្រើនទៀតនៅក្នុងរោងជាមួយគ្នា។ ខាងលិចជាខ្ទម "យាយតី" ដែលមានរូបស្នងស្រីនិងបំណែកជើងទម្របង្កាន់ដៃ។ នៅជាប់ខាងកើតខ្ទមយាយតី មានសាលាសំណាក់ឈើមួយធំល្មម លើកខ្ពស់ផុតពីដីខ្នងស្ពាន។ បើតាមកំណត់ត្រារបស់លោក Lunet de Lajonquière ថាស្ពាននេះមាន ប្រវែង១៣៦ម៉ែត្រ ទទឹង១៤,៥០ម៉ែត្រនិងរន្ធត្រដេវ៣៤[៧៧]។

ស្ពានបីចុងក្រោយនៅស្រុកភ្នំស្រុក គឺស្ពានថ្នល់ដាច់, ស្ពានដាច់ និងស្ពានរាប មានវាសនាមិនខុសពីស្ពានស្ពឹងស្រែងដែរ។ សព្វថ្ងៃមានតែស្ពានថ្នល់ដាច់ទេ (៣១៦៩៩៥, ១៥២៤៤០៥) ដែលនៅសំណល់រចនាសម្ព័ន្ធច្រើនជាងគេ។ ចំហៀងខាងត្បូងនៅមើលឃើញរន្ធត្រដេវ និងបង្កាន់ដៃថ្មបាយក្រៀមនិងក្បាលនាគដែលធ្វើពីថ្មបាយក្រៀមដែរ នៅសល់តែចំហៀងខាងជើង (មើលរូបទី២១)។ ស្ពាននេះមានបណ្ដោយប្រហែល៨២ម៉ែត្រ

---

[៧៤] ឈ្មោះនេះ លោក Lunet de Lajonquière សរសេរថា "Rolom Pil"។ ខ្ញុំយល់ថាឈ្មោះនេះ គួរតែសរសេរដូច្នេះ "រលំអំពិល"។

[៧៥] Lunet de Lajonquière 1911 : 365-366.

[៧៦] ទិន្នន័យនេះផ្ដល់ដោយលោក ហេង សុខា និង ស្រី បារាំង។

[៧៧] Lunet de Lajonquière 1911 : 323-324.

ទទឹង៩ម៉ែត្រ និងរន្ធត្រដេវ២៣។ ស្ពានដាច់ (៣២១៥៨៧, ១៥២១១០៤) មើលលែងស្ទើរលែងស្គាល់ ដោយសារសម័យកម្ពុជាប្រជាធិបតេយ្យ គេរើយកថ្មទៅស្ថាបនាស្ពានបីទៀតដែលនៅក្បែរៗនោះ (តាមដំណាលនគរបាលឃុំភ្នំដីដែលមានការិយាល័យនៅខាងកើតស្ពាន)។ ស្ពានរាប (៣១៣៩២៦, ១៥២៥៣៤៤) សព្វថ្ងៃមើលលែងស្គាល់ហើយ គឺគេលុបទាំងស្រុងដោយសារការសាងទំនប់អាងទឹកត្រពាំងថ្ម។ គេបន្ថែមកម្រាលថ្មគ្រុបពីលើមុខខាងជើងមួយជាន់ទៀតដើម្បីការពារកម្លាំងទឹកបុកមកប្រាំងទំនប់ (មើលរូបទី២២)។ មុខខាងត្បូង នៅសំណល់ថ្មបាយក្រៀមខ្លះ។



រូបទី២១ _ ស្ពានថ្នល់ដាច់



រូបទី២២ _ ស្ពានរាប

គ.១.៤. សព្វថ្ងៃយើងប្រទះឃើញស្ពាននៅតាមបណ្តោយផ្លូវពាយ័ព្យចំនួនសារុប២២ ដែលក្នុងនោះ ស្ពានចុះក្នុងបញ្ជីចាស់មានតែចំនួន១៦។ ដូចពោលមកខាងដើម ផ្លូវនេះឆ្លងកាត់ខេត្តពីរនិងស្រុកប្រាំមួយ ដែលស្ពាននៅរាយមកខាងក្រោម ៖

- ស្រុកសៀមរាបគ្មានសំណល់ស្ពានថ្មទេ។
- ស្រុកអង្គរធំមានស្ពានពីរ គឺស្ពានថ្មប្រាសាទសំពៅ (៦១១) និងស្ពានថ្កែកូន (៦២៦)។
- ស្រុកអង្គរជុំមានស្ពាន៩ ដែលស្ពាន៦គ្មានក្នុងបញ្ជីចាស់[៧៨]។ ស្ពានទាំង៦នោះ នៅរាយបន្តជាប់ៗគ្នា។ បើរាប់ពីដើមផ្លូវមាន ៖ ទីមួយ ស្ពានភ្ជាក់ដៃ (១០៣°៤៥.២៤៣, ១៣°៣៨.០២២) មានបណ្តោយ៣០ម៉ែត្រ ទទឹង១២ម៉ែត្រ និងរន្ធត្រដេវ១១។ ទីពីរ ស្ពានថ្ម (១០៣°៤៤.៦១៥, ១៣°៣៨.៥៦៣) មានបណ្តោយ១៥ម៉ែត្រ ទទឹង១១ម៉ែត្រ និងរន្ធត្រដេវ៦។ ទីបី ស្ពានភូមិស្ពាន (១០៣°៤៤.០១៦, ១៣°៣៩.០៧៥) មានបណ្តោយ២០ម៉ែត្រ ទទឹង៩ម៉ែត្រ និងរន្ធត្រដេវ៨។ ទីបួន ស្ពានថ្មភូមិស្ពាន (១០៣°៤២.៦១០, ១៣°៣៩.៤២៩) មានបណ្តោយ១៥ម៉ែត្រ ទទឹង៨ម៉ែត្រ។ ដោយស្ពានខូចខាតច្រើន យើងមិនដឹងថារន្ធត្រដេវមានប៉ុន្មាន។ ទីប្រាំ ស្ពានព្រៃស្ពាន (១០៣°៤២.៦៣៧, ១៣°៤០.២៦២) យើងមិនដឹងពីទំហំស្ពានពិតប្រាកដ ដោយសារដីលុបស្ពានស្ទើរទាំងស្រុង។ ទីប្រាំមួយ ស្ពានថ្មវត្តស្វាយ មានបណ្តោយ២០ម៉ែត្រ ទទឹង១០ម៉ែត្រ នៅខាងកើតវត្តស្វាយចម្ងាយប្រហែល១គ.ម. (យើងមានត្រឹមតែពត៌មានដូច្នេះ)។ ស្ពានបីចុងក្រោយ គឺស្ពានតម្រង់ (៦៨៤), ស្ពានតាកើម (៦៨៥) និងស្ពានត្នោត (៦៨៦)។
- ស្រុកស្រីស្នំមានស្ពាន៧ បានចុះក្នុងបញ្ជីបេតិកភណ្ឌរួចហើយ ដែលនៅរាយគ្នាដូច្នេះ ៖ ស្ពានព្រះចង្អេរ (៦៨៧), ស្ពានក្របៅ[៧៩] (៧១៣), ស្ពានស្វែង (៧១៤), ស្ពានពោធិ (៧១៥), ស្ពានក្មេង (៧១៦) និងស្ពានមេម៉ាយ (៧១៧)។
- ស្រុកចុងកល្បនិងសំរោងមានស្ពាន៥ បានចុះក្នុងបញ្ជីបេតិកភណ្ឌរួចហើយដែលនៅរាយគ្នាដូច្នេះ ៖ ស្ពានយាង (៧១៨), ស្ពានទ័ព (៧១៩),

---

[៧៨] Khut 2003 : 66-69.

[៧៩] ឈ្មោះនេះហៅតាមអ្នកស្រុក។ លោក Lunet de Lajonquière សរសេរថា "Krabon"។

ស្ពានត្បូង (៧២០) ស្ពានអូរធ្លក (៧៣៩) និង ស្ពានក្មេង (៧២៤)។

ស្ពានទ័ពជាស្ពានវែងជាងគេបង្អស់ក្នុងចំណោមស្ពានដែលនៅលើដងផ្លូវនេះ និងវែងជាងគ្រប់ស្ពានដែលប្រទះឃើញសព្វថ្ងៃ (មើលរូបទី២៣)។ ស្ពាននេះមានបណ្តោយ១៤៩ម៉ែត្រ ទទឹង១៤,៥០ម៉ែត្រ និងរន្ធត្រដេវ២៥។ ស្ពានស្ថាបនាពីថ្មបាយក្រៀមស្ទើរទាំងអស់ លើកលែងតែបង្កាន់ដៃនាគនិងជើងទម្រធ្វើអំពីថ្មភក់។ សព្វថ្ងៃបង្កាន់ដៃនាគនិងជើងទម្រនៅសល់តែបំណែកខ្លះៗប៉ុណ្ណោះ។ រីឯក្បាលនាគវិញបាត់សូន្យហើយ។ សសរស្ពានខ្លះសឹករិចរិលខ្លាំង ដែលនឹងអាចដួលរលំដោយផ្នែកៗ។ ស្ពាននៅប្រើប្រាស់ពេញបន្ទុកដល់សព្វថ្ងៃ។ នៅពេលជួសជុលស្ពារផ្លូវជាតិលេខ៦៨ គេបានលុបដីក្រហមពីលើកម្រាលថ្មនៃខ្នងស្ពានទាំងស្រុង ។



រូបទី២៣ _ ស្ពានទ័ព

សារុបមក ចំនួនស្ពានដែលប្រទះឃើញបន្តបន្ទាប់កន្លងមកកើនម្តងបន្តិចៗដូចតទៅ ៖

- លោក Aymonier បានប្រទះឃើញមានចំនួន២០។
- លោក Lunet de Lajonquière បានប្រទះឃើញចំនួន៣៨។
- លោក G. Groslier ថា គេប្រទះឃើញសំណល់ស្ពានប្រមាណ ជាង៥០[៨០]។
- លោក Bruguier នៅឆ្នាំ២០០០ ថាមានចំនួន៧២។
- ការស្រាវជ្រាវរបស់ខ្ញុំ រួមជាមួយនិស្សិតបុរាណវិទ្យាដែលធ្វើការស្រាវជ្រាវក្រោមការដឹកនាំរបស់ខ្ញុំកន្លងមកនៅលើទឹកដីសៀមរាបជាពិសេស ហើយនិងនៅតាមខេត្តខណ្ឌខាងលិចសៀមរាប ព្រមទាំងផ្អែកលើទិន្នន័យចាស់ផងនោះ ឃើញថាមានសំណល់ស្ពានសារុបចំនួន៩៣។ ចំនួនស្ពានអាចនឹងប្រទះឃើញ ច្រើនជាងនេះទៅទៀត កាលណាគ្រោះថ្នាក់មីននឹងថយចុះ។

គ.២. "សាលាសំណាក់"

យើងដឹងថា អាស្រមប្រមាណ១០០នៅក្នុងព្រះរាជាណាចក្រសម័យអង្គរ ស្ថាបនាដោយព្រះបាទយសោវរ្ម័ន។ អាស្រមទាំងនោះ កសាងនៅក្បែរៗប្រាសាទចាស់ ដែលស្ថាបនាក្នុងរាជ្យមុន ឬក្បែរបូជនីយដ្ឋានសំខាន់ៗ។ ព្រះបាទជ័យវរ្ម័នទី៧ ស្ថាបនា "សាលាសំណាក់" ដែលមានឈ្មោះដើម ជាភាសាសំស្ក្រិតថា "អគ្និគ្រិហ"[៨១] នៅរាយតាមបណ្តោយផ្លូវចេញ ពីរាជធានីអង្គរទៅកាន់មណ្ឌលផ្សេងៗក្នុងព្រះរាជាណាចក្រ។

ស្លោកទី១២២ដល់ទី១២៦នៃសិលាចារិកព្រះខ័ន[៨២] រៀបរាប់អគ្និគ្រិហចំនួន១២១ស្ថាបនានៅតាមដងផ្លូវព្រមទាំងនៅក្នុងបូជនីយដ្ឋានធំៗខ្លះនៃព្រះរាជាណាចក្រ។ ក្នុងចំណោមនោះ មានអគ្និគ្រិហចំនួន៥៧នៅតាមបណ្តោយផ្លូវ ដែលចេញពីរាជធានីអង្គរទៅកាន់បុរីមួយនៅស្រុកចម្ប៉ា[៨៣], ចំនួន១៧ ស្ថាបនានៅតាមដងផ្លូវពីអង្គរទៅភិម័យ, ចំនួន៤៤ ស្ថាបនានៅតាមបណ្តោយផ្លូវវង់មួយខ្សែ ដែលចេញពីអង្គររួចត្រឡប់ចូលអង្គរវិញ គឺ "យសោធរបុរ_ជ័យវតី_ជ័យសិង្ហវតី_ជ័យវីរវតី_ជ័យរាជគិរិ_ស្រីសុវីរបុរី_យសោធរបុរ" (យើងមិនទាន់ដឹងថាបុរីទាំងនេះ នៅឯណានៅឡើយ)។ ក្រៅពីនេះ មានអគ្និគ្រិហមួយស្ថិតនៅក្នុងបរិវេណភ្នំជីសូរ្យ (ប៉ុន្តែបើតាមពិនិត្យជាក់ស្តែង យើងពុំឃើញមានសំណង់ដូច្នេះនៅទីនោះទេ) និងពីរទៀតនៅ "ស្រីវិជ័យាទិត្យបុរ" និង "កល្យាណសិទ្ធិក" (យើងក៏មិនទាន់ស្គាល់ទីកន្លែងនៅឯណានៅដែរ)។

---

៨០ Groslier 1921 : 96.

៨១ ប្រែថា "ផ្ទះដែលមានភ្លើង"។

៨២ Cœdès 1941 : 255-302.

៨៣ យើងមិនទាន់ស្គាល់នៅឡើយថាក្រុងចម្ប៉ាមួយណានៅឡើយ បើតាមស្លោកទី១៦៦ នៃសិលាចារិកព្រះខ័នថា ប្រទេសចម្ប៉ាជំនាន់នោះ បែងចែកជាអាណាចក្រពីរ ដែលមានបុរី "វិជ័យ" និង "បាន្ទុរង្គ" ជាមណ្ឌល។ បើគិតជាចម្ងាយត្រង់ បុរីទាំងពីរមានប្រវែងស្មើគ្នាបើប្រៀបពីអង្គរ។

យើងឃើញសំណល់អគ្គិគ្រិហដូចពោលមកខាងលើ ជាសំណល់នៃសំណង់ប្រាសាទប៉ុណ្ណោះ។ លោកLunet de Lajonquière ធ្វើចំណាត់ថ្នាក់ប្រភេទសំណង់នេះ ដែលប្រទះឃើញក្នុងវេលាចុះបញ្ជីបេតិកភណ្ឌ ជាប្រភេទប្រាសាទ "ទ័ពជ័យ"[៨៤]។ បន្ទាប់មក លោក A. Foucher ហៅសំណង់នេះជាលើកទីមួយជាភាសាបារាំងថា " gîtes d'étapes" ដែលប្រែជាភាសាជាតិថា "សាលាសំណាក់" [៨៥]។ អគ្គិគ្រិហបានត្រូវប្រែជាភាសាបារាំងថា "maisons avec du feu"។ ដើម្បីងាយស្រួលចំពោះអ្នកស្រាវជ្រាវ ក្នុងសំណេរផ្សេងៗ លោក Louis Finot ស្នើឲ្យហៅថា "Dharmaçālā" *(ធម៌សាលា)* វិញ[៨៦]។ ក្រោយមកលោក Cœdès បានសរសេរអត្ថបទខ្លីមួយទៀត ដោយបង្ហាញពីស្ថាបត្យកម្មនិងតួនាទីនៃអគ្គិគ្រិហព្រមទាំងស្ថានភាពបច្ចុប្បន្ននៃសំណង់[៨៧]។ ប្រពៃណីស្ថាបនាអាគារដែលមានទំហំតូចធំនៅតាមដងផ្លូវសម្រាប់ប្រើប្រាស់ជាសាធារណៈនោះ មិនទាន់បាត់បង់នៅឡើយទេ។ សំណង់នោះ តែងហៅដោយខ្លីថា "សាលាសំណាក់" ជួនកាលថាត្រឹមតែ "សាលា" សម្រាប់អ្នកដំណើរឆ្លងកាត់សម្រាកហើយនិងអ្នកស្រុករៀបចំពិធីផ្សេងៗ។

ដូចបានពោលខ្លះៗ មកខាងដើមថា ក្នុងបណ្ដារបណ្ដាញផ្លូវខាងលើ យើងប្រទះឃើញសាលាសំណាក់នៅលើតែតាមដងផ្លូវពីរខ្សែ គឺផ្លូវបេងនិងផ្លូវពាយ័ព្យ ព្រមទាំងនៅក្នុងបរិវេណប្រាសាទធំៗមួយចំនួន។ សាលាសំណាក់ដែលស្ថាបនានៅក្នុងបរិវេណប្រាសាទតែងស្ថិតនៅខាងកើតក្នុងបរិវេណកំពែងហើយនៅខាងជើងផ្លូវបណ្ដោយថ្ងៃនៃប្រាសាទ។ របៀបដូច្នេះ ឃើញមាននៅរាជធានីអង្គរមានប្រាសាទព្រះខ័ននិងតាព្រហ្ម។ នៅខាងកើតអង្គរមានប្រាសាទមាលានិងបាកាណ។ នៅខាងលិចអង្គរ មានបន្ទាយឆ្មារ។

តាមបណ្ដោយផ្លូវបេង នៅលើចន្លោះកំណាត់ផ្លូវពីប្រាសាទមាលាទៅបាកាណមានសាលាសំណាក់បី។ ផ្លូវពាយ័ព្យ បើតាមសិលាចារិកប្រាសាទព្រះខ័ន ថាមានសាលាសំណាក់ចំនួនសារុប១៧។ ក្នុងចំនួននេះ មកទល់សព្វថ្ងៃ យើងប្រទះឃើញនៅស្រុកថៃឡង់ដីចំនួន៨ និងនៅក្នុងដីខ្មែរចំនួន៧ *(មើលរូបទី២៤និង២៥)*។ រីឯសាលាសំណាក់ពីរទៀត ដែលលោក Lunet de Lajonquière បរិយាយក្នុងបញ្ជីបេតិកភណ្ឌរបស់លោកនោះ យើងពុំទាន់បានឃើញនៅឡើយ។ ដោយសារសាលាសំណាក់ពីរនោះ ស្ថិតនៅក្នុងតំបន់ដែលគេមិនទាន់ដោះមីនក្នុងស្រុកសំរោង ខេត្តឧត្ដរមានជ័យ។

សព្វថ្ងៃ យើងរកឃើញសាលាសំណាក់បានតែចំនួន២៥នៅឡើយ។ សាលាសំណាក់៨នៅក្នុងស្រុកថៃឡង់ដីបច្ចុប្បន្ន ពោលគឺនៅតាមដងផ្លូវអង្គរ-ភិម័យ ភាគខាងថៃ ព្រមទាំង១៧ទៀតនៅរាយក្នុងស្រុកខ្មែរ ដែលនៅតាមបណ្ដោយផ្លូវបេង, ផ្លូវពាយ័ព្យ ហើយនិងនៅក្នុងបរិវេណប្រាសាទធំៗខ្លះ[៨៨]។

សាលាសំណាក់ដែលយើងឃើញនៅក្នុងបរិវេណប្រាសាទធំៗនិងនៅតាមបណ្ដោយផ្លូវបេង ស្ថាបនាអំពីថ្មភក់។ រីឯសាលាសំណាក់នៅតាមបណ្ដោយផ្លូវពាយ័ព្យ សាងអំពីថ្មបាយក្រៀមនិងគ្រឿងលំអអំពីថ្មភក់។ សំណង់ទាំងអស់មានទ្រង់ទ្រាយតាមលំនាំតែមួយ ពោលគឺមានរាងទ្រវែងចែកជាពីរផ្នែក ដែលខាងមុខជាសាលវែង ព្រមទាំងមានបង្អួចនៅខាងឆ្វេងដៃ បើយើងចូលពីខាងមុខ (លើកលែងប្រាសាទផ្លូ ដែលស្ថិតនៅខាងជើងព្រះខ័ន និងនៅខាងកើតផ្លូវខាងជើង មានបង្អួចនៅជញ្ជាំងទាំងពីរ)។ ចំណែកផ្នែកខាងក្រោយជាតួប៉មតម្កល់បដិមា។ ជាទូទៅ សាលាសំណាក់នៅតាមបណ្ដោយផ្លូវតែងមានស្រះទឹកចំនួនបួន ដែលនៅតាមទិសធៀង ពោលគឺនៅទិសឦសាន, អាគ្នេយ៍, និរតីនិងទិសពាយ័ព្យ។ ទំហំសាលាមានបណ្ដោយពី១៤ ទៅ១៥ម៉ែត្រ និងទទឹងពី៤ទៅ៥ម៉ែត្រ។

សាលាសំណាក់ទំនងជាទំនៀមចាស់ណាស់មកហើយ ដែលស្ថាបនាសម្រាប់បម្រើជាប្រយោជន៍សាធារណៈ។ នាស.វ.ទី១១ ទំនៀមនេះទំនងជាសាយខ្លាំងណាស់ បានជាយើងប្រទះឃើញមានចារលើសិលាចារិកនៅប្រាសាទស្ដុកកក់ធំស្លោកទី១១៩ ដែលខ្ញុំប្រែបន្តពីភាសាបារាំងដូច្នេះ "...ដើម្បីជាប្រយោជន៍សាធារណៈ នៅតាមដងផ្លូវមានស្ថាបនាសាលានិងស្រះទឹកសម្រាប់ជួយសម្រួលដល់អ្នកដំណើរសម្រាកនិងប្រើប្រាស់..."[៨៩]។ ចុងស.វ.ទី១៣ លោក ជីវ តាក្វាន់ បានសរសេរទាក់ទងនឹងសាលាសំណាក់ថា "...នៅតាមដងផ្លូវធំៗ តែងមានសាលាសម្រាប់សម្រាកដូចៗគ្នា ដែលតាំងនៅរាល់កន្លែងឈប់សំចតនិមួយៗ..."[៩០]។ ទីតាំងនៃសាលាសំណាក់ដែលយើងប្រទះឃើញបច្ចុប្បន្ន ស្ថិតនៅឆ្ងាយពីគ្នាក្នុងចន្លោះពី១១ទៅ២០គ.ម. ដែលត្រូវនឹងដំណើរថ្មើរជើងប្រមាណពី៣ទៅ៥ម៉ោង។ នៅក្នុងអគ្គិគ្រិហតែងមានភ្លើងសម្រាប់អ្នកដំណើរប្រើប្រាស់ដើម្បីចម្អិនអាហារជាដើម ព្រមទាំងមានព្រះពោធិសត្វ

---

[៨៤] Lunet de Lajonquière 1902 : L; 1907 : XXXI; 1911 : XXVI.
[៨៥] Foucher 1903 : 79.
[៨៦] Finot 1925 : 417-422.
[៨៧] Cœdès 1940 : 347-249.
[៨៨] *សាលាសំណាក់នៅរាយដូច្នេះ ៖ ក្នុងខេត្តសៀមរាបមានចំនួន១២, ខេត្តព្រះវិហារមាន២, ខេត្តឧត្ដរមានជ័យមាន២, បន្ទាយមានជ័យមាន១។*
[៨៩] Cœdès & Dupont 1943 : 56-134.
[៩០] Pelliot 1951 : 32.




*រូបទី២៤ - សាលាសំណាក់តាមបណ្តោយផ្លូវពីរាជធានីអង្គរទៅភិម័យ (កែសម្រួលពីរូបភាពផ្កាយរណបLandsat ETM)*



*រូបទី២៥ - សាលាសំណាក់ (ប្រាសាទតាមាន់)*

លោកេស្វរតម្កល់នៅខាងក្នុងសម្រាប់ជាទីគោរពបូជាផង។ នៅលើហោជាងក៏តែងមានចម្លាក់ព្រះពោធិសត្វលោកេស្វរដែរ។ ដូច្នេះអ្នកដំណើរអាចប្រារព្ធពិធី ផ្សេងៗទៅតាមប្រក្រតីទិននៅក្នុងអគ្គិគ្រិហ ព្រមទាំងអាចចៀសផុតពីគ្រោះថ្នាក់ផ្សេងៗ ក៏ថាបាន ដោយបានការគាំពារពីព្រះ ដែលតម្កល់នៅទីនោះ។

យើងឃើញមានរឿងស្រដៀងគ្នានេះ នៅលើចម្លាក់ក្រឡោតទាបនៅប្រាសាទបាយ័ន្ត។ រឿងនោះឆ្លាក់នៅលើជញ្ជាំងថែវខាងក្រៅ ផ្នែកខាងត្បូងចុងខាងកើត។ អ្នកដំណើរបីនាក់កំពុងសម្រាកក្នុងសាលាមួយដែលទំនងជាហត់ខ្លាំង ម្នាក់ទ្រោបលើកញ្ជើឥវ៉ាន់និងពីរនាក់ផ្អែកខ្នងនឹងជញ្ជាំងសាលា។ នៅខាងឆ្វេងដៃ អ្នកដំណើរមួយក្រុមទៀតរៀបបន្តដំណើរទៅមុខទៀត ដោយប្រុងលើកអម្រែកឥវ៉ាន់ ហើយងាកមើលមកអ្នកទើបនឹងមកដល់ថ្មី។ នៅខាងស្តាំអ្នកដំណើរម្នាក់កំពុងចម្អិនអាហារ ដែលទំនងកំពុងដាំបាយនិងមានត្រីអាំងមួយតំបុតផង (មើលរូបទី២៦)។

គ.៣. “មន្ទីរពេទ្យ”

ស្លោកទី១១៧នៃសិលាចារិកនៅប្រាសាទតាព្រហ្ម លើកបរិយាយពីសមិទ្ធិសំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧ ចំពោះវិស័យសង្គមកិច្ច។ សមិទ្ធិនោះគឺ ការស្ថាបនាមន្ទីរពេទ្យចំនួន១០២ នៅតាមមណ្ឌលនានានៃព្រះរាជាណាចក្រនាឆ្នាំ១១៨៦[៩១]។ ស្លោកបន្តមកទៀត ពីទី១១៨ដល់ទី១៤០ បរិយាយយ៉ាងលំអិតអំពីចំណាយជាវត្ថុ (គ្រឿងឧបភោគបរិភោគ) សម្រាប់ប្រើប្រាស់និងដំណើរការក្នុងមន្ទីរពេទ្យ។ លើសពីនេះ មន្ទីរពេទ្យនិមួយៗមានតម្កល់សិលាចារិក ដែលចារសេចក្តីដូចគ្នាទាំងអស់ ពោលគឺ “លក្ខន្តិក:” នៃមន្ទីរផ្ទាល់។

សំណល់ដែលយើងឃើញសព្វថ្ងៃជាប្រាសាទ ដែលស្ថាបនានៅក្នុងបរិវេណនៃមន្ទីរពេទ្យ។ ពោលគឺជាកន្លែងសម្រាប់បន់ស្រន់។ សិលាចារិកដែលពាក់ព័ន្ធសុទ្ធសឹងជាសំស្ក្រិត ដែលហៅអាគារសម្រាប់បន់ស្រន់នោះថា “អរោគ្យសាលា”។ ដូច្នេះ ដើម្បីនឹងសម្គាល់ព្រមទាំងងាយស្រួលក្នុងសំណេរផ្សេងៗ ខ្ញុំសូមស្នើរហៅប្រាសាទប្រភេទនោះថា “ហោបន់ស្រន់នៃមន្ទីរពេទ្យ”។ យើងដឹងថាមន្ទីរពេទ្យមិនមែនសាងអំពីថ្មទេ គឺកសាងអំពីគ្រឿងសំណង់ស្រាល (មានឈើ, ក្បឿងជាដើម)។ រីហោបន់ស្រន់វិញសាងអំពីថ្ម។ ហោបន់ស្រន់មានទ្រង់ទ្រាយស្ថាបត្យកម្មដូចៗគ្នា ពាត់ដោយកំពែងជុំវិញ ហើយមានច្រកចូលតាមក្លោងទ្វារខាងកើតតែមួយ។ តួប៉មនៅកណ្តាលមួយបែរមុខទៅកើតភ្ជាប់ដោយយ៉មួយ។ កូនប្រាសាទមួយនៅអាគ្នេយ៍ដែលមានយ៉មួយដែរ បែរមុខមកតួប៉មកណ្តាល។ នៅខាងក្រៅកំពែងមានស្រះទឹកមួយនៅឦសាន។ ហោបន់ស្រន់នៃមន្ទីរពេទ្យ ជួនកាលស្ថាបនាអំពីថ្មភក់ឬថ្មបាយក្រៀម។ កំពែងតែងធ្វើអំពីថ្មបាយក្រៀម (មើលរូបទី២៧)។ ព្រះបដិមាដែលតម្កល់នៅក្នុងតួប៉មកណ្តាល ជាព្រះពោធិសត្វបីព្រះអង្គ។ ព្រះបដិមាដែលសំខាន់ជាងគេ គឺព្រះពុទ្ធ “ភៃសជ្យគុរុ” (ប្រែថា “គ្រូថ្នាំ”)។



រូបទី២៦ _សាលាសំណាក់ (ចម្លាក់នៅថែវខាងត្បូង, បាយ័ន្ត)



រូបទី២៧ _ ហោបន់ស្រន់នៃមន្ទីរពេទ្យ (ប្រាសាទតាមាន់តូច)

[៩១] Cœdès 1906 : 44-82.

យោងតាមតួលេខចាស់[៩២] យើងមានហោបទ់ស្រន់នៃមន្ទីរពេទ្យចំនួន៣៣។ ក្នុងចំណោមនោះ មាន១៨នៅក្នុងទឹកដីខ្មែរនិង ១៥ នៅក្នុងដីថៃឡង់ដ៍បច្ចុប្បន្ន។ នៅអង្គរមានសំណង់នៃហោបទ់ស្រន់ចំនួន៥ ដែលបួនស្ថិតនៅក្រៅក្រុងអង្គរធំ ក្បែរច្រកចូលក្រុងទាំងបួន។ ខាងកើតឈ្មោះប្រាសាទ "តាព្រហ្មកិល" នៅខាងឆ្វេងដៃ បើយើងចូលក្រុងតាមក្លោងទ្វារជ័យ (ប្រាសាទនេះស្ថិតនៅខាងលិចប្រាសាទកែវ)។ ខាងលិច ឈ្មោះប្រាសាទ "ទ្រមូង" នៅខាងឆ្វេងដៃ បើយើងចូលក្រុងតាមក្លោងទ្វារតាកាវ។ ខាងត្បូង ឈ្មោះ "តាព្រហ្មកិល" នៅទល់មុខកសិណអង្គរវត្ត ខាងជើងត្រពាំងសេះ ហើយក៏នៅខាងឆ្វេងដៃដែរ បើយើងចូលក្រុងតាមក្លោងទ្វារទន្លេអុំ ព្រមទាំងចុងក្រោយនៅខាងជើង ឈ្មោះប្រាសាទ "ទន្លេស្ងួត" ស្ថិតនៅខាងស្តាំដៃ បើយើងចូលក្រុងតាមក្លោងទ្វារដីឆ្នាំង។ រីឯទីប្រាំ ស្ថិតនៅខាងជើងប្រាសាទព្រះខ័ន នោះគឺប្រាសាទប្រី។

ចំពោះសំណង់នៅក្បែរៗបណ្តាញផ្លូវវិញ យើងពុំប្រទះឃើញសំណល់នៃប្រាសាទនេះនៅតាមខ្សែផ្លូវខាងលិចនិងផ្លូវខាងជើងទេ។ ប៉ុន្តែយើងឃើញមានខ្លះៗនៅក្បែរបណ្តាញផ្លូវបីខ្សែទៀត។ ដោយកន្លងមកនេះ យើងពុំទាន់មានទិន្នន័យថ្មីបន្ថែមនៅឡើយ ដូច្នេះខ្ញុំសូមលើកការបរិយាយអ្វីដែលមានមក។ តាមបណ្តោយខ្សែផ្លូវអាគ្នេយ៍ យើងឃើញមានសំណល់នៃហោបទ់ស្រន់ចំនួនពីរ ដែលទីមួយនៅក្នុងទីប្រជុំជនកំពង់ក្តីខាងកើតស្ពានព្រះទិសនិងខាងជើងថ្នល់ (សូមមើលខាងលើ)។ ទីពីរ គឺគុករកានៅស្រយ៉ូវ ខេត្តកំពង់ធំ។ តាមបណ្តោយផ្លូវបេង យើងប្រទះឃើញតែមួយដែលនៅក្នុងបរិវេណប្រាសាទមាលា គឺប្រាសាទដូនច័ន្ទ (២១៥)។ រីឯផ្លូវអង្គរទៅភិម័យវិញ មានប្រមាណ៥ ដែលមួយប្រទះឃើញក្នុងទឹកដីខ្មែរ គឺប្រាសាទតាកើមធំ (៦៨២) ស្ថិតនៅក្នុងភូមិស្រែខ្វាវ ស្រុកអង្គរជុំ ក្បែរស្ពានតាកើម និងបួនទៀតស្ថិតនៅក្នុងដីថៃឡង់ដ៍បច្ចុប្បន្ន។ ហោបទ់ស្រន់នៃមន្ទីរពេទ្យទាំងបួននេះមាន ៖ តាមាន់តូច (៣៧៣)[៩៣] នៅម្តុំព្រំដែន, ពីរទៀតនៅក្បែរប្រាសាទមឿងតាំនិងភ្នំរុង និងមួយទៀតនៅច្រកទ្វារចូលប្រាសាទភិម័យ។

គ.៤. "សំណង់រក្សាទឹក"

ដូចបានលើកមកខាងលើ (សិលាចារិកស្តុកកក់ធំ) តាមបណ្តោយផ្លូវតែងមានស្ថាបនាស្រះទឹកសម្រាប់អ្នកដំណើរប្រើប្រាស់។ ការស្រាវជ្រាវកន្លងមក យើងប្រទះឃើញមានសំណង់ដូច្នេះច្រើនណាស់នៅតាមគ្រប់ដងផ្លូវ ប៉ុន្តែយើងពុំទាន់បានចុះក្នុងបញ្ជីបេតិកភណ្ឌនិងស្រាវជ្រាវឲ្យបានដិតដល់នៅឡើយ។ ខ្ញុំស្នើពាក្យ "សំណង់រក្សាទឹក" សម្រាប់ហៅជាទូទៅនៅក្នុងអត្ថបទនេះ ពីព្រោះសំណង់នេះមានច្រើនប្រភេទ ដូចដែលយើងឮអ្នកស្រុកហៅផ្សេងៗគ្នាមក។ ពាក្យខ្លះ យើងឃើញមានសរសេរក្នុងសិលាចារិកផង។ ពាក្យដែលទាក់ទងនឹងសំណង់រក្សាទឹកដូចមាន "កញ្ចន, ស្រះ, ត្រពាំង, ល្បើក, ខ្នារ, រហាល, រលំ, ទន្លេ" ជាដើម។

សំណង់រក្សាទឹកនេះ ស្ថាបនាឡើងជួននៅខាងឆ្វេងដៃនិងជួននៅខាងស្តាំដៃដែលមានចម្ងាយឃ្លាតពីគ្នាក្នុងរវាងពី៣ទៅ៤គ.ម. ហើយតាំងនៅមិនឆ្ងាយពីថ្នល់ ពោលគឺក្នុងបរិវេណប្រហែល៥០០ម៉ែត្រ។ ជាទូទៅសំណង់នេះមិនស្របនឹងថ្នល់ទេ។ គឺជ្រុងមួយនៃសំណង់ខិតមកប្រជល់នឹងថ្នល់។ ប៉ុន្តែមានសំណង់ខ្លះក៏ស្របនឹងថ្នល់ដែរ។ ភស្តុតាងនៅសល់សព្វថ្ងៃ ខ្លះរីងស្ងួតអស់ ខ្លះក្លាយទៅជាស្រែដែលយើងនៅមើលស្គាល់ដោយសំណល់ទំនប់ឬច្រាំងនៃសំណង់ (មើលរូបទី២៨)។ មួយចំនួនទៀតបន្តប្រើប្រាស់ទល់សព្វថ្ងៃ ហើយតែងមានខ្ទមអ្នកតានៅក្បែរនោះផង (មើលរូបទី២៩)។ ដោយមិនទាន់មានការចុះបញ្ជីត្រឹមត្រូវ យើងគ្រាន់តែដឹងដោយត្រួសៗតាមការស្រាវជ្រាវកន្លងមកថាសំណង់រក្សាទឹកប្រមាណ២០០បានប្រទះឃើញនៅតាមបណ្តោយផ្លូវទាំង៥ខ្សែខាងលើ ដោយគិតសារុបទាំងទំហំតូចធំ[៩៤]។ សំណង់រក្សាទឹកដែលនៅតាមបណ្តោយផ្លូវខាងជើងមានចំនួនប្រមាណជាង២០[៩៥]។ អត្រារបាយសំណង់រក្សាទឹក នៅតាមដងផ្លូវអាគ្នេយ៍ក្នុងរវាងចម្ងាយ៦០គ.ម. ពីអង្គរ មានចំនួនច្រើនជាងគេ។

បណ្តាញផ្លូវសម័យអង្គររៀបចេញពីប្រាសាទភ្នំដែលជាមណ្ឌលនៃរាជធានី, មណ្ឌលនៃព្រះរាជាណាចក្រ ហើយបើនិយាយវែងជាងនេះ គឺភ្នំព្រះសុមេរុនៃចក្រវាឡ។ ប្រាសាទនោះជាស្ថាននៃទេពធំប្រចាំព្រះរាជាណាចក្រនិងជានិមិត្តរូបនៃអំណាចកំពូលរបស់ព្រះរាជា។ ផ្លូវក្នុងរាធានី រៀបតាម

---

[៩២] Cœdès 1940 : 344-347.

[៩៣] ក្រុមតាមាន់មានប្រាសាទបី។ មួយគឺ "ប្រាសាទតាមាន់" ដែលជាសាលាសំណាក់, ទីពីរគឺ "ប្រាសាទតាមាន់តូច", ដែលជាហោបទ់ស្រន់នៃមន្ទីរពេទ្យ, រីឯប្រាសាទដែលហៅថា "តាមាន់ធំ" គឺជាប្រាសាទធំមួយ ដែលប្រហែលជាសាងឡើងនៅស.វ. ទី១១ បែរទៅរកចម្រាក់ភ្នំខាងត្បូង។

[៩៤] ប្រភេទទំហំតូចៗ មានកញ្ចននិងស្រះ (ជួនកាលស្រះក៏មានទំហំធំណាស់ដែរ ដូចជាស្រះស្រង់)។ ទំហំមធ្យមមានត្រពាំង ធំជាងនេះមានល្បើក, រលំ, ទន្លេ, រហាល, បារាយ។ល។

[៩៥] ចំពោះផ្លូវ៤ខ្សែទៀត ដែលមួយខ្សែមានប៉ុន្មាន យើងមិនទាន់ដឹងនៅឡើយ។ ការស្រាវជ្រាវកំពុងបន្ត។

លំនាំនៃខ្សែពីរ ៖ ទទឹងថ្ងៃនិងបណ្តោយថ្ងៃ ដោយចែករាជធានីជាបួនមណ្ឌលធំៗ។ ផ្លូវឆ្ពោះទៅមណ្ឌលផ្សេងៗក្នុងព្រះរាជាណាចក្រ គឺតភ្ជាប់អំពី ផ្លូវបណ្តោយនិងទទឹងថ្ងៃនេះ។



រូបទី២៨ _ សំណង់រក្សាទឹកនៅតាមផ្លូវអាគ្នេយ៍



រូបទី២៩ _ ខ្ទមអ្នកតានៅក្បែរសំណង់រក្សាទឹក តាមផ្លូវអាគ្នេយ៍(ត្រពាំង ដូនហុង)

ផ្លូវលើកខ្ពស់ផុតពីទឹកលិច ហើយរត់នៅលើខ្សែផុតពីតំបន់ទឹកលិចនៃទន្លេសាប។ ជាឧទាហរណ៍ ផ្លូវអាគ្នេយ៍និងផ្លូវខាងលិចសន្ធឹងជាខ្សែប្រៀបជាព្រំប្រទល់ទឹកសាយនៃទន្លេសាប។ រីឯផ្លូវបេងនិងផ្លូវខ្សែពាយ័ព្យក៏ជាផ្លូវលើកខ្ពស់នៅលើវាលរាប ហើយចុះរាបមកវិញ ពេលផ្លូវរត់ចូលកាត់ខ្ពង់រាប។ មួយភាគធំនៃផ្លូវបុរាណព្រមទាំងស្ពាននិងសំណង់រក្សាទឹកខ្លះៗនៅបន្តប្រើមកទល់សព្វថ្ងៃ។ ផ្លូវខ្លះក៏ក្លាយទៅជាផ្លូវជាតិ ខ្លះនៅប្រើជាផ្លូវលំរបស់ខេត្តខណ្ឌ។ ក្នុងចំណោមស្ពានទាំងអស់ មានស្ពានតែបីដែលនៅតាមបណ្តោយផ្លូវអាគ្នេយ៍បានជួសជុលក្នុងទសវត្ស១៩៦០។ អ្នកស្រុកក៏បន្តរស់នៅតាមបណ្តោយផ្លូវ កើតជាសហគមន៍ជាប់ៗតមក ដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនេះដដែល។

សព្វថ្ងៃនេះ ហេដ្ឋារចនាសម្ព័ន្ធដូចពោលមកកំពុងស្ថិតនៅក្នុងស្ថានភាពអន្តរាយដោយកត្តាច្រើនយ៉ាង ហើយចាក់ស្រេះគ្នាខ្លាំងណាស់។ ភាពអន្តរាយនោះមានដូចជាកាប់ពង្រាបផ្លូវវាតយកដីធ្វើជាចម្ការ, ស្រែ, ទីតាំងកងទ័ព, វាលវាយកូនគោលជាដើម។ ខ្លះទៀតកាប់យកដីថ្មលំមកធ្វើផលិតជាឥដ្ឋសម្រាប់អាជីវកម្មផ្ទាល់ខ្លួន។ ស្ពានក៏រងគ្រោះខ្លាំងណាស់ដែរ។ ស្ពានខ្លះត្រូវគេដាក់គ្រាប់ផ្ទុះកំទេចចោលក្នុងសម័យសង្គ្រាម ខ្លះរើយកថ្មមកប្រើប្រាស់ ខ្លះទៀតលុបបំបាត់ពីលើតែម្តង។ សំណង់រក្សាទឹកខ្លះដែលនៅតាមបណ្តោយផ្លូវខ្លះក៏ត្រូវគេលុបដើម្បីយកដីដែរ។ ដូច្នេះបើការគ្រប់គ្រងបេតិកភណ្ឌទៅអនាគត់មិនបានតឹងរឹងទេនោះ ទំហំអន្តរាយនឹងកាន់តែធំឡើងៗ។

ការបរិយាយមកខាងលើនេះ គ្រាន់តែចង់លើកបង្ហាញអំពីស្ថានភាពនៃការស្រាវជ្រាវកន្លងមក ដែលពាក់ព័ន្ធនឹងផ្លូវបុរាណនិងរចនាសម្ព័ន្ធនៅតាមបណ្តោយផ្លូវ។ ទិន្នន័យនៃការស្រាវជ្រាវដែលកំពុងបន្តសព្វថ្ងៃនឹងបន្ថែមចន្លោះខាងលើ ព្រមទាំងពង្រីកចំណេះដឹងបន្តទៀត។ ម្យ៉ាងទៀត អ្វីដែលយើងយល់សព្វថ្ងៃថាដូច្នេះ ទៅអនាគតអាចនឹងខុសក៏សឹងមាន។

# ឯកសារពិគ្រោះ

ពាក្យកាត់

*AA* : *Arts Asiatiques*, Paris.
*AAK* : *Arts et Archéologie Khmers*, revue des recherches sur les arts, les monuments et l'ethonologie du Cambodge depuis les origines jusqu'à nos jours, dirigée par G. Groslier, Paris.
*ASEMI* : *Asie du Sud-Est et Monde Insulindien*, Paris.
*BCAI*, Bulletin de la Commission Archéologique de l'Indochine.
*BEFEO* : *Bulletin de l'École Française d'Extrême-Orient*, Hanoi puis Paris.
*CEDORECK* : Centre de Documentation et de Recherche sur la Civilisation Khmère, Paris.
*CEFEO* : *Cahiers de l'École Française d'Extrême-Orient.*
*EA* : *Études Asiatiques,* Paris.
*IC* : *Inscription du Cambodge*, par G. Cœdès, 8 volumes, Hanoi, Paris 1937-1966.
*JA* : *Journal Asiatique*, Paris.
Publ. EFEO : Publications de l'École Française d'Extrême-Orient, Paris.
*RAA* : *Revues des Arts Asiatiques*, Paris.

Aymonier, E., 1900-1903, *Le Cambodge*, 3 vol., E. Leroux Ed, Paris.

Boisselier, J., 1966, *Le Cambodge*, Picard, Paris.

Boulbet, J., 1979, *Le Phnom Kulèn et sa région*, Publ. EFEO., Paris.

Bruguier, B., 2000, "Les ponts en pierre du Cambodge ancien: aménagement ou contrôle du territoire?", *BEFEO* 87 : 529-551.

Cœdès, G., 1906, "La stèle de Ta Prohm", *BEFEO* VI : 44-82.

– 1908, "Inscription de Bàt Chum", *JA* XII, 10ème série : 213-252.
– 1911, "Les bas-reliefs d'Angkor Vat", *BCAI* : 170-220.

– 1932, , " A la recherche du Yaçodharāçrama", *BEFEO* XXXII : 84-112.

– 1940, "Les hôpitaux de Jayavarman VII", *BEFEO* XL : 344-347.

– 1940, "Les gîtes d'étape à la fin du XIIe siècle", *BEFEO* XL : 347-349.

– 1941, "La stèle du Práh Khan d'Angkor", *BEFEO* XLI : 255-302.

– 1941, "L'assistance médicale au Cambodge à la fin du XIIè siècle", *CEFEO*, 26 : 29-31.

– 1943, "Les stèle de Sdok Kak Thom", *BEFEO,* XLIII : 56-134.

– 1948, *Les Etats hindouisés d'Indochine et d'Indonésie*, Éd. de Boccard, Paris.

Déricourt, M., 1962, "Observations archéologiques aériennes", *BEFEO* L : 519-525.

Dumarçay, J., 1994, "Histoire des retenues d'eau khmères", *JA* CCLXXXII : 371-390.

– 1998, *L'architecture et ses modèles en Asie du sud-est*, Librairie Oriens, Paris.

Finot, L., 1925, "Dharmaçālās au Cambodge", *BEFEO* XXV : 417-422.

Foucher, A., 1903, "Les édicules des gîtes d'étapes", *J.A* I, dixième série : 174-180.

Giteau, M., 1976, *Angkor : un peuple, un art,* Office du livre, Fribourg (suisse).

– 1996, *Histoire d'Angkor,* PUF, Paris.

Glaize, M., 1963, *Les monuments du groupe d'Angkor,* 3ème édition, Ed. A. Maisonneuve, Paris.

Goloubew, V., 1934, "Le Phnom Bakhèng et la ville de Yaçovarman", *BEFEO* XXXIII : 219-241.

– 1935, "Nouvelles recherches autour du Phnom Bakhèng", *BEFEO* XXXIV : 556-557.

– 1937, "Reconnaissance aérienne au Cambodge", *BEFEO* XXXVI : 469-477.

– 1937, "Recherches dans Angkor Thom", *BEFEO* XXXVI : 619-623.

– 1938, "La double enceinte et les avenues d'Angkor Thom. Leur études et leur dégagements systématiques", *CEFEO* 14 : 33-39.

– 1938, "Chaussée à gradin de pierre. Recherches dans Angkor Thom", *BEFEO* XXXVII : 651-664.

Groslier B-P., 1958, *Angkor et le Cambodge au XVI*[ème] *siècle d'après les sources portugaises et espagnoles,* PUF, Paris.

– 1960, *Indochine, carrefour des arts*, Albin-Michel, Paris.

– 1979, "La cité hydraulique angkorienne : exploitation ou surexploitation du sol ?", *BEFEO* LXVI : 161-202.

Groslier, B-P. 1973, *Inscriptions du Bayon*, EFEO.

Groslier, G., 1921, *Recherches sur les Cambodgiens d'après les textes et les monuments depuis les premiers siècles de notre ère*, Augustin Challamel.

– 1924-1926, "Promenades artistiques et archéologiques au Cambodge", *AAK* 2 : 113-141.

Ishizawa, Y. & Tamura, H., 1999., Along the Royal Roads to Angkor, Weathehill, Inc., New York & Tokyo.

Jacques, C., & Dumont, R., 1990, Angkor, Bordas, Paris.

Le Bonheur, A., & Poncar, J., 1995, "Des dieux, des rois et des hommes", Ed. Olizaine, Genève.

Lunet de Lajonquière, E., 1902-1911, *Inventaire descriptif des monuments du Cambodge, 3 vol.* Publ. EFEO., Paris.

Malleret, L. 1959, "Ouvrages circulaires en terre dans l'Indochine méridional", *BEFEO* XLIX : 409-453.

Marchal, H., 1933, "Récents travaux d'Angkor", *RAA* VIII 1 : 52-56.

Martel G. 1975, *Lovea, village des environs d'Angkor,* EFEO, Paris

Maspéro, G., 1925, "La géographe politique de l'Indochine aux environ de l'an 960 A.D.", *EA* 2 : 79-125.

Maspéro, H., 1918, "La frontière de l'Annam et du Cambodge du VIII au XIV ème siècle", *BEFEO* XVIII : 29-36.

Paris, P., 1942, "L'importance rituelle du nord-est et ses applications en Indochine", *BEFEO* XLI : 316-333.

Parmentier, H., 1916, "Carte de l'Empire khmer d'après la situation des inscriptions datées", *BEFEO* XVI : 69-73.

– 1933, "Examen du levé d'avion du parc d'Angkor par capitaine Gouet les 24-26 jan. 1933 à 9 heures à l'altitude de 1.300 m., Siem Reap, 1933", dans "Chroniques", *BEFEO* XXXIII : 1111-1116.

– 1934, "Examen du nivellement d'Angkor", *BEFEO* XXXIII : 310-318.

Pelliot Paul, 1951, *Mémoire sur les coutumes du Cambodge de Tcheou Ta-Kouan*, A. Maisonneuve, Paris.

Pichard, P., 1976, *Pimay. Etude architecturale du temple*, Publ. EFEO., Paris.

Pou, S., 1981, " Notes historico-sémantiques khmères ", *ASEMI* XII, 1-2 : 111-124.

– 1992, *Dictionaire vieux khmer-français-anglais. An Old Khmer-French-English Dictionary*, Cedoreck

– 1992, "From Old Khmer Epigraphy to Popular Tradition: A study of the names of Cambodian monuments", *Southeast Asian Archaeology 1990*, Proceedings of the Third Conference of the EASEAA, ed. Ian Glover, Center for South-East Asian Studies, University of Hull: 7-24.

Im, S. 1995, *La vie quotidienne khmère à l'époque d'Angkor d'après les bas-reliefs du Bayon*, mémoire de fin d'études, Phnom Penh (inédit)

– 1998, *Les réseaux routiers et moyens de transport à l'époque angkorienne du IX[ème] au XIV[ème] siècles*, mémoire présenté en vue du diplôme de l'EHESS, Paris (inédit)

Khut, S. 2003, *Aménagement territorial au nord d'Angkor Thom*, Mémoire de fin d'études, Phnom Penh (inédit)

Stern, P., 1939, "Hariharâlaya et Indrapura", *BEFEO* XXXVIII : 175-189.

– 1951, "Diversité et rythme des fondations royales Khmères", *BEFEO* XLIV : 649-685.

Trouvé, G., 1934, "Chroniques", *BEFEO* XXXIII : 528.

Trouvé, G., 1945, "Les chaussées et canaux autour d'Angkor Thom", *BEFEO* XXXIV : 1120-1128.

Vickery, M., 1985, "The reign of Sûryavarman I and the dynamics of Angkorean development", in *The eighth conference international association of historiants of Asia*, Kuala Lumpur

– 1998, *Society, Economics and Politics in Pre-Angkor Cambodia,* The Centre for East Asian Cultural Studies for Unesco, The Toyo Bunko.

– 2004, "Cambodia and Its Neighbors in the 15th Century", *Working Paper Series No. 27*, Asia Research Institute, Singapore.

**Abstract**

This article presents current knowledge on the major axes and more minor communication routes out of Angkor, as well as related infrastructures. It describes, in particular, remains situated within modern Cambodia's borders, suggesting future research to be carried out in neighboring states. It does not treat as yet poorly studied road networks out of pre-Angkorian centers.

Five major axes are described. One leaves from the Bakheng, passing through Roluos to "end" in Kompong Kdei (beyond this point the route remains hypothetical). The second, also originating at the Bakheng, but heading east, passes through Chau Srei Vibol and Beng Mealea to end at Bakan (otherwise known as "Preah Khan of Kompong Svay"). This same axis branches from Beng Mealea the north to reach Koh Ker and Vat Phu. From the northwestern corner of the Western Baray another dyke-road passes by Phnom Srok to reach Sdok Kak Thom. The fourth axis originates in Angkor Thom and also leads to the northwest. The end-point currently known for this route is Phimai. It passes over the famous bridge "Spean Toap," the O Smach region, Muang Tam and Phnom Rung. A last axis has been identified to the north of Angkor Thom. This heads west to Kbal Spean, but can be tracked for only some 20 kilometers.

As is to be expected, all sorts of structures are found along these routes, including 93 bridges (curiously, no bridges have been identified to date in Thailand), hospital chapels and rest houses, all constructed during the reign of Jayavarman VII, as well as water reservoirs of all sizes which are often difficult to date...

Based on extensive field surveys and archival research, including reference to images produced through remote sensing, this article provides a crucial update on Angkorian communication routes and associated structures.

**Résumé**

Cet article représente l'état de nos connaissances sur les grands axes et autres voies de communication partant d'Angkor, et aussi les structures y relatifs. Il traite notamment des vestiges situés en territoire cambodgien actuel, laissant ouverte la partie relevant aujourd'hui des pays voisins pour les recherches à venir. Pour l'instant il délaisse également le réseau routier (dont on sait encore si peu) partant d'autres centres que sont les grandes cités pré-angkoriennes.

Cinq importants axes sont ainsi décrits. L'un part du Bakhèng, passant par Roluos pour " aboutir " à Kompong Kdei (au-delà, les tracés sont encore hypothétiques). Le deuxième, toujours partant du Bakhèng, mais vers l'est, passant par Chau Srei Vibol, Beng Mealea pour se terminer à Bakan (dit " Preah Khan de Kompong Svay). Le même axe présente une bifurcation à Beng Mealea qui mène au nord : Koh Ker, Vat Phu. De l'angle nord-ouest du Baray occidental part une autre chaussée-digue qui conduit à Sdok Kâk Thom, passant par Phnom Srok. Le quatrième axe part d'Angkor Thom et se dirige aussi vers le nord-ouest. Sa destination actuellement connue est Phimai. Il passe par le fameux pont Spean Toap, la région d'Ô Smach, Muang Tam, Phnom Rung. Enfin du nord d'Angkor Thom, on a repéré un axe passant à l'ouest de Kbal Spean, et dont on perd trace au bout d'environ 20 km.

Comme il est normal, le long de ces axes on trouve des structures de toutes sortes, notamment les ponts, au nombre de 93 (curieusement il n'en existe aucun en Thaïlande), les chapelles des hôpitaux ainsi que les gîtes d'étapes, tous construits sous Jayavarman VII, les réservoirs d'eau de tailles variées, dont souvent il est difficile de connaître les dates de construction...

Voici donc, pour la première fois depuis assez longtemps, un passage en revue des voies de communications et les structures y afférentes présenté après nombre de voyages sur le terrain. Il faut aussi souligner que les images de télédétection ont beaucoup aidé à la présente étude.